# ការឃ្លាំមើលសេរីភាពមូលដ្ឋាន នៅកម្ពុជា

## របាយការណ៍ប្រចាំឆ្នាំទី៦

ខែមករា ដល់ខែធ្នូ ឆ្នាំ២០២១




### គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សមាគមអាដហុក
ADHOC

SOLIDARITY CENTER
AFL-CIO

គាំទ្រដោយ៖

ICNL
INTERNATIONAL CENTER FOR NOT-FOR-PROFIT LAW

# មាតិកា


មូលន័យសង្ខេប ........................................................................ 4

សេចក្តីផ្តើម ........................................................................ 9

១. ចំណុចគន្លឹះទី១ ៖ តើក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានច្បាប់អន្តរជាតិដែរឬទេ? ........................................................................ 11

១.១. អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ........................................................................ 12

១.២ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ........................................................................ 16

១.៣. សង្ឃប្រកាស ........................................................................ 20

ចំណុចគន្លឹះទី២៖ តើក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធសេរីភាពមូលដ្ឋាន ត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវដែរឬទេ? ........................................................................ 22

២.១. សេរីភាពខាងសមាគម ........................................................................ 25

២.២. សេរីភាពខាងការបញ្ចេញមតិ ........................................................................ 31

២.៣. សេរីភាពខាងការជួបប្រជុំ ........................................................................ 36

៣. ចំណុចគន្លឹះទី៣៖ តើបុគ្គលម្នាក់ៗយល់ដឹងអំពីសេរីភាពមូលដ្ឋាន និងយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសេរីភាពទាំងនេះដែរឬទេ? ........................................................................ 42

៣.១. ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅតែមានកម្រិតថេរដដែល ........................................................................ 42

៣.៣. ពលរដ្ឋកម្ពុជាភាគច្រើនយល់ថាមានសេរីភាពកាន់តែខ្លាំងឡើងក្នុងការអនុវត្តសេរីភាពស្របច្បាប់របស់ខ្លួន ........................................................................ 45

៤. ចំណុចគន្លឹះទី៤៖ តើអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានទទួលស្គាល់និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាលកម្ពុជាដែរឬទេ? ........................................................................ 51

៤.១ ថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីពមិនត្រូវបានរដ្ឋាភិបាលមើលឃើញថាជាដៃគូដែលមានសមត្ថភាពដែលនាំឱ្យកិច្ចសហប្រតិបត្តិការមានកម្រិតទាប ........................................................................ 51

៤.២ ជំនាញ និងធាតុចូលរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហីពដែលជាដៃគូដ៏សំខាន់ ពុំសូវបានបញ្ចូលនោះទេ ........................................................................ 54

៤.៣ ឱកាសទទួលបានហិរញ្ញប្បទានរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពមិនត្រូវបានផ្សព្វផ្សាយនិងពិបាកស្វែងរក ........................................................................ 54

សេចក្តីសន្និដ្ឋាន ........................................................................................................ 56
ឧបសម្ព័ន្ធទី១ ៖ វិធីសាស្ត្រ និងការប្រមូលទិន្នន័យ ........................................................................ 58
ឧបសម្ព័ន្ធទី ២ ៖ តារាងលទ្ធផលនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ........................................... 62
ឧបសម្ព័ន្ធទី៤៖ សំណួរ និងលទ្ធផលនៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព................. 120

# មូលន័យសង្ខេប

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានពិនិត្យមើលពីស្ថានភាពនៃសេរីភាពមូលដ្ឋានចំនួន៣ គឺ សេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)[1] នៅក្នុងព្រះរាជាណាចក្រកម្ពុជា ("ប្រទេសកម្ពុជា")។ គម្រោងប្រើប្រាស់ឧបករណ៍ឃ្លាំមើលជាច្រើន គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានផ្តល់នូវទិដ្ឋភាពបែបសត្យានុម័ត ថាតើសេរីភាពមូលដ្ឋានបានចែងនៅក្នុងច្បាប់ និងអនុវត្តបែបណានៅទូទាំងប្រទេសកម្ពុជា។

ទិន្នន័យដែលគម្រោងប្រមូលបាននៅចន្លោះថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ (ឆ្នាំទី៦) បានបង្ហាញថា លំហនៃការអនុវត្តសេរីភាពមូលដ្ឋាននៅតែមានកម្រិតនៅឡើយ។ ជាញឹកញាប់ទង្វើរបស់អាជ្ញាធរត្រូវបានចាត់ទុកជាការរឹតត្បិតសេរីភាពមូលដ្ឋានដោយហេតុថាច្បាប់មិនបានអនុញ្ញាត ខណៈដែលក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជារារាំងបន្ថែមទៀតដល់ការអនុវត្តសេរីភាពមូលដ្ឋាន ហើយមានសាធារណជនតិចតួចប៉ុណ្ណោះបានរាយការណ៍ថា មានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះ។

*តួលេខទី១៖ ចំនួនហេតុការណ៍ដែលមានការការពារ ការរឹតត្បិត ឬរំលោភបំពាន សេរីភាពមូលដ្ឋានក្នុងឆ្នាំទី៦*




គម្រោងបានកត់ត្រាហេតុការណ៍សរុបចំនួន ៤៥៤ ករណី ទាក់ទងនឹងការអនុវត្តសេរីភាពមូលដ្ឋាន ក្នុងឆ្នាំទី៦។ ក្នុងចំណោមហេតុការណ៍ទាំងនេះ មាន ៣៤១ ករណី បង្ហាញថា មានការរឹតត្បិត ឬការរំលោភសេរីភាពមូលដ្ឋាន យ៉ាងហោចណាស់មួយករណី។[2]

*តួលេខទី២៖ ផែនទីភូមិសាស្ត្របង្ហាញហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពានសេរីភាពមូលដ្ឋាន*




ហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬរំលោភលើសេរីភាពមូលដ្ឋានត្រូវបានកត់ត្រានៅគ្រប់រាជធានី-ខេត្តនៃប្រទេសកម្ពុជា។ ករណីភាគច្រើនកើតឡើងនៅរាជធានីភ្នំពេញ ដោយមានហេតុការណ៍ចំនួន ១៦៥ ករណី ត្រូវបានកត់ត្រា។

[1] សម្រាប់គោលបំណងនៃរបាយការណ៍នេះ សេរីភាពមូលដ្ឋានរួមមានសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ។ គម្រោងអនុម័តយកនិយមន័យនៃពាក្យ 'សមាគម' ដែលប្រើដោយអ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងសមាគម។

[2] ភាពខុសគ្នារវាងការរឹតត្បិត និងការរំលោភបំពានសិទ្ធិ គឺការរឹតត្បិតអាចធ្វើបានដោយមានច្បាប់អនុញ្ញាតជាក់លាក់ ខណៈដែលការរំលោភបំពានគឺផ្ទុយពីបទដ្ឋានច្បាប់អន្តរជាតិ។

របកគំហើញសំខាន់ៗចំនួន៥ ដែលគាំទ្រដល់ការសន្និដ្ឋានរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ថាលំហនៃការអនុវត្តសេរីភាពមូលដ្ឋាននៅឆ្នាំទី៦ ត្រូវបានរងការរឹតត្បិត។ ប្រទេសកម្ពុជា បានអនុម័តបទប្បញ្ញត្តិច្បាប់ចំនួនបី ដែលរារាំងដល់ការអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានរបស់បុគ្គលម្នាក់ៗ (**របកគំហើញទី១**) ។ គម្រោងក៏បានកត់ត្រាផងដែរនូវការប៉ុនប៉ងជាច្រើនលើកច្រើនសារទាំងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងភាគីទីបី ដើម្បីរារាំងក្រុមនយោបាយជំទាស់ (**របកគំហើញទី២**)។ របកគំហើញក្នុងឆ្នាំទី៦ បង្ហាញថា អាជ្ញាធរបានជ្រៀតជ្រែកតាមទំនើងចិត្តលើការជួបប្រជុំគ្នា (**របកគំហើញទី៣**) ហើយការរឹតត្បិតលើការបញ្ចេញមតិតាមអនឡាញ មានការកើនឡើង (**របកគំហើញទី៤**) ។ របកគំហើញសំខាន់ៗទាំងនេះ អាចពន្យល់ពីមូលហេតុដែលបុគ្គលម្នាក់ៗ នៅតែមិនមានសេរីភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន (**របកគំហើញទី៥**) ។

## របកគំហើញទី១៖ ការកែប្រែក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជា អាចរារាំងដល់លទ្ធភាពរបស់បុគ្គលម្នាក់ៗក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេ។

ច្បាប់ និងបទប្បញ្ញត្តិថ្មីៗចំនួនបី ត្រូវបានអនុម័តក្នុងឆ្នាំទី៦ ដែលមានផលប៉ះពាល់ ឬប៉ះពាល់ដល់លទ្ធភាពរបស់បុគ្គលម្នាក់ៗក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេ៖

- *អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ* ត្រូវបានអនុម័តកាលពីខែកុម្ភៈ ឆ្នាំ២០២១។ អនុក្រឹត្យនេះបង្កើតនូវច្រកទ្វារអ៊ីនធឺណិតជាតិ ដែលនឹងច្រោះយករាល់ការទំនាក់ទំនង និងទិន្នន័យតាមអ៊ីនធឺណិតទាំងក្នុង និងក្រៅប្រទេស មុនពេលបញ្ជូនទៅដល់អ្នកប្រើប្រាស់ចុងក្រោយ។ ដោយសារតែអនុក្រឹត្យនេះ ផ្តល់នូវការត្រួតពិនិត្យបែបនេះដល់រដ្ឋាភិបាលតាមរយៈប្រព័ន្ធអ៊ីនធឺណិត ដែលទំនងជានឹងប៉ះពាល់ដល់ការអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំតាមអនឡាញ។
- *ច្បាប់ស្តីពីវិធានការបង្ការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត* (ហៅកាត់ថាច្បាប់កូវីដ-១៩) ត្រូវបានអនុម័តកាលពីខែមីនា ឆ្នាំ២០២១។ ច្បាប់នេះផ្តល់សិទ្ធិអំណាចឱ្យអាជ្ញាធរក្នុងការរឹតត្បិតលើសិទ្ធិសេរីភាពខាងសមាគម និងសេរីភាពខាងការជួបប្រជុំក្រោមលេសប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។
- *សង្ឃប្រកាស* ដែលបានអនុម័តកាលពីខែធ្នូ ឆ្នាំ២០២១ ហាមឃាត់ព្រះសង្ឃមិនឱ្យចូលរួមក្នុងរាល់ការតវ៉ា ឬបាតុកម្មទាំងអស់។

## របកគំហើញសំខាន់ទី២៖ ក្រុមនយោបាយនយោបាយជំទាស់ត្រូវបានកំណត់ជាមុខសញ្ញា

អាជ្ញាធរ និងភាគីទីបីបានកំណត់មុខសញ្ញានូវបុគ្គលទាំងឡាយ ដែលត្រូវបានគេយល់ថា ជាប់ទាក់ទងជាមួយនឹង ឬដែលមានការជាប់ទាក់ទងជាក់ស្តែងជាមួយគណបក្សនយោបាយជំទាស់ ទោះបីជាការ ពាក់ព័ន្ធ ឬចូលរួមជាមួយគណបក្សនយោបាយ គឺជាសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងសមាគមក៏ដោយ។ គម្រោងបានកត់ត្រាមានបុគ្គលយ៉ាងហោចណាស់ ២៨២ នាក់ ដែលបានទទួលរងនូវការរឹតត្បិតលើសេរីភាពខាងសមាគម ។ ១០១ នាក់ (ឬ ៣៥%) គឺជាសកម្មជននយោបាយ ឬអ្នកនយោបាយមកពីគណបក្សជំទាស់។ ការជ្រៀត

ជ្រែកលើសេរីភាពខាងសមាគមរបស់សកម្មជននយោបាយ មានដូចជា ការតាមដានហួសហេតុ[3] បណ្ដឹងផ្លូវច្បាប់[4] ការបំភិតបំភ័យ[5] និងការវាយដំលើរាងកាយ។[6]

**របកគំហើញទី៣៖ អាជ្ញាធរបានជ្រៀតជ្រែកតាមទំនើងចិត្តលើការជួបប្រជុំ។**

ទោះបីជាសេរីភាពខាងការជួបប្រជុំត្រូវបានការពារយ៉ាងទូលំទូលាយនៅឆ្នាំទី៦ក៏ដោយ ក៏មិនមានការគោរពស្មើៗគ្នាពីអាជ្ញាធរចំពោះសេរីភាពនេះឡើយ។ គោលបំណងនៃការជួបប្រជុំហាក់ដូចជាសំខាន់ណាស់។ អាជ្ញាធរបានជ្រៀតជ្រែក ៩៥% នៃការជួបប្រជុំរបស់ក្រុមស្ត្រីថ្ងៃសុក្រ[7] ដែលបានអំពាវនាវសុំឱ្យមានការដោះលែងសមាជិកគណបក្សសង្គ្រោះជាតិដែលកំពុងជាប់ពន្ធនាគារ។ ដូចគ្នានេះដែរ អាជ្ញាធរមិនបានជ្រៀតជ្រែកលើការជួបប្រជុំផ្សេងៗទៀតទេ។ ការជ្រៀតជ្រែកលើការជួបប្រជុំរបស់ក្រុមស្ត្រីថ្ងៃសុក្រ រួមមានការរឹបអូសបដា និងការប្រើប្រាស់កម្លាំងច្រើនហួសហេតុពីសំណាក់អាជ្ញាធរ។[8]

---

[3] រ៉ដ្ឋល ចិត្រា & តេង យ៉ាលីរ៉ូហ្សី "នាយករដ្ឋមន្ត្រីបានប្រាប់ពីការលបស្តាប់ការសន្ទនារបស់គណបក្សសង្គ្រោះជាតិ" (ខេមបូឌៀននីស, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១) https://cambodianess.com/article/pm-tells-of-listening-in-on-exiled-cnrp ។

[4] ឡាយ សាមាន និង គឹម សារុំ "លោក សម រង្ស៊ី ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ២៥ ឆ្នាំ" (ភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២១) https://phnompenhpost.com/national-politics/rainsy-sentenced-25-years ។

[5] កាន់ វិច្ឆិកា "ការរឹតត្បិត ភាពភ័យខ្លាច និងបញ្ហាជីវភាព រុកគួនអតីតមន្ត្រីបក្សជំទាស់និងគ្រួសារ" (វីអូអេ, ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១)https://khmer.voanews.com/a/opposition-loyalists-live-in-fears-of-arrests-violence-and-economic-hardships-amid-relentless-political-crackdowns/5756653.html?fbclid=IwAR26JST6lTCUWIBntLcv-LJPPMLyB1P7LkXvAeEtSRg8mp1Sey0nzGA-uPc ។

[6] Joshua Lipes, "សកម្មជនបក្សជំទាស់ចុងក្រោយត្រូវបានជនមិនស្គាល់មុខវាយប្រហារនៅកម្ពុជា" (អាស៊ីសេរី, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/attack-02162021163449.html ។

[7] ស្ត្រីថ្ងៃសុក្រ គឺជាក្រុមស្ត្រីដែលតែងជួបប្រជុំគ្នារៀងរាល់ថ្ងៃសុក្រ ដើម្បីសុំឱ្យមានការដោះលែងសាច់ញាតិរបស់ពួកគេចេញពីពន្ធនាគារ ដោយពួកគេសុទ្ធតែជាសមាជិកគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងដ៏ធំមួយត្រូវបានរំលាយចោលកាលពីឆ្នាំ២០១៧។

[8] សូមមើលឧទាហរណ៍៖ ខៃ សុណង "ក្រុមស្ត្រីថ្ងៃសុក្រ បន្តដាក់ញត្តិទៅស្ថានទូតអូស្ត្រាលី" (អាស៊ីសេរី, ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១) https://www.rfa.org/khmer/news/politics/peaceful-protester-who-are-families-of-jailed-dissidents-submit-petition-to-australian-embassy-09232021102717.html; ឃុត សុគុន្ធា "គ្រួសារអតីតសកម្មជនគណបក្សសង្គ្រោះជាតិ បន្តធ្វើការតវ៉ានៅមុខតុលាការ" (វីអូឌី, ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១) https://vodkhmer.news/2021/01/29/former-cnrp-activist-families-continues-their-protest-in-front-of-court/ ។

**របកគំហើញទី៤៖ ការរឹតត្បិតលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត មានការកើនឡើង។**

*តួលេខទី៣៖ ភាគរយនៃហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត សេរីភាពខាងការបញ្ចេញមតិតាមអ៊ីនធឺណិតពីសំណាក់រដ្ឋាភិបាល*




រាជរដ្ឋាភិបាលកម្ពុជា បានពង្រីកការតាមដានរបស់ខ្លួនលើការបញ្ចេញមតិតាមអនឡាញនៅឆ្នាំទី៦[9] ដែលបង្ហាញថាមានការកើនឡើងករណីរឹតត្បិតការបញ្ចេញមតិតាមអនឡាញដោយស្របច្បាប់។ នេះបង្ហាញថារាជរដ្ឋាភិបាលកម្ពុជាកាន់តែមិនអត់ឱនចំពោះការនិយាយរិះគន់តាមអនឡាញ។

**របកគំហើញទី៥៖ បុគ្គលម្នាក់ៗនៅតែមិនមានសេរីភាពពេញលេញក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន**

ចំនួនបុគ្គលដែលបានរាយការណ៍ថា មានអារម្មណ៍ថាមានសេរីភាពក្នុងការបញ្ចេញមតិនៅលើបណ្ដាញទំនាក់ទំនងសង្គម (សូមមើលតួលេខទី៤)[10] និងជាសាធារណៈ (សូមមើលតួលេខទី៥) មានការកើនឡើងនៅឆ្នាំទី៦។[11] ទោះបីនេះគឺជាការលើកទឹកចិត្តមួយ និងបង្ហាញថា បុគ្គលម្នាក់ៗមិនត្រូវបានរារាំងចំពោះការបញ្ចេញមតិដោយសេរីដែលកំពុងមានបរិយាកាសរួមតូចកើនឡើងនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏មានការព្រួយបារម្ភថា ប្រជាជនកម្ពុជាតិចជាង ៥០% ដែលមានអារម្មណ៍ថា មានសេរីភាពខាងការបញ្ចេញមតិដោយផ្ទាល់ ឬតាមអនឡាញ។

*តួលេខទី៤៖ ភាគរយនៃអ្នកឆ្លើយតបដែលមានអារម្មណ៍ថា មានសេរីភាពខាងការបញ្ចេញមតិនៅលើបណ្ដាញទំនាក់ទំនងសង្គម*




*តួលេខទី៥៖ ភាគរយនៃអ្នកឆ្លើយតបដែលមានអារម្មណ៍ថាមានសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈ*




ពលរដ្ឋកម្ពុជាមិនទទួលបានសេរីភាពពេញលេញក្នុងការជួបប្រជុំ និងសេរីភាពខាងសមាគមនោះទេ ដូចដែលបានបង្ហាញចំនួនដ៏ទាបនៃអ្នកឆ្លើយតបដែលបានរាយការណ៍ថា មានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ឬចូលរួមក្នុងសកម្មភាពនយោបាយនៅឆ្នាំទី៦។ មានតែ ៥៥% នៃអ្នកឆ្លើយតបប៉ុណ្ណោះបាននិយាយថា

---

[9] "កម្ពុជាពង្រីកការឃ្លាំមើល "ព័ត៌មានក្លែងក្លាយ" (សារព័ត៌មាន UCA ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២១) https://www.ucanews.com/news/cambodia-expands-monitoring-of-fake-news/91186# ។

[10] ទិន្នន័យនៅក្នុងតួលេខទី៤ រួមមាន ចំនួនអ្នកឆ្លើយតបដែលបានរាយការណ៍ថា *"មានសេរីភាពខ្លាំងណាស់"* ឬ *"មានសេរីភាពខ្លះដែរ"* ក្នុងការបញ្ចេញមតិនៅលើបណ្ដាញទំនាក់ទំនងសង្គម។

[11] ទិន្នន័យក្នុងតួលេខទី៥ រួមមានចំនួនអ្នកឆ្លើយតបដែលបានរាយការណ៍ថា *"មានសេរីភាពខ្លាំងណាស់"* ឬ *"មានសេរីភាពខ្លះដែរ"* ក្នុងការបញ្ចេញមតិជាសាធារណៈ។

ពួកគេមានអារម្មណ៍ថាមានសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី (សូមមើលតួលេខទី៦)[12] ដែលជាភាគរយដ៏ទាបថាការជួបប្រជុំរបស់បុគ្គលម្នាក់ៗត្រូវបានរឹតត្បិត ទោះបីជាសេរីភាពខាងការជួបប្រជុំជាសេរីភាពមូលដ្ឋានមួយដែលត្រូវតែមានក្នុងលទ្ធិប្រជាធិបតេយ្យក៏ដោយ។ ដូចគ្នាដែរ នៅតែមានការព្រួយបារម្ភដោយសារមានតែ ២៩% នៃអ្នកឆ្លើយតបប៉ុណ្ណោះបាននិយាយថា ពួកគេមានអារម្មណ៍ថា មានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ (សូមមើលតួលេខទី៧) ។[13] របកគំហើញនេះបង្ហាញថា បរិយាកាសបច្ចុប្បន្ននៅកម្ពុជាមិនមានអំណោយផលចំពោះទិដ្ឋភាពនយោបាយដែលកំពុងមានការរីកចម្រើននោះទេ ដែលបង្ហាញពីក្ដីកង្វល់មួយ ចំពោះការបោះឆ្នោតនៅឆ្នាំ២០២២ និងឆ្នាំ២០២៣ នាពេលខាងមុខ។

*តួលេខទី៦៖ ភាគរយនៃអ្នកឆ្លើយតបដែលមានអារម្មណ៍ថា មានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី*




*តួលេខទី៧៖ ភាគរយនៃអ្នកឆ្លើយតបលមានអារម្មណ៍ថា មានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ*




[12] ទិន្នន័យនៅក្នុងតួលេខទី៦ រួមមានចំនួនអ្នកឆ្លើយតបដែលបានរាយការណ៍ថា *"មានសេរីភាពខ្លាំងណាស់"* ឬ *មានសេរីភាពខ្លះដែរ"* ក្នុងការជួបប្រជុំដោយសន្តិវិធី។

[13] ទិន្នន័យក្នុងតួលេខទី៧ រួមមានចំនួនអ្នកឆ្លើយតបដែលបានរាយការណ៍ថា *"មានសេរីភាពខ្លាំងណាស់"* ឬ *"មានសេរីភាពខ្លះដែរ"* ក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ។

# សេចក្តីផ្តើម

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ គឺជាគម្រោងរយៈពេលវែងដែលពិនិត្យតាមដាន និងវាយតម្លៃអំពីស្ថានភាពសេរីភាពមូលដ្ឋានចំនួនបី គឺសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិនិងសេរីភាពខាងការជួបប្រជុំ ("សេរីភាពមូលដ្ឋាន")[14] នៅក្នុងប្រទេសកម្ពុជា។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន តាមដានការអនុវត្តសេរីភាពមូលដ្ឋានដោយប្រើប្រាស់ឧបករណ៍តាមដានការឃ្លាំមើល ("MTT")។ នេះជារបាយការណ៍ឆ្នាំទី៦ ដែលពិនិត្យតាមដានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានមានគោលបំណងបង្ហាញពីទិដ្ឋភាពបែបសត្យានុម័តអំពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជានាពេលបច្ចុប្បន្ននេះដោយកំណត់និន្នាការដែលទាក់ទងទៅនឹងច្បាប់ និងការអនុវត្តសេរីភាពមូលដ្ឋាន។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រុមការងារគម្រោងបានបង្កើតនូវឧបករណ៍តាមដានការឃ្លាំមើលក្នុងការផ្តល់ជាក្របខ័ណ្ឌសត្យានុម័តនិងតុល្យភាព សម្រាប់ពិនិត្យអំពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជាដោយផ្តោតលើការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងពលរដ្ឋ។ ឧបករណ៍តាមដានឃ្លាំមើលវាយតម្លៃនេះវាយតម្លៃជាលក្ខណៈប្រព័ន្ធថាតើសេរីភាពមូលដ្ឋានត្រូវបានធានា និងអនុវត្តនៅក្នុងប្រទេសកម្ពុជាដល់កម្រិតណា។

ឧបករណ៍តាមដានការឃ្លាំមើលមានធាតុផ្សំចំនួន ១៥២ ដែលឆ្លើយតបទៅនឹងចំណុចគន្លឹះសំខាន់ៗចំនួន ៤ ដែលពិនិត្យមើលថាតើ៖

**ចំណុចគន្លឹះទី១៖** ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិ

**ចំណុចគន្លឹះទី២៖** ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងប្រតិបត្តិតាម

**ចំណុចគន្លឹះទី៣៖** បុគ្គលយល់ដឹងអំពីសេរីភាពមូលដ្ឋាននិងសិទ្ធិដែលពាក់ព័ន្ធនិងយល់ថាខ្លួនអាចអនុវត្តសេរីភាពនេះដោយសេរី និង

**ចំណុចគន្លឹះទី៤៖** អង្គការសង្គមស៊ីវិលនិងសហជីពត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល។

---

[14] ក្នុងគោលបំណងនៃរបាយការណ៍នេះ សេរីភាពមូលដ្ឋានរួមមាន៖ សេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបជុំ។ គម្រោងប្រើប្រាស់នូវនិយមន័យនៃពាក្យសមាគម ដែលកំណត់ដោយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី និងសមាគម។

នៅក្នុងរបាយការណ៍ឆ្នាំទី៦នេះ វិធីសាស្ត្រប្រមូលទិន្នន័យចំនួន ៦ ត្រូវបានប្រើដើម្បីវាស់ចំណុចគន្លឹះទាំងនេះ ៖ យន្តការរាយការណ៍ពីហេតុការណ៍ដែលបានកើតឡើង[15] ការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន[16] ការពិនិត្យមើលទៅលើច្បាប់ដែលពាក់ព័ន្ធ ("ការពិនិត្យច្បាប់")[17] ឧបករណ៍វាយតម្លៃការចុះបញ្ជិកាសហជីព[18] ការស្ទង់មតិជាសាធារណៈ[19] និងការស្ទង់មតិជាមួយនឹងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ("ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព")[20]។ របាយការណ៍នេះបង្ហាញអំពីការវិភាគនៃចំណុចគន្លឹះនីមួយៗ និងរបត់ផ្សេងៗដោយផ្អែកលើទិន្នន័យដែលប្រមូលបាននៅក្នុងឆ្នាំទី៦។

---

[15] ការរាយការណ៍ពីហេតុការណ៍ត្រូវបានប្រមូលតាមរយៈទម្រង់មួយដែលត្រូវបានបង្កើតឡើងដើម្បីកត់ត្រានូវការរឹតត្បិតទៅលើសេរីភាពខាងសមាគមនិងសិទ្ធិដែលទាក់ទងដទៃទៀតជាមួយបុគ្គល និងសមាគម។

[16] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាគឺជាអ្នកតាមដានជាប្រចាំទៅលើការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ការតាមដាននេះផ្តោតទៅលើការផ្សព្វផ្សាយរបស់សារព័ត៌មានពីសេរីភាពខាងសមាគមនិងសិទ្ធិទាក់ទិនដទៃទៀត និងត្រូវកំណត់ដោយគោលការណ៍ណែនាំអំពីការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយផ្អែកទៅលើឧបករណ៍តាមដានការឃ្លាំមើល។

[17] ការពិនិត្យលើច្បាប់ត្រូវបានធ្វើឡើងដោយមានការវិភាគពីអ្នកជំនាញទៅលើខ្លឹមសារនៃច្បាប់ គោលនយោបាយ របាយការណ៍ និងឯកសារផ្លូវការដទៃទៀតដើម្បីធ្វើការវាយតម្លៃឱ្យដឹងថាតើមានការធានាដោយច្បាប់ប៉ុណ្ណា និងមានលក្ខខណ្ឌណាផ្សេងទៀតដែរឬទេដែលធានាដល់សេរីភាពមូលដ្ឋាន ។

[18] ឧបករណ៍វាយតម្លៃការចុះបញ្ជីសហជីពកត់ត្រាទុកនូវបទពិសោធន៍របស់តំណាងសហជីព ដែលព្យាយាមចុះបញ្ជីរបស់ពួកគេដែលតម្រូវតាមច្បាប់សហជីព។

[19] ការស្ទង់មតិជាសាធារណៈគឺដើម្បីស្វែងយល់ពីការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាន។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងជាភាសាខ្មែរចន្លោះពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

[20] ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវធ្វើឡើងជាប្រចាំឆ្នាំតាមរយៈប្រព័ន្ធអ៊ីនធឺណិត និងការសម្ភាសផ្ទាល់ដើម្បីស្វែងយល់ពីទស្សនៈ និងបទពិសោធន៍របស់ថ្នាក់ដឹកនាំពាក់ព័ន្ធនឹងលទ្ធភាពរបស់ពួកគេក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ នៅក្នុងឆ្នាំទី៦នេះ ដោយសារតែមានការរីករាលដាលជំងឺកូវីដ-១៩ ការស្ទង់មតិនេះត្រូវបានធ្វើតាមរយៈអនឡាញតែប៉ុណ្ណោះគឺចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

## ១. ចំណុចគន្លឹះទី១ ៖ តើក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានច្បាប់អន្តរជាតិដែរឬទេ?

ចំណុចគន្លឹះទី១ ពិនិត្យមើលទៅលើវិសាលភាពក្របខ័ណ្ឌច្បាប់កម្ពុជាដែលអនុលោមតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន[21]។ នៅក្នុងឆ្នាំទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តច្បាប់ និងបទប្បញ្ញត្តិដូចខាងក្រោម ដែលតែមានលក្ខណៈរឹតត្បិតទៅលើសេរីភាពមូលដ្ឋាន និងមិនអនុលោមតាមច្បាប់អន្តរជាតិ៖ (ក) *អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលត្រូវបានអនុម័តនៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ (ខ) ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត* ដែលត្រូវបានអនុម័តនៅក្នុងខែមីនា ឆ្នាំ២០២១ និង (គ) សង្ឃប្រកាស ដែលត្រូវបានប្រកាសនៅក្នុងខែធ្នូ ឆ្នាំ២០២១។

កម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ដែលមានចែងនៅក្នុងច្បាប់កម្ពុជាមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ[22]។ ចំពោះការរឹតត្បិតទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិសេរីភាពខាងការជួបប្រជុំ ឬសិទ្ធិសេរីភាពខាងការបង្កើតសមាគមដែលបានអនុញ្ញាតនៅក្រោមច្បាប់អន្តរជាតិ ការរឹតត្បិតនោះត្រូវតែអនុលោមតាមគោលការណ៍នៃលក្ខខណ្ឌតម្រូវបី ដែលមានចែងនៅក្នុងមាត្រា ១៩ មាត្រា ២១ និងមាត្រា ២២ នៃ ក.អ.ស.ព.ន។

---

[21] របកគំហើញនៅក្នុងចំណុចគន្លឹះទី១ ផ្អែកចម្បងលើការពិនិត្យឯកសារច្បាប់។ ការពិនិត្យឯកសារនេះ ធ្វើការវិភាគទៅលើវិសាលភាពដែលក្របខ័ណ្ឌច្បាប់ជាតិទាក់ទងនឹងសេរីភាពមូលដ្ឋានអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលកើតចេញពី សន្ធិសញ្ញាអន្តរជាតិ និងបទដ្ឋានអន្តរជាតិដូចដែលគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UN) និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានបកស្រាយ។ នៅក្នុងរបាយការណ៍នេះ "ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" សំដៅដល់ច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងសេរីភាពមូលដ្ឋានរួមមានសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ដែលបានកើតចេញពីសន្ធិសញ្ញាអន្តរជាតិមានប្រទេសកម្ពុជាជារដ្ឋហត្ថលេខី។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាផ្តល់ធម្មនុញ្ញភាពដល់សិទ្ធិមនុស្សដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងកតិកាសញ្ញា និងអនុសញ្ញាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។ សេចក្តីសម្រេចចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបកស្រាយជាផ្លូវការនូវមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា សន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នគឺអាចអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ជាតិ។ សូមមើលសេចក្តីសម្រេច លេខ ០៩២/០០៣/២០០៧ (ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សន្ធិសញ្ញាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួមមាន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច និងវប្បធម៌ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ បន្ថែមក្រៅពីសន្ធិសញ្ញាទាំងនេះ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ក៏ប្រើបទដ្ឋានអន្តរជាតិផ្សេងៗ ដែលគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានបកស្រាយផងដែរ។

[22] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ ២ https://ccc.gov.kh/detail_info_en.php?_txtID=453។

| មាត្រានៃ ក.អ.ស.ព.ន | លក្ខខណ្ឌតម្រូវបី |
|---|---|
| **មាត្រា ១៩៖ សិទ្ធិសេរីភាពខាងការបញ្ចេញមតិ** | ដើម្បីអាចអនុញ្ញាតស្របតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ការរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិត្រូវតែ៖<br>១) មានចែងដោយច្បាប់មានភាពជាក់លាក់ និងច្បាស់លាស់។<br>២) គោរពសិទ្ធិឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ និង<br>៣) ភាពចាំបាច់ និងសមាមាត្រជាមួយនឹងគោលបំណង[23]។ |
| **មាត្រា ២១៖ សិទ្ធិសេរីភាពខាងការជួបប្រជុំ** | ដើម្បីអាចអនុញ្ញាតស្របតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ការរឹតត្បិតលើសិទ្ធិសេរីភាពខាងការជួបប្រជុំត្រូវតែ៖<br>១. អនុវត្តស្របតាមច្បាប់ ដែលមានភាពជាក់លាក់ និងច្បាស់លាស់។<br>២. ដើម្បីផលប្រយោជន៍សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការពារសុខភាពសាធារណៈ សីលធម៌ ឬការពារសិទ្ធិ និងសេរីភាពអ្នកដទៃ និង<br>៣. មានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ និងសមាមាត្រទៅនឹងគោលបំណង[24]។ |
| **មាត្រា ២២៖ សិទ្ធិសេរីភាពសមាគម** | ដើម្បីអាចអនុញ្ញាតស្របតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ការរឹតត្បិតលើសិទ្ធិសេរីភាពខាងសមាគមត្រូវតែ៖<br>១) មានចែងក្នុងច្បាប់ ដែលជាក់លាក់ និងច្បាស់លាស់។<br>២) ដើម្បីផលប្រយោជន៍សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការពារសុខភាពសាធារណៈ សីលធម៌ ឬការពារសិទ្ធិ និងសេរីភាពអ្នកដទៃ និង<br>៣) ភាពចាំបាច់ និងសមាមាត្រទៅនឹងគោលបំណង[25]។ |

## ១.១. អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលត្រូវបានអនុម័តនៅខែកុម្ភៈ អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពខាងការប្រើប្រាស់អ៊ីនធឺណិត

អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិដែលបានអនុម័តនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ បានបង្កើតនូវច្រកទ្វារអ៊ីនធឺណិតជាតិនៅក្នុងប្រទេសកម្ពុជា។ ច្រកទ្វារអ៊ីនធឺណិតជាតិធ្វើការបញ្ជូនចរាចរណ៍ អ៊ីនធឺណិតទាំងអស់ទៅកន្លែងជាក់លាក់ ដើម្បីតាមដានលើចរាចរណ៍បណ្តាញអ៊ីនធឺណិតទាំងចេញ និងចូល ដែល

[23] ក.អ.ស.ព.ន មាត្រា ១៩(៣), គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, អនុសាសន៍ទូទៅលេខ ៣៤៖ មាត្រា ១៩៖ សេរីភាពខាងការបញ្ចេញយោបល់ និងមតិ CCPR/C/GC/៣៤ (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) វាក្យខណ្ឌ ២៥ https://www2.ohchr.org/english/bodies/hrc/docs/gc34.pdf។

[24] ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "របាយការណ៍រួមរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងសមាគម និងរបស់អ្នករាយការណ៍ពិសេសអំពីការអនុវត្តដោយបង្ខំក្រៅប្រព័ន្ធតុលាការភ្លាមៗ ឬតាមអំពើចិត្តលើការគ្រប់គ្រងត្រឹមត្រូវនៃការជួបប្រជុំ" A/HRC/៣១/៦៦ (ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦) វាក្យខណ្ឌ ៣០ https://undocs.org/A/HRC/31/66។

[25] ក.អ.ស.ព.ន មាត្រា ២២។

នេះអនុញ្ញាតឱ្យមានការច្រោះយកព័ត៌មាន និងបិទមិនឱ្យដំណើរការនូវមាតិកាព័ត៌មានជាក់លាក់ណាមួយ។ ច្រកទ្វារអ៊ីនធឺណិតជាតិ[26]នេះនឹងតម្រូវឱ្យគ្រប់ការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអ៊ីនធឺណិតទាំងអស់និងទិន្នន័យក្នុងប្រទេសនិងក្រៅប្រទេសត្រូវតែច្រោះចូលតាមច្រកទ្វារអ៊ីនធឺណិតជាតិជាមុនសិនមុននឹងធ្វើការបញ្ជូនទៅកាន់អ្នកប្រើប្រាស់។

អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិបាន បង្ហាញអំពីរបៀបធ្វើប្រតិបត្តិការ និងគ្រប់គ្រងរបស់ច្រកទ្វារអ៊ីនធឺណិតជាតិ ហើយបានផ្តល់សិទ្ធិអំណាចដល់ប្រតិបត្តិករដែលត្រូវបានតែងតាំងដោយរដ្ឋាភិបាល (ប្រតិបត្តិករច្រកទ្វារអ៊ីនធឺណិតជាតិ) និងស្ថាប័នរដ្ឋមួយចំនួន រួមទាំងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនិយ័តករទូរគមនាគមន៍កម្ពុជាផងដែរ។ ការណ៍ដែលប្រតិបត្តិករច្រកទ្វារអ៊ីនធឺណិតជាតិនឹងត្រូវតែជាប្រតិបត្តិករដែលបានតែងតាំងដោយរដ្ឋាភិបាល និងមានភារកិច្ចធ្វើការងារដោយសហការជាមួយអាជ្ញាធរនេះ មានន័យថារាជរដ្ឋាភិបាលនឹងអាចគ្រប់គ្រងស្ទើរតែទាំងស្រុងទៅលើប្រតិបត្តិការរបស់ច្រកទ្វារអ៊ីនធឺណិតជាតិនេះ។ ហេតុដូច្នេះ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិនេះ បង្កជាក្តីបារម្ភយ៉ាងខ្លាំងសម្រាប់សិទ្ធិមនុស្សនាពេលខាងមុខក្នុងប្រទេសកម្ពុជា ដោយហេតុថានឹងរឹតត្បិតទៅលើលទ្ធភាពរបស់ពលរដ្ឋក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួននៅលើប្រព័ន្ធអនឡាញ។

### ១.១.១. អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិអាចនឹងត្រូវបានប្រើប្រាស់ដើម្បីរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិ

មាត្រា ១ មាត្រា ១ នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិបានចែងថាគោលបំណងនៃការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដូចមានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមថាជា *"ច្រកទ្វារដែលសេវាអ៊ីនធឺណិតទាំងអស់ត្រូវបានតភ្ជាប់គ្នាទាំងក្នុងប្រទេស និងអន្តរជាតិ"* គឺក្នុងគោលបំណង *"សម្រួល និងគ្រប់គ្រងការតភ្ជាប់បណ្តាញអ៊ីនធឺណិតដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការកៀរគរចំណូលជាតិការការពារសន្តិសុខជាតិ និងការថែរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សង្គម"*។

រាល់ការប្រាស្រ័យទាក់ទង និងទិន្នន័យទាំងអស់ដែលបានចរាចរណ៍តាមអ៊ីនធឺណិតតម្រូវឱ្យឆ្លងកាត់ជាមុនតាមច្រកទ្វារអ៊ីនធឺណិតជាតិ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិនេះបង្កើតជាមធ្យោបាយមួយដែលអាចជួយសម្រួលដល់ការតាមដានយ៉ាងជិតដល់ទៅលើការចែករំលែកព័ត៌មាន ឬសកម្មភាពតាមអនឡាញក្នុងគោលបំណង *"ធ្វើការលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការកៀរគរចំណូលជាតិការការពារសន្តិសុខជាតិ និងការថែរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សង្គម"*។ ការរំលោភលើសិទ្ធិឯកជនភាពជាមធ្យោបាយ

[26] អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិត្រូវបានអនុម័តនៅថ្ងៃ១៦ ខែកុម្ភៈ ឆ្នាំ២០២១ ដោយទុកពេលជូនក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ("ISPs") និងក្រុមហ៊ុនអ៊ីនធឺណិតរយៈពេល ១២ ខែនៅក្នុងការរៀបចំផ្លូវបណ្តាញអ៊ីនធឺណិតឡើងវិញរបស់ខ្លួនឱ្យតភ្ជាប់ជាមួយនឹងច្រកទ្វារអ៊ីនធឺណិតជាតិដែលត្រូវបានគេរំពឹងថានឹងអាចធ្វើប្រតិបត្តិការនៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០២២។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានប្រកាសអំពីការផ្អាកអនុវត្តអនុក្រឹត្យនេះ។

ដែលអនុញ្ញាតឱ្យមានដូចជាការចាប់យកនិងការដោនរាល់ទំនាក់ទំនងជាលក្ខណៈឯកជន អាចរារាំងដល់បុគ្គលគ្រប់រូបពីការបញ្ចេញមតិដោយសេរី ដែលនេះចាត់ទុកថាការរឹតត្បិតចំពោះសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

យោងតាមមាត្រា ១ ដែលចែងថា *"ការថែរក្សារបៀបរៀបរយសណ្ដាប់ធ្នាប់សង្គម"* គឺមិនមានភាពច្បាស់លាស់បណ្ដាលឱ្យមានការការបកស្រាយតាមការយល់ឃើញ ដោយបំពានទៅលើលក្ខខណ្ឌតម្រូវដែលច្បាប់បានកំណត់ថាជាការរឹតត្បិតចំពោះសេរីភាពមូលដ្ឋានត្រូវតែបំពេញតាមគោលការណ៍នៃភាពជាក់លាក់ និងភាពច្បាស់លាស់។ ប្រការនេះអាជ្ញាធរអាចបកស្រាយយ៉ាងទូលំទូលាយ ដោយអះអាងថាច្បាប់អនុញ្ញាតឱ្យខ្លួនធ្វើអំពើនេះបាន ដែលនេះប៉ះពាល់ដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ចំពោះការប្រើពាក្យថា *"សន្តិសុខជាតិ"* ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបញ្ជាក់យ៉ាងច្បាស់ថា *"ការផ្ដល់ហេតុផលមិនច្បាស់លាស់ និងទូលំទូលាយខ្លាំងពេកដូចជា ការចែងមិនជាក់លាក់អំពី "សន្តិសុខជាតិ" មិនមានលក្ខណៈគ្រប់គ្រាន់ច្បាស់លាស់ជាច្បាប់នោះទេ"*[27]។ ដូច្នេះ មាត្រា ១ មិនបានបំពេញចំណុចទីមួយនៃលក្ខខណ្ឌតម្រូវបីចំណុចនៃមាត្រា ១៩ នោះទេ។

ជាងនេះទៅទៀត មិនថាទាំង "ការកៀរគរចំណូលជាតិ" ឬ *"ការថែរក្សារបៀបរៀបរយសណ្ដាប់ធ្នាប់សង្គម"* នោះទេដែលចាត់ទុកថាជាគោលដៅស្របច្បាប់ក្នុងការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិបាននោះ នេះគឺបំពានទៅលើចំណុចទីពីរនៃលក្ខខណ្ឌបីចំណុចនៃមាត្រា ១៩។

ជាចុងក្រោយ ការផ្ដល់សិទ្ធិឱ្យអាជ្ញាធរ *"ការត្រួតពិនិត្យយ៉ាងទូលំទូលាយ"*[28] តាមអ៊ីនធឺណិត *"ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការកៀរគរចំណូលជាតិ ការការពារសន្តិសុខជាតិ និងការថែរក្សារបៀបរៀបរយសណ្ដាប់ធ្នាប់សង្គម"* ត្រូវបានចាត់ទុកថាពុំមានភាពចាំបាច់បំផុត ឬមានសមាមាត្រនោះទេ។ វិធានការត្រួតពិនិត្យកាន់តែតិចតួចជាជាងការគ្រប់គ្រងទាំងស្រុងរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធអ៊ីនធឺណិតអាចធ្វើបានហើយដើម្បីសំរេចនូវគោលបំណងទាំងនេះបាន ខណៈដែលមនុស្សគ្រប់រូបអាចទទួលបានសិទ្ធិឯកជនភាព និងសិទ្ធិសេរីភាពខាងការបញ្ចេញមតិប្រសើរឡើង។

មាត្រា ៦

មាត្រា ៦ ចែងប្រគល់ភារកិច្ចច្រកទ្វារអ៊ីនធឺណិតជាតិដល់ប្រតិបត្តិករចាត់តាំងដោយរាជរដ្ឋាភិបាល ដើម្បីធ្វើការសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនិយ័តករទូរគមនាគមន៍កម្ពុជា និងអាជ្ញាធរពាក់ព័ន្ធផ្សេងៗបិទដំណើរការ និងផ្ដាច់ការតភ្ជាប់តាមអនឡាញ ឬមាតិកាណាដែលត្រូវបានចាត់ទុកថា *"ប៉ះពាល់ដល់សុវត្ថិភាព ចំណូលជាតិ សណ្ដាប់ធ្នាប់សង្គម សេចក្ដីថ្លៃថ្នូរ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់"*។ ហេតុផលដែលមិនមានភាពច្បាស់លាស់ និងទូលំទូលាយក្នុងការដកយកមាតិកាព័ត៌មាន រួមជាមួយនឹងការត្រួតពិនិត្យយ៉ាងខ្លាំងនេះ នាំឱ្យរាជរដ្ឋាភិបាលនឹងមានការដោះដូរលើទិន្នន័យនៅក្នុងប្រទេសនឹង

---

[27] ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, "សិទ្ធិឯកជនភាពនៅយុគសម័យឌីជីថល" A/HRC/៣៩/២៩ (ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៨) វាក្យខណ្ឌ ៣៥ https://documents-dds-ny.un.org/doc/UNDOC/GEN/G18/239/58/PDF/G1823958.pdf?OpenElement ។

[28] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស, កម្ពុជា៖ បទប្បញ្ញត្តិតាមដានទិន្នន័យគឺមាន "លក្ខណៈបង្ក្រាប" មិនត្រូវអនុវត្តឡើយ– អ្នកជំនាញអង្គការសហប្រជាជាតិ" (ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២) https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=28077&LangID=E ។

អនុញ្ញាតឱ្យរាជរដ្ឋាភិបាលធ្វើការត្រួតត្រាលើមាតិកាតាមអនឡាញយ៉ាងមានប្រសិទ្ធភាព ដោយពិចារណាទៅលើភាពទូលំទូលាយ និងភាពមិនច្បាស់លាស់នៃមូលហេតុក្នុងការដកហូតលើមាតិកាស្ទើរតែទាំងអស់ រួមទាំងមាតិកាដែលគ្មានគ្រោះថ្នាក់អាចត្រូវបានចាត់ទុកថាមានផលប៉ះពាល់ដល់មាតិកានោះ។ ឧទាហរណ៍ របាយការណ៍ដែលព្យាករណ៍អំពីការធ្លាក់ចុះនូវកំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា ឬរបាយការណ៍ដែលនិយាយអំពីការខូចខាតហេដ្ឋារចនាសម្ព័ន្ធបន្ទាប់ពីព្យុះអាចត្រូវបានគេចាត់ទុកថាប៉ះពាល់ដល់ "ចំណូលជាតិ" និង"សុវត្ថិភាព"ហើយរបាយការណ៍ទាំងនេះត្រូវក៏ត្រូវបានបិទដំណើរការ។

ពាក្យដែលមិនមានកំណត់និយមន័យដូចជា *"សុវត្ថិភាព ចំណូលជាតិ សណ្តាប់ធ្នាប់សង្គម សេចក្តីថ្លៃថ្នូរ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់"* ដែលមានចែងនៅក្នុងមាត្រា ៦ គឺអាចបកស្រាយដោយផ្អែកលើការយល់ឃើញក្នុងកម្រិតខ្ពស់។ ដូចនេះ វាមានការលំបាកខ្លាំងក្នុងការយល់ឱ្យបានច្បាស់លាស់អំពីមាតិកាណាដែលគួរបិទដំណើរការ ដូច្នេះហើយការបង្កការរារាំងដល់បុគ្គលម្នាក់ៗនៅក្នុងការកែតម្រូវអាកប្បកិរិយារបស់ពួកគេដើម្បីធានាបាននូវការអនុលោមតាមច្បាប់។ ដូច្នេះ មាត្រា ៦ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ត្រង់ចំណុចទីមួយនៃលក្ខខណ្ឌបីចំណុចក្នុងមាត្រា ១៩ ហើយនឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលធ្វើការត្រួតពិនិត្យ និងដកហូតលើមាតិកានៅតាមអនឡាញតាមអំពើចិត្ត ដែលខ្លួនចាត់ទុកថាផ្ទុយនឹងគោលបំណងរបស់ច្បាប់។

ការអនុញ្ញាតឱ្យប្រតិបត្តិករច្រកទ្វារអ៊ីនធឺណិតជាតិបិទដំណើរការ និងផ្តាច់ការតភ្ជាប់តាមអនឡាញឬមាតិកាដែលផ្ទុយនឹងគោលបំណងទាំងនេះ មានលក្ខណៈហួសហេតុពីព្រោះថាការរឹតត្បិតបែបនេះគឺមានលក្ខណៈទូលំទូលាយខ្លាំងពេក និងហួសពីភាពចាំបាច់យ៉ាងតឹងរ៉ឹងដើម្បីសម្រេចបាននូវគោលបំណងស្របច្បាប់។ ហានិភ័យនៃ "បិទដំណើរការទាំងស្រុង " គឺជាការរឹតត្បិតដោយមិនត្រឹមត្រូវលើបណ្តាញតភ្ជាប់ ឬមាតិកាស្របច្បាប់ ដែលមានចែងនៅក្នុងមាត្រា ៦ គឺមានន័យថាវាមានលក្ខណៈមិនសមាមាត្រ[29] និងមិនបំពេញតាមចំណុចទីបីនៃលក្ខខណ្ឌតម្រូវក្នុងមាត្រា ១៩ នោះឡើយ។

លើសពីនេះទៅទៀត មាត្រា ៦ បានបំពានលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិឆ្នាំ២០២០ បានតម្រូវរដ្ឋសមាជិកមិនឱ្យដាក់ចេញនូវការរឹតត្បិតដោយខុសច្បាប់លើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ រួមទាំងតាមរយៈ *"ការប្រើប្រាស់នូវការបិទអ៊ីនធឺណិតដោយចេតនា និងតាមអំពើចិត្តដើម្បីរារាំង ឬរំខានដល់ការចូលប្រើប្រាស់ ឬការផ្សព្វផ្សាយព័ត៌មានតាមអនឡាញឡើយ"*។[30] ដោយហេតុថា អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិបានផ្តល់អំណាចឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងលើអ៊ីនធឺណិត រាជរដ្ឋាភិបាលអាចនឹងបង្អាក់ការតភ្ជាប់អ៊ីនធឺណិត បិទដំណើរការ នូវមាតិកាតាមអនឡាញណា

[29] ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពខាងការបញ្ចេញយោបល់ និងមតិ ហ្វ្រែនយ៍ ឡា រី A/HRC/១៧/២៧ (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១ វាក្យខណ្ឌ ៣១ https://www2.ohchr.org/english/bodies/hrcouncil/docs/17session/a.hrc.17.27_en.pdf ។

[30] ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេរីភាពខាងការបញ្ចេញយោបល់ និងមតិ A/HRC/៤៤/L.១៨/កំណែ ១ (ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២០) វាក្យខណ្ឌ ៨(ធ) https://ap.ohchr.org/documents/dpage_e.aspx?si=A/HRC/44/L.18/Rev.1 ។

ដែលខ្លួនមិនចូលចិត្ត ឬបិទមិនឱ្យដំណើរការអ៊ីនធឺណិតតែម្ដង។ ហើយអាចនឹងប្រើប្រាស់វាជាគោលដៅលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។

### ១.១.២. អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិអាចត្រូវបានប្រើប្រាស់ដើម្បីរឹតត្បិតលើសិទ្ធិសេរីភាពខាងការជួបប្រជុំ

**មាត្រា ៦** មាត្រា ៦ នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ក៏អាចជាបញ្ហាសម្រាប់សិទ្ធិសេរីភាពខាងការជួបប្រជុំផងដែរ ពីព្រោះរាជរដ្ឋាភិបាលអាចប្រើប្រាស់អនុក្រឹត្យនេះដើម្បីបិទអ៊ីនធឺណិត ឬបិទដំណើរការ សេវាកម្មជាក់លាក់ដូចជា ប្រព័ន្ធបណ្តាញសង្គម ឬសេវាកម្មសន្និសីទវីដេអូ ដែលជារឿយៗត្រូវបានប្រើប្រាស់ដោយពលរដ្ឋ ដើម្បីអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំនៅលើអ៊ីនធឺណិត។[31] សិទ្ធិសេរីភាពខាងការជួបប្រជុំ រួមមានសិទ្ធិក្នុងការចូលរួម និងរៀបចំការជួបជុំតាមអ៊ីនធឺណិត។[32]

នៅមាត្រា ៦ ប្រតិបត្តិករច្រកទ្វារអ៊ីនធឺណិតជាតិទទួលបានសិទ្ធិអំណាចនៅក្នុងការ *"គ្រប់គ្រង និងបង្កលទ្ធភាពងាយស្រួលក្នុងការតភ្ជាប់ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ បណ្តាញនិងសេវាអ៊ីនធឺណិតនៅគ្រប់ច្រកទ្វារអ៊ីនធឺណិតជាតិ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតឆ្លងកាត់ព្រំដែនគោក"*។ ចំណុចនេះ អនុញ្ញាតឱ្យរាជរដ្ឋាភិបាលបិទអ៊ីនធឺណិត ឬកាត់ផ្តាច់ការការប្រាស្រ័យទាក់ទងតាមអ៊ីនធឺណិតដោយចេតនា ឬការប្រាស្រ័យទាក់ទងតាមសារអេឡិចត្រូនិក ដោយធ្វើមិនឱ្យអាចទទួលបាន ឬមិនអាចប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព[33]។ សិទ្ធិអំណាចដ៏ទូលំទូលាយដែលផ្តល់ឱ្យរាជរដ្ឋាភិបាលនេះ គឺជាមូលហេតុបង្កឱ្យមានការភ័យខ្លាចថាការបិទអ៊ីនធឺណិត ដូចមានចែងក្នុងមាត្រា ៦ ដែលនេះអនុវត្តហួសពីភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដូច្នេះគឺមិនស្របតាមចំណុចទីបីនៃលក្ខខណ្ឌតម្រូវបីនៅក្នុងមាត្រា ២១។

### ១.២ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ផ្តល់សិទ្ធិអំណាចដោយគ្មានការត្រួតពិនិត្យដល់អាជ្ញាធរដែលអាចរឹតត្បិតសេរីភាពមូលដ្ឋាននៅក្រោមរូបភាពប្រយុទ្ធនឹងជំងឺកូវីដ-១៩

នៅក្នុងខែមីនា ឆ្នាំ២០២១ រាជរដ្ឋាភិបាល បានអនុម័តច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត (ច្បាប់ជំងឺកូវីដ-១៩)។ បញ្ញត្តិជាច្រើននៃច្បាប់ជំងឺកូវីដ-១៩ គឺមានបញ្ហា និងផ្តល់សិទ្ធិអំណាចដោយគ្មានការត្រួតពិនិត្យដល់អាជ្ញាធរ។

---

[31] ICNL សេចក្តីពន្យល់ស្តីពីច្រកទ្វារអ៊ីនធឺណិតកម្ពុជា។

[32] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ អនុសាសន៍ទូទៅលេខ ៣៧៖ (ឆ្នាំ២០២០) ស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី (មាត្រា ២១) CCPR/C/GC/៣៧ (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០) វាក្យខណ្ឌ ១៣ https://undocs.org/CCPR/C/GC/37

[33] ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ការបញ្ឈប់ការបិទអ៊ីនធឺណិត៖ ដំណើរឆ្ពោះទៅមុខ – របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងខាងការបង្កើតសមាគម A/HRC/៤៧/២៤/បន្ថែម ២ (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១) វាក្យខណ្ឌ ៧ https://undocs.org/A/HRC/47/24/Add.2 ដកស្រង់ចេញគំនិតផ្តួចផ្តើមបណ្តាញសកល "បានផ្តល់ការតភ្ជាប់៖ អភិក្រមសិទ្ធិមនុស្សចំពោះការរំខានការតភ្ជាប់បណ្តាញ" (ឆ្នាំ២០១៧)។

មាត្រា ៤ មាត្រា ៤ នៃច្បាប់ជំងឺកូវីដ-១៩ ផ្តល់សិទ្ធិអំណាចរាជរដ្ឋាភិបាលនៅក្នុងការដាក់ចេញជា "បណ្តោះអាសន្ន" នូវ "វិធានការរដ្ឋបាល និងវិធានការផ្សេងទៀត" ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។ នេះរាប់បញ្ចូលទាំងការហាមប្រាម ឬការរឹតត្បិតលើការធ្វើដំណើរ ឬប្រតិបត្តិការអាជីវកម្ម ដែលអាចបង្កឱ្យមានការរីករាលដាលនៃជំងឺកូវីដ-១៩ ឬការបិទខ្ទប់តំបន់ដែលមានមេរោគឆ្លង។ មាត្រា ៤ នេះ ក៏បញ្ជាក់ផងដែរថា រាជរដ្ឋាភិបាលអាចចាត់ "វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលមានភាពចាំបាច់ដើម្បីឆ្លើយតប និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩"។ ហានិភ័យដែលមិនមានដែនកំណត់នៃមាត្រា ៤ រួមទាំងភាពមិនច្បាស់លាស់នៃវាក្យសព្ទនៅក្នុងមាត្រានេះផងដែរ។ អាជ្ញាធរមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយនៅក្នុងការអនុវត្តវិធានការដើម្បីបញ្ឈប់ការរីករាលដាលនៃជំងឺកូវីដ-១៩។ ភាសាទូលំទូលាយនៃមាត្រា ៤ នេះ មានន័យថាអាជ្ញាធរអាចប្រើប្រាស់មាត្រានេះដើម្បីអនុវត្តវិធានការតាមអំពើចិត្តហួស ពីគោលដៅប្រឆាំងនឹងជំងឺកូវីដ-១៩។ ជាពិសេស មាត្រា ៤ ផ្តល់អំណាចឱ្យអាជ្ញាធរ ដែលបាម្តថាអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងពលរដ្ឋ ឬស្ថាប័នដែលគេយល់ថាបានរិះគន់ដល់រាជរដ្ឋាភិបាល។

ការប្រើប្រាស់វាក្យសព្ទ "បណ្តោះអាសន្ន" ក៏បង្កឱ្យមានការព្រួយបារម្ភផងដែរ។ ខណៈពេលដែលវិធានការគ្រាអាសន្ន អាចត្រូវបានអនុវត្តដើម្បីការពារសុខភាពសាធារណៈ ទោះបីជាមិនមានស្ថានភាពគ្រាអាសន្នត្រូវបានប្រកាសក៏ដោយ ក៏វិធានការបែបនេះត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពស្របច្បាប់ ភាពចាំបាច់ និងសមាមាត្រ[34]។ ភាពមិនច្បាស់លាស់នៃពាក្យ "បណ្តោះអាសន្ន" បើកឱ្យមានការបកស្រាយតាមការយល់ឃើញដោយបំពានលើលក្ខខណ្ឌតម្រូវនៃភាពស្របច្បាប់។ ការគ្មានពេលវេលាជាក់លាក់ ឬកាលបរិច្ឆេទផុតកំណត់សម្រាប់វិធានការទាំងនេះ អាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាលបកស្រាយយ៉ាងទូលំទូលាយនូវមាត្រា ៤ និងអនុម័តវិធានការទាំងនេះដោយគ្មានដែនកំណត់ សូម្បីតែនៅពេលដែលលែងមានភាពចាំបាច់ក៏ដោយ។

### ១.២.១. ច្បាប់ជំងឺកូវីដ-១៩ ត្រូវបានប្រើប្រាស់ដើម្បីរឹតត្បិតសេរីភាពខាងការជួបប្រជុំ

មាត្រា ៤ មាត្រា ៤ នៃច្បាប់ជំងឺកូវីដ-១៩ អនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចដាក់ចេញជាបណ្តោះអាសន្ននូវការអនុវត្តវិធានការរដ្ឋបាល ឬវិធានការផ្សេងទៀត ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មានជាអាទិ៍ ការរឹតត្បិត ឬការហាមឃាត់ *"ការជួបជុំ និងការប្រមូលផ្តុំមនុស្ស ដែលអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩"*។ បញ្ញត្តិមិនច្បាស់លាស់នេះអាចនាំឱ្យមានការរឹតត្បិតមិនសមហេតុផលទៅលើសេរីភាពខាងការជួបប្រជុំ។ ដោយសារតែការអនុវត្តជាបណ្តោះអាសន្ននូវវិធានការរឹតត្បិត ឬហាមឃាត់ការជួបប្រជុំ

---

[34] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស, "ជំងឺកូវីដ-១៩៖ រដ្ឋនានាមិនគួររំលោភលើវិធានគ្រាអាសន្នដើម្បីបង្ក្រាបលើសិទ្ធិមនុស្ស – អ្នកជំនាញអង្គការសហប្រជាជាតិ" (ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០) https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25722&LangID=E; OHCHR, "វិធានការគ្រាអាសន្ន និងជំងឺកូវីដ-១៩៖ ឯកសារណែនាំ" (ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០)។ https://www.ohchr.org/Documents/Events/EmergencyMeasures_Covid19.pdf។

អាចអនុវត្តទៅតាម ដើម្បីប្រយុទ្ធនឹងវិបត្តិសុខភាពសាធារណៈ ដូចជាការរាតត្បាតនៃជំងឺកូវីដ-១៩ ជាដើម[35] ពាក្យពេជន៍នៅក្នុងមាត្រា ៤ មិនមានភាពច្បាស់លាស់ ហើយបង្ហាញអំពីការផ្តល់សិទ្ធិអំណាចកាន់តែខ្លាំងដល់អាជ្ញាធរ ផ្ទុយពីចំណុចទីមួយ និងទីបីនៃលក្ខខណ្ឌតម្រូវក្នុងមាត្រា ២១។

ដើម្បីបំពេញតាមគោលការណ៍នីត្យានុកូលភាព ក្រោមចំណុចទីមួយនៃលក្ខខណ្ឌតម្រូវក្នុងមាត្រា ២១ ច្បាប់ត្រូវតែមានភាពច្បាស់លាស់គ្រប់គ្រាន់ ពោលគឺ មិនត្រូវផ្តល់អំណាចផ្តាច់មុខច្រើនពេកដល់អ្នកដែលអនុវត្តច្បាប់ឡើយ។[36] ពាក្យថា "ការជួបជុំ និងការប្រមូលផ្តុំមនុស្ស ដែលសកម្មភាពនេះអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩" គឺមិនមានភាពច្បាស់លាស់ និងមិនផ្តល់នូវលក្ខណៈវិនិច្ឆ័យអំពីប្រភេទនៃការប្រមូលផ្តុំដែលអាចត្រូវបានរឹតត្បិត និងហាមឃាត់នោះទេ។ ដូច្នេះ មាត្រា ៤ បានផ្តល់នូវសិទ្ធិអំណាចផ្តាច់មុខយ៉ាងទូលំទូលាយដល់អាជ្ញាធរ ដើម្បីសម្រេចចិត្តថាតើការប្រមូលផ្តុំមួយណាដែលបង្ហាញថាអាចឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បាន ដែលចំណុចនេះបានចោទជាបញ្ហាដែលថាការប្រមូលផ្តុំរបស់សកម្មជនជំទាស់ ឬអ្នកជំទាស់ដែលត្រូវបានកំណត់គោលដៅ។

ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវភាពចាំបាច់ ស្របតាមចំណុចទីបីនៃលក្ខខណ្ឌតម្រូវក្នុងមាត្រា ២១ វិធានការរឹតត្បិតត្រូវតែជាវិធានការមិនរំលោភច្បាប់ដើម្បីសម្រេចបាននូវគោលដៅស្របច្បាប់ ហើយវិធានការនេះត្រូវតែសមាមាត្រទៅនឹងប្រយោជន៍ដែលត្រូវការពារ។ ដូច្នេះ អាជ្ញាធរត្រូវកំណត់ករណីនីមួយៗជាក់លាក់ដោយរក្សាតុល្យភាពនៃផលប៉ះពាល់ពីការជ្រៀតជ្រែកមកលើការជួបប្រជុំដែលរារាំងដល់គោលដៅសំខាន់ដែលគេចង់បាន។[37]

កង្វះខាតនៃភាពជាក់លាក់ដែលកំណត់អំពីការជួបប្រជុំ "ថាអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩" រួមទាំងការផ្តល់អំណាចដល់អាជ្ញាធរធ្វើការហាមឃាត់ការជួបប្រជុំទាំងនេះ បង្កើតបានជាលក្ខខណ្ឌដែលហាមឃាត់ទាំងស្រុងលើការជួបប្រជុំអាចនឹងត្រូវអនុវត្ត ដោយមិនគិតថាវិធានការធូរស្រាលស្ថានភាពជំងឺកូវីដ-១៩ ឬទីតាំង និងគោលបំណងនៃការជួបប្រជុំយ៉ាងណានោះទេ។ ការហាមឃាត់ទាំងនេះ អាចនឹងរារាំងដល់ចំណុចពិចារណាមួយចំនួនអំពីកាលៈទេសៈជាក់លាក់នៃការជួបប្រជុំ និងអាចរំលោភដល់សិទ្ធិសេរីភាពខាងការជួបប្រជុំ។[38]

### ១.២.២. ច្បាប់ស្តីពីជំងឺកូវីដ-១៩ ត្រូវបានប្រើប្រាស់ដើម្បីរឹតត្បិតសេរីភាពខាងសមាគម

**មាត្រា ៤** មាត្រា ៤ នៃច្បាប់ស្តីពីកូវីដ-១៩ ក៏ជាការគំរាមកំហែងដល់សេរីភាពខាងសមាគម។ ទោះបីជាច្បាប់ស្តីពីកូវី-១៩ មិនបានបញ្ជាក់ឱ្យបានច្បាស់អំពី "ការជួបប្រជុំ និងការប្រមូលផ្តុំមនុស្ស" យ៉ាងណាក្តី ការបក

---

[35] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អនុសាសន៍ទូទៅលេខ ៣៧ (ឆ្នាំ២០២០) ស្តីពីការជួបប្រជុំដោយសន្តិវិធី (មាត្រា ២១) CCPR/C/GC/៣៧ (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០) វាក្យខណ្ឌទី ៤៥ https://undocs.org/CCPR/C/GC/37 ។

[36] ដូចខាងលើ, វាក្យខណ្ឌទី ៣៩។

[37] ដូចខាងលើ, វាក្យខណ្ឌទី ៤០។

[38] ដូចខាងលើ។

ស្រាយសមហេតុផលអាចនឹងលើកឡើងថារាជរដ្ឋាភិបាល អាចនឹងហាមឃាត់មនុស្សច្រើនប្រមូលផ្ដុំគ្នា ដែលជាផ្នែកមួយនៃការជួបប្រជុំឬការធ្វើសកម្មភាពជាក្រុមដែលអាចប៉ះពាល់ដល់សេរីភាពខាងសមាគម។

មាត្រា ៤ មិនបានអនុលោមតាមចំណុចទីមួយនៃលក្ខខណ្ឌតម្រូវបីចំណុចក្នុងមាត្រា ២២ នោះទេ ដោយសារតែមាត្រានេះមិនមានភាពច្បាស់លាស់ ថាតើអ្វីជា "ការជួបប្រជុំនិងការប្រមូលផ្ដុំមនុស្សដែលជាសកម្មភាពនេះអាចបណ្ដាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩" នោះទេ ដូច្នេះការនេះនឹងធ្វើឱ្យមានការប្រឈមសម្រាប់បុគ្គល និងក្រុម ដោយសារភាពមិនច្បាស់លាស់អំពីការជួបប្រជុំ និងការប្រមូលផ្ដុំណាដែលថាអាចអនុញ្ញាតបាននោះ។ មាត្រា ៤ អនុញ្ញាតឱ្យអាជ្ញាធរបកស្រាយតាមការយល់ឃើញរបស់ខ្លួនថាអ្វីជាការជួបប្រជុំ ឬប្រមូលផ្ដុំដែលខ្លួនហាមឃាត់ ដែលចំណុចនេះអាចនាំឱ្យមានការអនុវត្តច្បាប់តាមអំពើចិត្ត។

មាត្រា ៤ អនុញ្ញាតឱ្យមានការរឹតត្បិត និងហាមឃាត់ទាំងស្រុងលើការជួបប្រជុំ ឬការប្រមូលផ្ដុំមនុស្សនូវសកម្មភាពដែលអាចបណ្ដាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ មាត្រា ៤ អនុញ្ញាតឱ្យមានការរឹតត្បិតចំពោះការជួបប្រជុំ ឬការប្រមូលផ្ដុំដោយមិនពិចារណាទៅលើកាលៈទេសៈនីមួយៗនៃការប្រមូលផ្ដុំនោះ ដែលមិនបំពេញទៅតាមលក្ខខណ្ឌសមាមាត្រនៅក្នុងចំណុចទីបីក្នុងមាត្រា ២២ ។ ការរឹតត្បិតយ៉ាងទូលំទូលាយនេះមានលក្ខណៈលើសពីភាពចាំបាច់ និងសមាមាត្រទៅនឹងការឆ្លើយតបនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ដូច្នេះច្បាប់នេះរំលោភបំពានលើសេរីភាពខាងសមាគម។

**មាត្រា ៥** មាត្រា៥នៃច្បាប់ស្តីពីកូវីដ-១៩ បានផ្ដល់អំណាចលើសលុបដល់អាជ្ញាធរដើម្បីអនុវត្តទោសទណ្ឌដែលរួមបញ្ចូលទាំងការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម និងការបិទអាជីវកម្ម ទៅនឹងអ្នកដែលមិនគោរពតាម "វិធានការសុខាភិបាល រដ្ឋបាល និងវិធានការផ្សេងៗ" ដូចមានចែងនៅក្នុងមាត្រា ៣ និង ៤ នៃច្បាប់នេះ។ ទោសទណ្ឌដែលមានចែងក្នុងមាត្រា ៥ គឺមានលក្ខណៈធ្ងន់ធ្ងរហួសហេតុ វិធានការមិនសូវធ្ងន់ធ្ងរ ដូចជាការផាកពិន័យ អាចត្រូវបានអនុវត្តដើម្បីឆ្លើយតប និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩។ ដូច្នេះ មាត្រា ៥ រំលោភបំពានលើលក្ខខណ្ឌតម្រូវបានចែងថា ការរឹតត្បិតត្រូវតែមានភាពចាំបាច់ និងសមាមាត្រដើម្បីសម្រេចបាននូវគោលដៅស្របច្បាប់បំពេញតាមចំណុចទីបីនៃលក្ខខណ្ឌតម្រូវក្នុងមាត្រា ២២។ មាត្រានេះក៏បង្កើនឱ្យមានការព្រួយបារម្ភ ដោយហេតុតែប្រការនេះអាចនឹងត្រូវបានប្រើប្រាស់ជាអាវុធដើម្បីបង្ក្រាបទៅលើអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ ដែលរាជរដ្ឋាភិបាលតែងបានកំណត់មុខសញ្ញាជាញឹកញាប់ និងកាន់តែខ្លាំងឡើងក្នុងការរារាំងការចូលរួមរបស់សាធារណជន។

**មាត្រា ៩** មាត្រា ៩ នៃច្បាប់ជំងឺកូវីដ-១៩ កំណត់ទោសទណ្ឌឱ្យជាប់ពន្ធនាគាររហូតដល់ដប់ឆ្នាំ ប្រសិនបើជនណា "មានបំណងចម្លងជំងឺកូវីដ-១៩ ដោយចេតនាដល់អ្នកដទៃ"។ រយៈពេលនៃការដាក់ទោសនេះអាចនឹងមានការកើនឡើងរហូតដល់ ២០ ឆ្នាំ ប្រសិនបើអំពើនោះ ត្រូវបានធ្វើឡើងដោយមានការរៀបចំជាក្រុម ឬអង្គការចាត់តាំង។ មាត្រា ៩ មិនមានភាពច្បាស់លាស់ថាតើអ្វីទៅគឺជាអំពើចេតនានោះទេ ដែលនេះមិនអនុឡោមតាមលក្ខខណ្ឌតម្រូវដោយច្បាប់ត្រង់ចំណុចទីមួយមាត្រា ២២ ដូច្នេះធ្វើឱ្យសាធារណជនមិនបានយល់ច្បាស់ថាតើសកម្មភាពបែបណាដែលច្បាប់បានហាមប្រាម ហើយកែសម្រួលឥរិយាបថរបស់ខ្លួនទៅតាមលក្ខខណ្ឌតម្រូវ

នោះ។ មាត្រានេះ ធ្វើឱ្យបុគ្គល និងក្រុមបុគ្គលនោះងាយប្រឈមនឹងការកាត់ទោសជាប់ពន្ធនាគាររយៈពេលយូរផងដែរ។

ភាពធ្ងន់ធ្ងរនៃការដាក់ទោសព្រហ្មទណ្ឌនៅក្នុងមាត្រា ៩ នេះ គឺជាការឆ្លើយតបហួសហេតុដើម្បីគាំទ្រដល់វិធានការសុខភាពសាធារណៈប្រឆាំងនឹងជំងឺកូវីដ-១៩។ ការដាក់ទោសដែលមានចែងនៅក្នុងមាត្រា ៩ មានលក្ខណៈហួសហេតុខ្លាំងជាងអ្វីដែលភាពចាំបាច់ពិតប្រាកដក្នុងការសម្រេចគោលដៅនៃច្បាប់ ពោលគឺបំពានលើចំណុចទីបីនៃលក្ខខណ្ឌតម្រូវនៃមាត្រា ២២។[39]

មាត្រា ៩ អាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាលប្រកាសថាការជួបជុំ ឬការដំណើរការរបស់គណបក្សនយោបាយឬអង្គការសង្គមស៊ីវិល អាចរួមចំណែកបង្កឱ្យរីករាលដាលជំងឺកូវីដ-១៩ ដូច្នេះអាចឱ្យអាជ្ញាធរចាប់ខ្លួន និងពិន័យលើសមាជិកអង្គការសង្គមស៊ីវិលតាមអំពើចិត្ត ដោយរំលោភទៅលើសេរីភាពខាងសមាគម។

## ១.៣. សង្ឃប្រកាសរឹតត្បិតហួសហេតុលើសេរីភាពខាងការជួបប្រជុំរបស់ព្រះសង្ឃ

នៅក្នុងអំឡុងពេលមហាសន្និបាតមន្ត្រីសង្ឃលើកទី២៩ ដែលបានធ្វើឡើងនៅថ្ងៃទី២០ ដល់ ២១ ខែធ្នូ ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ មានសេចក្ដីសម្រេចចំនួនប្រាំពីរចំណុចដែលផ្ដោតលើការពង្រឹងវិន័យព្រះសង្ឃបានដាក់ចេញ។[40] ប្រកាសនេះបានចុះហត្ថលេខាដោយតំណាងមន្ត្រីសង្ឃ និងក្រសួងធម្មការ និងសាសនា។[41]

ចំណុចទីប្រាំ (ចំណុច ៥) នៃប្រកាសនេះ បានលើកឡើងគួរឱ្យព្រួយបារម្ភថាព្រះសង្ឃ *"មិនត្រូវចូលរួមក្នុងសកម្មភាពតវ៉ា បាតុកម្ម ការទាមទារ ឬកុប្បកម្មនៅទីសាធារណៈដែលនាំឱ្យបាត់បង់សេចក្ដីថ្លៃថ្នូរ និងភាពជាសង្ឃដោយប៉ះពាល់ដល់សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ។"* ចំណុចនេះបានបំពានដល់សេរីភាពខាងការជួបប្រជុំដែលមានចែងក្នុងមាត្រា ២១ នៃក.អ.ស.ព.ន។

### ១.៣.១. សង្ឃប្រកាស រឹតត្បិតសេរីភាពខាងការជួបប្រជុំ

**ចំណុចទី ៥** ចំណុចទី ៥ នៃប្រកាសនេះមិនបានបំពេញទៅតាមចំណុចទីពីរនៃលក្ខខណ្ឌតម្រូវបីចំណុចក្នុងមាត្រា ២១ ដែលចែងថា ការរឹតត្បិតត្រូវតែស្របទៅតាមគោលបំណងស្របច្បាប់។ បញ្ញត្តិ ដែលបង្កើតឱ្យមានទំនាក់ទំនងរវាងការចូលរួមរបស់ព្រះសង្ឃនៅក្នុងការប្រមូលផ្ដុំ និងការបាត់បង់សេចក្ដីថ្លៃថ្នូររបស់ព្រះសង្ឃ មានគោលដៅពង្រឹងសង្ឃវិន័យតាមរយៈការហាមឃាត់ព្រះសង្ឃចូលរួមក្នុងការប្រមូលផ្ដុំណាមួយឡើយ។ ការហាមឃាត់នេះមិនបានផ្ដល់ជាប្រយោជន៍ដល់គោលដៅច្បាប់ណាមួយដែលមានចែងនៅក្នុងមាត្រា ២១ ឡើយ។

---

[39] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អនុសាសន៍ទូទៅលេខ ៣៤៖ មាត្រា ១៩៖ សេរីភាពខាងការបញ្ចេញយោបល់ និងមតិ CCPR/C/GC/៣៤ (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) វាក្យខណ្ឌទី ៣៣ https://www2.ohchr.org/english/bodies/hrc/docs/gc34.pdf ។

[40] មុំ គន្ធា, "មហាសន្និបាទបានចេញប្រកាសហាមឃាត់ព្រះសង្ឃចូលរួមការតវ៉ា" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១) https://www.phnompenhpost.com/national/congress-issues-prakas-banning-monks-protest-participation ។

[41] សង្ឃប្រកាស គឺជាសេចក្ដីសម្រេចរបស់សម្ដេចព្រះសង្ឃរាជដែលជាអ្នកដឹកនាំផ្នែកព្រះពុទ្ធសាសនានៅកម្ពុជា។ សេចក្ដីប្រកាសនេះមិនមែនជាលិខិតគតិយុត្តដែលចេញដោយកម្រិតក្រសួង ដើម្បីអនុវត្ត និងបញ្ជាក់អំពីបញ្ញត្តិជាក់លាក់ដូចមាននៅក្នុងឋានុក្រមនូវលិខិតបទដ្ឋានគតិយុត្តនោះទេ។

លើសពីនេះ ការហាមឃាត់ព្រះសង្ឃចូលរួមក្នុងការប្រមូលផ្តុំ គឺមិនមានភាពចាំបាច់នោះទេនៅក្នុងសង្គមប្រជាធិបតេយ្យ ដោយសារតែការហាមឃាត់នេះមិនអាចចាត់ទុកថា "មានភាពចាំបាច់នៅក្នុងបរិបទសង្គមដែលផ្អែកលើលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងសិទ្ធិមនុស្ស"។[42] វាមិនសមាមាត្រនោះទេ ហើយវាគួរតែមានវិធានការរឹតត្បិតតិចតួចជាជាងការហាមឃាត់ទាំងស្រុងលើព្រះសង្ឃក្នុងការចូលរួមតវ៉ា ដើម្បីធានាភាពស្របច្បាប់ដូចមានចែងនៅក្នុងមាត្រា២១។ ដូច្នេះ ចំណុច ៥ នៃប្រកាសនេះមិនបានបំពេញទៅតាមលក្ខខណ្ឌទី៣ នៃមាត្រា ២១ ហើយចាត់ទុកថាជាការបំពានសេរីភាពខាងការជួបប្រជុំ។

ការអនុម័តអនុក្រឹតស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ច្បាប់កូវីដ-១៩ និងសង្ឃប្រកាសបានផ្តល់នូវហេតុផលចំពោះការព្រួយបារម្ភពីអនាគតនៃសេរីភាពមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ អនុក្រឹតស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិនេះ បង្ហាញពីការគំរាមកំហែងធ្ងន់ធ្ងរចំពោះការអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានទាំងបីតាមអនឡាញ។ អនុក្រឹតស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ នឹងជួយសម្រួលឱ្យមានការតាមដានការដកចេញ និងការគ្រប់គ្រងរបស់រដ្ឋាភិបាលមកលើបណ្តាញអ៊ីនធឺណិត។ បញ្ញត្តិមួយចំនួននៃច្បាប់កូវីដ-១៩ នៅមានបញ្ហា ដែលអនុញ្ញាតឱ្យអាជ្ញាធរប្រើប្រាស់វិធានការហួសពីកម្រិតនៃភាពចាំបាច់ដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩ ពោលគឺបំពានលើសេរីភាពមូលដ្ឋាន។ ចំណែកឯសង្ឃប្រកាសវិញ ក៏មានការរឹតត្បិតចំពោះសេរីភាពខាងការជួបប្រជុំរបស់ព្រះសង្ឃដែលជាការរារាំងហួសហេតុចំពោះការចូលរួមរបស់ព្រះសង្ឃដើម្បីផលប្រយោជន៍សាធារណៈ។

ដូច្នោះតាមរយៈការអនុម័តអនុក្រឹតស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ច្បាប់កូវីដ-១៩ និងសង្ឃប្រកាសក៏ដូចជាច្បាប់ផ្សេងៗ ដែលគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានធ្លាប់បានពិនិត្យមើលនៅពេលមុនអាចសន្និដ្ឋានជារួមថាក្របខ័ណ្ឌច្បាប់កម្ពុជានៅបន្តធ្វើការរឹតត្បិតដោយមិនត្រឹមត្រូវលើសេរីភាពមូលដ្ឋាននិងបំពានច្បាប់អន្តរជាតិ។

[42] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អនុសាសន៍ទូទៅលេខ ៣៧ (ឆ្នាំ២០២០) ស្តីពីសិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី (មាត្រា ២១) CCPR/C/GC/៣៧(ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០) វាក្យខណ្ឌទី ៤៥ https://undocs.org/CCPR/C/GC/37 ។

## ចំណុចគន្លឹះទី២៖ តើក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធសេរីភាពមូលដ្ឋាន ត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវដែរឬទេ ?[43]

ចំណុចគន្លឹះទី២ ពិនិត្យមើលថា តើក្របខ័ណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវក្នុងកម្រិតណាដែរ? ដើម្បីឱ្យបុគ្គលម្នាក់ៗទទួលបានសេរីភាពមូលដ្ឋានរបស់ខ្លួន មិនមែនគ្រាន់តែក្របខ័ណ្ឌច្បាប់ជាតិអនុលោមតាមបទដ្ឋាននិងច្បាប់សិទ្ធិមនុស្សអន្តរជាតិប៉ុណ្ណោះទេ។ ការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ត្រូវតែអនុវត្តស្របតាមលិខិតគតិយុត្ត ដោយសង្គតិភាពនិងមិនមែនតាមទំនើងចិត្ត។

**<u>របកគំហើញសំខាន់ៗ</u>៖** ទិន្នន័យពីចំណុចគន្លឹះទី២ បង្ហាញឱ្យឃើញថា ច្បាប់មួយចំនួនពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន បង្កើតឡើងក្នុងគោលបំណងរារាំងការចូលរួមរបស់សាធារណជន បំបិទសំឡេងរិះគន់ និងបញ្ឈប់មតិជំទាស់។ អង្គការសង្គមស៊ីវិល ជាញឹកញាប់តែងត្រូវបានរាជរដ្ឋាភិបាលកម្ពុជាកំណត់ជាមុខសញ្ញា ដោយសារការរៀបចំវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយឱ្យមានការយល់ដឹងដែលធ្វើឱ្យរាជរដ្ឋាភិបាលមិនយល់ស្រប ឬការធ្វើសកម្មភាពស្របច្បាប់ផ្សេងៗទៀត។ សមាជិកអង្គការសង្គមស៊ីវិលជារឿយៗប្រឈមមុខនឹងការដាក់ទោសព្រហ្មទណ្ឌ។ សមាជិកគណបក្សនយោបាយជំទាស់ ត្រូវបានកំណត់មុខសញ្ញាញឹកញាប់ជាងគេបំផុត។ ការជួបប្រជុំគ្នាជាច្រើន មិនត្រូវបានធានាការពារពីរដ្ឋាភិបាលនោះទេ តែរងការរារាំងតាមរយៈការប្រើប្រាស់កម្លាំងមិនសមស្របទៅវិញ។ ការរឹតត្បិតចំពោះការបញ្ចេញមតិតាមអនឡាញបានកើនឡើង ហើយមានករណីនៃការជ្រៀតជ្រែកជាច្រើនលើសេរីភាពប្រព័ន្ធផ្សព្វផ្សាយត្រូវបានកត់ត្រា។

*តួលេខទី៨៖ ចំនួនហេតុការណ៍ដែលទទួលបានការការពារ ការរឹតត្បិត ឬការរំលោភបំពាន សេរីភាពមូលដ្ឋាននៅឆ្នាំទី៦*




នៅឆ្នាំទី៦ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានកត់ត្រាហេតុការណ៍ចំនួន ៤៥៤ ករណីដែលទាក់ទងនឹងការអនុវត្តសេរីភាពមូលដ្ឋាន។ ៣៥១ ករណី នៃហេតុការណ៍ទាំងនោះបានកត់ត្រាតាមរយៈការឃ្លាំមើលប្រព័ន្ធផ្សព្វផ្សាយ ហើយហេតុការណ៍បន្ថែមចំនួន ១០៣ ករណី ត្រូវបានកត់ត្រាតាមរយៈការរាយការណ៍ពីហេតុការណ៍។ ហេតុការណ៍ចំនួន ១១៣ ករណី បានបង្ហាញពីការការពារសេរីភាព

[43] របកគំហើញនៅក្នុងចំណុចគន្លឹះទី២ គឺផ្អែកលើការរាយការណ៍ពីហេតុការណ៍ ការឃ្លាំមើលតាមប្រព័ន្ធផ្សព្វផ្សាយ ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានធ្វើឡើងក្នុងខែកញ្ញា ឆ្នាំ២០២១ ការស្ទង់មតិជាសាធារណៈដែលបានធ្វើឡើងក្នុងខែវិច្ឆិកាដល់ខែធ្នូ ឆ្នាំ២០២១ និងឧបករណ៍វាយតម្លៃការចុះបញ្ជីសហជីព។ វិធីសាស្ត្រប្រមូលទិន្នន័យទាំងនេះត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី១ ។

មូលដ្ឋាន ខណៈដែល ៩៣ ករណី មានការរឹតត្បិតយ៉ាងតិចមួយ និង ២៤៨ ករណី ចាត់ទុកថាជាការរំលោភលើសេរីភាពមូលដ្ឋានយ៉ាងហោចណាស់មួយ។[44]

*តួលេខទី៩៖ ចំនួននៃការរឹតត្បិត ឬការរំលោភបំពានតាមខែនីមួយៗក្នុងឆ្នាំទី៦*




នៅដើមឆ្នាំទី៦ មានការកើនឡើងចំនួនករណីឆ្លងជំងឺកូវីដ-១៩ នៅកម្ពុជា ដែលបណ្តាលឱ្យមានការបិទខ្ទប់រាជធានីភ្នំពេញ និងបម្រាមធ្វើដំណើរទៅមករាជធានី-ខេត្តនៅអំឡុងខែមេសា ឆ្នាំ២០២១ ដែលបម្រាមបានដកវិញនៅដើមខែឧសភា[45] និងមួយចំនួននៅដំណាច់ខែមេសា។[46] វិធានការទាំងនេះទំនងជានាំឱ្យមានការថយចុះនូវការរឹតត្បិត និងការរំលោភបំពានក្នុងខែមេសា ឆ្នាំ ២០២១។ ការរឹតត្បិត និងការរំលោភបំពាន[47] មានចំនួនខ្ពស់បំផុតនៅខែវិច្ឆិកា ឆ្នាំ២០២១ នៅពេលដែលសកម្មជននយោបាយ និងអ្នកនយោបាយជាច្រើនប្រឈមមុខនឹងវិធានការផ្លូវច្បាប់ ឬការរឹតត្បិតលើសកម្មភាពគណបក្សរបស់ពួកគេ។ គួរកត់សម្គាល់ថា សកម្មជនគណបក្សសង្គ្រោះជាតិ ចំនួន ៤ នាក់ ដែលបានភៀសខ្លួនទៅប្រទេសថៃក្រោយពីការរំលាយគណបក្សសង្គ្រោះជាតិ កាលពីឆ្នាំ២០១៧ ត្រូវបានចាប់ខ្លួន និងនិរទេសមកកម្ពុជាតាមសំណើ ឬក្រោមការសហការជាមួយអាជ្ញាធរកម្ពុជានៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២១។[48] ពួកគេទាំងអស់ត្រូវបានចាប់ដាក់ពន្ធនាគារពីទង្វើ ដែល

---

44 ការរឹតត្បិត និងការរំលោភសិទ្ធិខុសគ្នាត្រង់ថា ការរឹតត្បិតអាចត្រូវបានអនុញ្ញាតតាមផ្លូវច្បាប់ក្នុងកាលៈទេសៈជាក់លាក់មួយចំនួន រីឯការរំលោភបំពានជាបឋមគឺផ្ទុយទៅនឹងបទដ្ឋានច្បាប់អន្តរជាតិ។

45 មុំ គន្ធា "រដ្ឋាភិបាលចេញសេចក្តីណែនាំ ខណៈដែលការបិទខ្ទប់ប្រទេសជិតបញ្ចប់" (ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១) https://www.phnompenhpost.com/national/govt-issues-guidelines-lockdown-nears-end ។

46 "បម្រាមលើការធ្វើដំណើរទៅមករាជធានី-ខេត្តបានដកចេញ លើកលែងតែរាជធានីភ្នំពេញ និងក្រុងតាខ្មៅ" (ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ https://www.phnompenhpost.com/national/inter-provincial-travel-ban-lifted-phnom-penh-and-takmao-not-exempted ។

47 ចំនួនការរឹតត្បិត និងការរំលោភបំពានសរុប គឺខ្ពស់ជាងចំនួនហេតុការណ៍ដែលពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពាន ពីព្រោះដារឿយៗហេតុការណ៍មួយអាចមានការរឹតត្បិតច្រើន។

48 ខាន់ លក្ខិណា "អាជ្ញាធរថៃចាប់ខ្លួនអតីតសកម្មជនបក្សប្រឆាំងម្នាក់ទៀត ប្រគល់ឱ្យអាជ្ញាធរកម្ពុជា" (វីអូឌី, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២១) https://www.vodkhmer.news/2021/11/20/thai-authorities-arrest-former-opposition-activist-hand-him-over-to-cambodian-authorities/; Richard Finney "សកម្មជនគណបក្សប្រឆាំងដែលត្រូវបានឃុំខ្លួននៅប្រទេសថៃ ប្រឈមនឹងការនិរទេស" (អាស៊ីសេរី, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/deport-11232021190849.html; Roseanne Gerin "អាជ្ញាធរថៃចាប់ខ្លួន និរទេសសកម្មជនបក្សប្រឆាំងកម្ពុជាពីរនាក់" (អាស៊ីសេរី, ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/cnrp-activists-deported-11102021171509.html ។

អង្គការសហប្រជាជាតិហៅថា "ការចោទប្រកាន់ពាក់ព័ន្ធនឹងរឿងនយោបាយ"។ [49] នៅពេលពួកគេត្រូវបានបញ្ជូនមកដល់ប្រទេសកម្ពុជា ពួកគេត្រូវបានចោទប្រកាន់ពីបទ "សមគំនិត" ដែលក្នុងនោះបីនាក់ត្រូវបានចោទប្រកាន់ពីបទគាំទ្រចំពោះគម្រោងវិលត្រឡប់មកកម្ពុជារបស់លោក សម រង្ស៊ី ក្នុងឆ្នាំ២០១៩ ដែលបានបរាជ័យ[50] ហើយអ្នកទី៤ ចោទប្រកាន់ ពីបទរិះគន់រដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។[51] កាលពីខែវិច្ឆិកា ឆ្នាំ២០២១ អតីតសកម្មជនគណបក្សសង្គ្រោះជាតិម្នាក់ត្រូវបានសម្លាប់នៅរាជធានីភ្នំពេញ ក្នុងការវាយប្រហារមួយដែលក្រុមគ្រួសារ និងមិត្តភក្តិរបស់គាត់បានរៀបរាប់ថា "ជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ" ។[52]

*តួលេខទី១០៖ ផែនទីភូមិសាស្ត្រនៃហេតុការណ៍ដែលពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភលើសេរីភាពមូលដ្ឋាន*




ហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពានលើសេរីភាពមូលដ្ឋាន ត្រូវបានកត់ត្រានៅគ្រប់រាជធានី-ខេត្តនៃប្រទេសកម្ពុជា។ ភាគច្រើន (១៦៥ ករណី) បានកើតឡើងនៅរាជធានីភ្នំពេញ ដែលជាមធ្យមមាន ១៣,៦ ករណីក្នុងមួយខែ។

---

[49] "បទអត្ថាធិប្បាយរបស់ Rupert Colville អ្នកនាំពាក្យការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ស្តីពីការសម្លាប់សកម្មជនកម្ពុជា និងការបញ្ជូនជនស្វែងរកសិទ្ធិជ្រកកោនចេញពីប្រទេសថៃ" (ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២១) https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=27906&LangID=E ។

[50] ឃួន ណារីម "ក្រុមសង្គមស៊ីវិលរិះគន់ការនិរទេសជនស្វែងរកសិទ្ធិជ្រកកោនរបស់គណបក្សសង្គ្រោះជាតិ" (ខេមបូចា, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១) https://cambojanews.com/civil-society-groups-decry-deportation-of-cnrp-asylum-seekers/ ។

[51] Eugene Whong, "តុលាការកាត់ទោសសកម្មជនកម្ពុជាដែលទើបធ្វើមាតុភូមិនិវត្តន៍ ឱ្យជាប់ពន្ធនាគារ" (អាស៊ីសេរី, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/michheang-11302021184914.html ។

[52] លោក សំ សុពេជ្រ "មិត្តភ័ក្តិ និងក្រុមគ្រួសាររបស់ ស៊ិន ខុន អះអាងថា ឃាតកម្មគឺពាក់ព័ន្ធនឹងរឿងនយោបាយ" (ខេមបូចា, ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១) https://cambojanews.com/sin-khons-friends-and-family-claim-murder-was-politically-motivated/

*តួលេខទី១១៖ ចំនួនការរឹតត្បិត និងការរំលោភសេរីភាពនីមួយៗតាមត្រីមាស*




បន្ទាប់ពីការផ្ទុះឡើងនូវជំងឺកូវីដ-១៩ នៅអំឡុងខែមេសា ឆ្នាំ២០២១ ស្របពេលជាមួយនឹងការថយចុះនូវចំនួនការរឹតត្បិតនិងការរំលោភបំពាននៅក្នុងត្រីមាសទី២ ចំនួននៃការរឹតត្បិត និងការរំលោភលើសេរីភាពមូលដ្ឋាន មានការកើនឡើងនៅត្រីមាសទី៣ និងទី៤ ។

## ២.១. សេរីភាពខាងសមាគម

នៅឆ្នាំទី៦ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រានូវការរឹតត្បិតចំនួន ២០០ ករណី លើសេរីភាពខាងសមាគម ដែលប៉ះពាល់ដល់មនុស្សយ៉ាងតិច ២៨២ នាក់។[53] ១៥៤ នៃការរឹតត្បិតទាំងនេះ (ឬ ៧៧%) គឺមិនត្រូវបានចាត់ចូលជាការរឹតត្បិតដែលស្របតាមលក្ខខណ្ឌអនុញ្ញាតនោះទេ ដែលនេះមានន័យថាបានរំលោភលើសេរីភាពខាងសមាគម។ ការរឹតត្បិតទាំងនេះ មានដូចជាការជ្រៀតជ្រែកក្នុងសកម្មភាពរបស់សមាគម[54] ការឃ្លាំមើលលើសកម្មភាពសមាគមហួសហេតុ[55] ការវាយដំលើរាងកាយមកលើសមាជិកសមាគម[56] និងការប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីរារាំង ឬបន្ទុចបង្អាក់សមាគម និងសមាជិកសមាគម។[57]

### ២.១.១. ការរឹតត្បិតលើសេរីភាពខាងសមាគម ជារឿយៗត្រូវបានប្រើប្រាស់ដើម្បីកំណត់ជាមុខសញ្ញាមកលើអ្នកដែលមានទស្សនៈនយោបាយផ្ទុយ

53 ការរឹតត្បិត ឬការរំលោភបំពានជារឿយៗពាក់ព័ន្ធនឹងបុគ្គលច្រើនលើសពីម្នាក់។

54 ម៉ិច ដារ៉ា និង Danielle Keeton-Olsen "អ្នកឃ្លាំមើលរបស់សមាគមអាដហុកនិយាយថា នាងត្រូវបានគេរារាំងមិនឱ្យចូលស្តាប់សវនាការនៅខេត្តព្រះសីហនុ" (វីអូឌី, ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២១) https://vodenglish.news/adhoc-monitor-says-shes-blocked-from-preah-sihanouk-court-hearings/. ។

55 ការរាយការណ៍ពីហេតុការណ៍ IRAD១៧៤ ។

56 ត្រាន់ តិចសេង "មនុស្សបួននាក់វាយដំសកម្មជនបក្សប្រឆាំងម្នាក់នៅក្បែរផ្សារក្នុងរាជធានីភ្នំពេញ" (វីអូឌី, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០២១) https://vodenglish.news/four-men-assault-opposition-activist-at-phnom-penh-market/. ។

57 ឃី សុវណ្ណី "សកម្មជនបរិស្ថាន ជាប់ចោទពីបទរួមគំនិត និងប្រមាថព្រះមហាក្សត្រ" (ខេមបូចា, ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២១) https://cambojanews.com/environmental-activists-charged-with-plotting-and-insulting-the-king/ ។

មានមនុស្សយ៉ាងតិច ២៨២ នាក់ ត្រូវបានរឹតត្បិតសេរីភាពខាងសមាគមក្នុងឆ្នាំទី៦ ដែលបង្ហាញពីបរិយាកាសដ៏លំបាកក្នុងការអនុវត្តសេរីភាពនេះ។ ក្នុងចំណោមអ្នកទាំងនេះ មានមនុស្សយ៉ាងតិច ១០១ នាក់ (ឬ ៣៥%) គឺជាសកម្មជននយោបាយ ឬអ្នកនយោបាយ។ ក្នុងចំណោមសកម្មជន ឬអ្នកនយោបាយចំនួន ១០១ នាក់នេះ មាន ៩៤ នាក់ ដែលមានទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សជំទាស់ដ៏ធំមួយ ត្រូវបានតុលាការកំពូលរំលាយ កាលពីឆ្នាំ២០១៧។ អ្នកជាប់ពាក់ព័ន្ធគណបក្សនយោបាយផ្សេងទៀត ក៏ត្រូវបានកំណត់ជាមុខសញ្ញាផងដែរ។[58] ការជ្រៀតជ្រែកលើសេរីភាពខាងសមាគមរបស់សកម្មជននយោបាយ មានដូចជាការឃ្លាំមើលច្រើនហួសហេតុ[59] បណ្ដឹងផ្លូវច្បាប់[60] ការបំភិតបំភ័យ[61] និងការវាយប្រហារលើរាងកាយ។[62]




---

គម្រោងបានកត់ត្រាហេតុការណ៍ចំនួនប្រាំបួននៃអំពើហិង្សាលើរាងកាយទៅលើសមាជិកសមាគមក្នុងឆ្នាំទី៦ ដែលក្នុងនោះ ៨ ករណី កើតឡើងចំពោះសមាជិកអតីតគណបក្សសង្គ្រោះជាតិ ដោយជនមិនស្គាល់មុខបានវាយដំតាមដងផ្លូវ។ អាជ្ញាធរបានចាប់ខ្លួនជនសង្ស័យម្នាក់ក្នុងចំណោមការវាយដំទាំងនោះ នោះគឺករណីធ្វើឃាតលោក ស៊ិន ខុន កាលពីខែវិច្ឆិកា ឆ្នាំ២០២១។[63] ការវាយដំផ្សេងទៀតមិនត្រូវបានដោះស្រាយទេ ដែលបង្ហាញពីកង្វះឆន្ទៈពីសំណាក់អាជ្ញាធរក្នុងការស៊ើបអង្កេត និងដោះស្រាយការវាយដំទាំងនោះ។

---

[58] គណបក្សនយោបាយផ្សេងទៀត ដែលសមាជិក ឬសកម្មជនរបស់ខ្លួន បានជួបប្រទះការរឹតត្បិត ឬរំលោភលើសេរីភាពខាងសមាគម រួមមានគណបក្សភ្លើងទៀន គណបក្សបេះដូងជាតិខ្មែរ គណបក្សខ្មែរស្នេហាជាតិ គណបក្សខ្មែរស្រឡាញ់ជាតិ គណបក្សខ្មែរប្រជាធិបតេយ្យ គណបក្សសង្គមប្រជាធិបតេយ្យ គណបក្សវង្សកុងខេមរៈ មហានគរ គណបក្សកំណែទម្រង់កម្ពុជា និងគណបក្សខ្មែរឈ្នះ។

[59] វ៉េដួល ចិត្រា & តេង យ៉ាលីវ៉ូហ្សី "លោកនាយករដ្ឋមន្ត្រី ប្រាប់ពីការលបស្ដាប់គណបក្សសង្គ្រោះជាតិដែលត្រូវបាននិរទេសខ្លួន" (ខេមបូឌៀននីស, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១) https://cambodianess.com/article/pm-tells-of-listening-in-on-exiled-cnrp ។

[60] ឡាយ សាមាន & គីម សារុំ "ការកាត់ទោសលោក សម រង្ស៊ី ឱ្យជាប់ពន្ធនាគារ ២៥ ឆ្នាំ" (ភ្នំពេញប៉ុស្ដិ៍, ថ្ងៃទី១ ខែមីនា ឆ្នាំ ២០២១) https://phnompenhpost.com/national-politics/rainsy-sentenced-25-years ។

[61] កាន់ វិច្ឆិកា "អតីតមន្ត្រីបក្សប្រឆាំង និងក្រុមគ្រួសាររបស់ពួកគេ ប្រឈមមុខនឹងការរឹតត្បិត ការភ័យខ្លាច និងបញ្ហាជីវភាព" (វីអូអេខ្មែរ, ថ្ងៃទី៣ ខែមករា ឆ្នាំ២០២១) https://khmer.voanews.com/a/opposition-loyalists-live-in-fears-of-arrests-violence-and-economic-hardships-amid-relentless-politicalcrackdowns/5756653.html?fbclid=IwAR26JST6lTCUWIBntLcv-LJPPMLyB1P7LkXvAeEtSRg8mp1Sey0nzGA-uPc ។

[62] Joshua Lipes "សកម្មជនដែលត្រូវបានគេវាយប្រហារដោយជនមិនស្គាល់មុខក្នុងការវាយប្រហារចុងក្រោយបំផុតមកលើក្រុមប្រឆាំងរបស់កម្ពុជា" (អាស៊ីសេរី, ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០២១) https://www.rfa.org/english/news/cambodia/attack-02162021163449.html។

[63] សំ សុពេជ្រ & ជា សុខនី "មិត្តភ័ក្តិ និងក្រុមគ្រួសាររបស់ ស៊ិន ខុន អះអាងថា ឃាតកម្មគឺជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ" (ខេមបូចា, ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១) https://cambojanews.com/sin-khons-friends-and-family-claim-murder-was-politically-motivated/។

នៅឆ្នាំទី៦ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រាមនុស្សចំនួន ៦៥ នាក់ត្រូវបានចាប់ខ្លួន ដែលក្នុងនោះ ៣៩ នាក់ ត្រូវបានចោទប្រកាន់ និង ៦៤ នាក់ ត្រូវបានកាត់ទោសពីបទព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់នៅពេលកំពុងអនុវត្តសេរីភាពខាងសមាគម។ ភាគច្រើននៃបុគ្គលទាំងនេះ គឺជាសកម្មជននយោបាយ ឬអ្នកនយោបាយ៖

- ក្នុងចំណោមមនុស្ស ៦៥ នាក់ ដែលត្រូវបានចាប់ខ្លួន មាន ១៨ នាក់ (ឬ ២៨%) គឺជាសកម្មជននយោបាយ ឬជាអ្នកនយោបាយ។
- ក្នុងចំណោមមនុស្ស ៣៩ នាក់ ដែលត្រូវបានចោទប្រកាន់ មាន ១៦ នាក់ (ឬ ៤១%) គឺជាសកម្មជននយោបាយ ឬអ្នកនយោបាយ។
- ក្នុងចំណោមមនុស្ស ៦៤ នាក់ ដែលត្រូវបានកាត់ទោស មាន ៥២ នាក់ (ឬ ៨១%) គឺជាសកម្មជននយោបាយ ឬអ្នកនយោបាយ។




ការកំណត់មុខសញ្ញាលើសកម្មជននយោបាយនេះ អាចបង្ហាញពីចេតនារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបន្ទុចបង្អាក់ និងរារាំងទៅលើអ្នកដែលមានទស្សនៈផ្ទុយមុនពេលបោះឆ្នោតនៅឆ្នាំ២០២២ និងឆ្នាំ២០២៣ ខាងមុខ។

***ឧទាហរណ៍៖*** *នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ តុលាការខេត្តត្បូងឃ្មុំបានកាត់ទោសអតីតសមាជិកគណបក្សសង្គ្រោះជាតិចំនួន ១២ នាក់ ពីបទញុះញង់ (មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ)។ អ្នកទាំងអស់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារចំនួនមួយឆ្នាំ និងពិន័យជាប្រាក់ពីពីរ ទៅបួនលានរៀល។ ការផ្តន្ទាទោសទាំងនេះកើតចេញពីការចូលរួមប្រមូលផ្តុំនៅខាងក្រៅស្ថានទូតចិននៅក្នុងរាជធានីភ្នំពេញក្នុងទិវាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសខែតុលា ឆ្នាំ២០២០។ ក្នុងចំណោមពួកគេ មាន៦នាក់ត្រូវបានឃុំខ្លួននៅពេលសវនាការ ខណៈដែលមនុស្ស៦នាក់ទៀតត្រូវបានកាត់ទោសកំបាំងមុខបន្ទាប់ពីបានរត់គេចខ្លួនទៅក្រៅប្រទេស។*[64]

[64] ម៉ិច ដារ៉ា "គ្រួសារមន្ត្រីគណបក្សសង្គ្រោះជាតិដែលត្រូវបានផ្តន្ទាទោស ថាពួកគេនឹងពុះពារបង់ប្រាក់ពិន័យរបស់តុលាការ" (វីអូឌី, ថ្ងៃទី ២ ខែកក្កដា ឆ្នាំ២០២១) https://vodenglish.news/families-of-convicted-cnrp-officials-say-they-will-struggle-to-pay-court-fines/ ។

### ២.១.២. សហជីពប្រឈមមុខនឹងការរឹតត្បិតដោយសារភាគីទីបី

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រានូវការរឹតត្បិតជាច្រើន ដែលប៉ះពាល់ដល់សហជីពក្នុងឆ្នាំទី៦។ ឆ្នាំទី៦ បានឃើញមានការកើនឡើងនូវចំនួនថ្នាក់ដឹកនាំសហជីពដែលបានរាយការណ៍ពីការជ្រៀតជ្រែកក្នុងស្ថាប័ន ឬសកម្មភាពរបស់ខ្លួនពីសំណាក់ភាគីទីបី (សូមមើលតួលេខទី ១២) ។ ថ្នាក់ដឹកនាំសហជីពដែលបានរាយការណ៍ពីការជ្រៀតជ្រែកបែបនេះនៅឆ្នាំទី៦ បានបង្ហាញថា ករណីភាគច្រើនកើតឡើងដោយសារសហជីពផ្សេងទៀត(សូមមើលតួលេខទី១៣) ដែលបង្ហាញពីការប្រជែងគ្នាក្នុងចំណោមសហជីពប្រហែលជាដោយសារតែផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើរូបភាពសហជីពនៅកម្ពុជា។[65]

*តួលេខទី១២៖ ចំនួនភាគរយថ្នាក់ដឹកនាំសហជីពដែលបានរាយការណ៍ថាស្ថាប័ន ឬសកម្មភាពរបស់ពួកគេត្រូវបានជ្រៀតជ្រែកដោយភាគីទីបី*




*តួលេខទី១៣៖ ប្រភពនៃការជ្រៀតជ្រែកដោយភាគីទីបីនៅក្នុងសហជីព ឬសកម្មភាពរបស់ពួកគេក្នុងឆ្នាំទី៦*




គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រាហេតុការណ៍ចំនួន ១០ ករណី ដែលនិយោជកបានធ្វើឱ្យសមាជិកសហជីព ថ្នាក់ដឹកនាំសហជីព និងសកម្មជន ប្រឈមមុខនឹងផ្លូវច្បាប់[66] ឬរងការគំរាមកំហែង និងការ

[65] ការធ្វើទុក្ខបុកម្នេញសហជីព សំដៅដល់សកម្មភាពទាំងឡាយណារបស់និយោជកដើម្បីបន្ថយឥទ្ធិពលសហជីព ឬដើម្បីរារាំងកម្មករនិយោជិតពីការអនុវត្តសិទ្ធិ សកម្មភាពនេះបានកើនឡើងក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាដែលមានសហជីពជាច្រើនអះអាងថាត្រូវបានព្យួរការងារ ដោយនិយោជកបានកំណត់មុខសញ្ញាទៅលើខ្លួនដោយសារតែជាសមាជិកសហជីព ក្រោមហេតុផលការរីករាលដាលជំងឺកូវីដ-១៩។ សូមមើលឧទាហរណ៍៖ ឡាយ សាមាន "កម្មករចោទថាមានការធ្វើទុក្ខបុកម្នេញសហជីពដោយសារហេតុផលជំងឺកូវីដ-១៩" https://cambojanews.com/garment-factories-accused-of-union-busting-under-cover-of-covid-19/ (ខេមបូចា, ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០)ឡាយ សុភាវត្តី, "សហជីពចោទក្រុមហ៊ុនព្រលានយន្តហោះ Cambodia Airport អំពីការបណ្តេញចេញមិនស្មើរភាព និងការបំបែកបំបាក់សហជីព" (ខេមបូឌៀននីស, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១) https://cambodianess.com/article/unions-sue-cambodia-airports-over-unfair-dismissals-and-union-busting ។

[66] យុត សុគន្ធ "មេដឹកនាំសហជីពស្វែងរកអន្តរាគមន៍ពីក្រសួងយុត្តិធម៌ បន្ទាប់ពីមានបណ្តឹងពីក្រុមហ៊ុនមួយ" (វីអូឌី, ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០២១) https://www.vodkhmer.news/2021/02/05/union-leader-intervention-ministry-justice-after-lawsuit-company/

បំភិតបំភ័យ[67] ការរើសអើង[68] ឬត្រូវបានបណ្តេញចេញពីការងារ[69] និងរារាំងក្នុងការចុះបញ្ជីសហជីព។[70] ទោះបីជាគម្រោងមិនអាចផ្ទៀងផ្ទាត់ថា តើមានមនុស្សប៉ុន្មាននាក់ត្រូវបានកំណត់ជាមុខសញ្ញាដោយសារតែសកម្មភាពសហជីពក៏ដោយ ក៏សមាជិកសហជីពបានរាយការណ៍ថា សកម្មភាពរបស់និយោជកហាក់ដូចជាការសងសឹកចំពោះសកម្មភាពសហជីព។[71] ហេតុការណ៍ទាំងនេះរំលោភលើសិទ្ធិសេរីភាពខាងសមាគម ដែលពាក់ព័ន្ធសិទ្ធិរបស់កម្មករនិយោជិតក្នុងការរៀបចំ និងការចរចាអនុសញ្ញារួម។

***ឧទាហរណ៍៖*** *នៅថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២១ បន្ទាប់ពីបានជូនដំណឹងដល់ក្រុមហ៊ុន Trippos International Co. Ltd. អំពីដំណើរការចុះបញ្ជីសហជីពនៅក្រុមហ៊ុន និយោជិតចំនួន ៣ នាក់ដែលធ្វើការចុះបញ្ជីសហជីព ត្រូវបានកោះហៅឱ្យមកជួប។ ពួកគេត្រូវបានគេគំរាមបណ្តេញចេញពីការងារ ប្រសិនបើពួកគេបន្តដំណើរការចុះបញ្ជីសហជីព។ ក្រុមហ៊ុនក៏បានជួបជាមួយកម្មករនិយោជិត ៦ នាក់ផ្សេងទៀតដែលបានពិចារណាចូលរួមជាមួយសហជីព ហើយបានគំរាមបណ្តេញពួកគេចេញពីការងារ ប្រសិនបើពួកគេមិនបោះបង់គម្រោងចូលរួមជាមួយសហជីពនោះទេ។ នៅទីបំផុត មនុស្សទាំង ៩ នាក់បានបន្តការងាររបស់ពួកគេ។ សហជីពត្រូវបានចុះបញ្ជី ហើយបុគ្គលទាំង ៩ នាក់នោះបានចូលរួមក្នុងសកម្មភាពសហជីព។*[72]

### ២.១.៣. ដំណើរការចុះបញ្ជីសហជីពអូសបន្លាយពេលយូរ និងមានបន្ទុកច្រើនលើសលុប

---

[67] ការរាយការណ៍ពីហេតុការណ៍ IRCC ៣៤៧ ។

[68] ឡេង ម៉ាលី "សហជីពថា ថៅកែរោងចក្ររើសអើងពួកគេក្រោយពីធ្វើកូដកម្ម" (អាស៊ីសេរី, ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១) https://www.rfa.org/khmer/news/social-economy/employer-of-master-blacksmith-factory-in-svay-rieng-accused-of-union-discrimination-02052021074840.html ។

[69] ត្រឹង តិចសេង និង ហ៊ន ថូរ៉ាន "មេដឹកនាំសហជីពកំពូលរបស់ណាហ្គាវើល ទទួលបានការជូនដំណឹងពីការបណ្តេញចេញពីការងារ (វីអូឌី, ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១) https://vodenglish.news/nagaworlds-top-union-leaders-receive-dismissal-notices/; ឡាយ សុភាវត្តី & កួង វន្ថា «ណាហ្គាវើលដ៍ រំសាយបុគ្គលិកអំឡុងពេលឆ្លងរីករាលដាលជំងឺកូវីដ ១៩ គឺជាទង្វើអមនុស្សធម៌ នេះបើតាមសម្តីរបស់មេដឹកនាំសហជីព និងអង្គការមិនមែនរដ្ឋាភិបាល"។(ខេមបូឌៀននីស, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១) https://cambodianess.com/article/nagaworld-laying-off-employees-during-the-covid-១៩-pandemic-is-inhuman-union-leaders-and-ngos-say ។

[70] ការរាយការណ៍ពីហេតុការណ៍ IRSC០៨៩ ។

[71] សូមមើលឧទាហរណ៍៖ ឡេង ម៉ាលី "សហជីពនិយាយថា ថៅកែរោងចក្ររើសអើងពួកគេបន្ទាប់ពីធ្វើកូដកម្ម" (អាស៊ីសេរី, ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១) https://www.rfa.org/khmer/news/social-economy/employer-of-master-blacksmith-factory-in-svay-rieng-accused-of-union-discrimination-02052021074840.html; ត្រឹង តិចសេង និង ហ៊ន ថូរ៉ាន "ថ្នាក់ដឹកនាំសហជីពកំពូលរបស់ណាហ្គាវើលទទួលបានការជូនដំណឹងពីការបណ្តេញចេញពីការងារ (វីអូឌី, ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១) https://vodenglish.news/nagaworlds-top-union-leaders-receive-dismissal-notices/; Incident Report IRSC082; Incident Report IRSC089។

[72] ការរាយការណ៍ពីហេតុការណ៍ IRSC០៨៥ ។

នៅឆ្នាំទី៦ គម្រោងបានចងក្រងឯកសារអំពីបទពិសោធន៍របស់សហជីពចំនួន ៣ ដែលព្យាយាមចុះបញ្ជីសហជីពរបស់ខ្លួនស្របតាមច្បាប់ស្តីពីសហជីព។[73] ពាក្យស្នើសុំចុះបញ្ជីសហជីពចំនួន ២ ក្នុងចំណោមពាក្យស្នើសុំចំនួន៣ បានជួបប្រទះការពន្យារពេល ហើយសហជីពទាំង ៣ ដែលបានស្ទង់មតិ បានឆ្លើយថាទម្រង់ "ពាក្យស្នើសុំចុះបញ្ជីសហជីពមូលដ្ឋាន" គឺពិបាកក្នុងការបំពេញ។ ការរកឃើញទាំងនេះបង្ហាញថា ការចុះបញ្ជីសហជីព គឺជាដំណើរការមួយដែលអូសបន្លាយពេលយូរ និងមានបន្ទុកច្រើនលើសលុប ដែលរារាំងដល់ការអនុវត្តសេរីភាពខាងសមាគមរបស់ពួកគេ ដោយសារការចុះបញ្ជីសហជីពគឺជាបុរេលក្ខខណ្ឌដើម្បីអាចអនុវត្តសកម្មភាពសហជីពដោយស្របច្បាប់បាន។[74]

## ២.១.៤. ការឃ្លាំមើលសមាគមជាញឹកញាប់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា បង្ហាញពីការមិនទុកចិត្តលើសង្គមស៊ីវិល

*តួលេខទី១៤៖ ចំនួនភាគរយនៃហេតុការណ៍ពាក់ព័ន្ធនឹងសេរីភាពខាងសមាគម ដែលត្រូវបានរាយការណ៍ថាស្ថិតក្រោមការតាមដាន ឬឃ្លាំមើលហួសហេតុពីរាជរដ្ឋាភិបាលកម្ពុជា*




ការតាមដាន និងឃ្លាំមើលពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាលើសកម្មភាពរបស់អង្គការសង្គមស៊ីវិលស្ថិតក្នុងអត្រាមួយដ៏ខ្ពស់ដែលរឹតត្បិត ឬរំលោភលើសេរីភាពខាងសមាគម។[75] នេះបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានមន្ទិលសង្ស័យមកលើសមាគម។

***ឧទាហរណ៍៖*** *នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចូលទៅស្តាប់ការប្រជុំរបស់អតីតគណបក្សសង្គ្រោះជាតិ ហើយបានព្រមានអ្នកចូលរួមថា លោកបានកំពុងឃ្លាំមើលពួកគេ។[76] កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលស្គាល់ថា លោកបានស្តាប់ការប្រជុំជាច្រើនដែលធ្វើឡើងដោយសមាជិកគណបក្សសង្គ្រោះជាតិ ហើយថាលោកមានវីដេអូឃ្លីបប្រមាណ ៥០ នៃកិច្ចប្រជុំរបស់ក្រុមប្រឆាំង។[77]*

---

[73] ការកត់ត្រាចំនួនដ៏ទាបរបស់សហជីពដែលបានព្យាយាមចុះបញ្ជីក្នុងឆ្នាំទី៦ អាចដោយសារតែការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ដែលបានធ្វើឱ្យកន្លែងធ្វើការជាច្រើនត្រូវបានផ្អាកដំណើរការនៅទូទាំងប្រទេសកម្ពុជា។

[74] មាត្រា ១៣ និង ១៤ នៃច្បាប់ស្តីពីសហជីព។

[75] មិនមានទិន្នន័យនេះទេសម្រាប់ឆ្នាំទី១ និងឆ្នាំទី២។

[76] Paul Eckert, "នាយករដ្ឋមន្ត្រីកម្ពុជានិយាយថា លោកបានបំបែកការសន្ទនាតាមហ្ស៊ូមរបស់បក្សប្រឆាំងដើម្បីព្រមានចំពោះពួកបះបោរ" (អាស៊ីសេរី, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/hunsen-zoom-09162021191746.html ។

[77] រំដួល ចិត្រា & តេង យ៉ាលីរ៉ូហ្សី "លោកនាយករដ្ឋមន្ត្រី ប្រាប់ពីការលបស្តាប់គណបក្សសង្គ្រោះជាតិដែលត្រូវបាននិរទេសខ្លួន" (ខេមបូឌៀននីស, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១) https://cambodianess.com/article/pm-tells-of-listening-in-on-exiled-cnrp ។

ផ្អែកតាមរបកគំហើញទាំងនេះ និងដោយការពិចារណាអំពីការព្រួយបារម្ភជុំវិញការបង្កើតច្បាប់ដែលទំនងជាជួយសម្រួលដល់ការឃ្លាំមើលទ្រង់ទ្រាយធំ (សូមមើលចំណុចគន្លឹះទី១) មិនគួរឱ្យភ្ញាក់ផ្អើលទេ ដែលថាស្ទើរតែ ២ នាក់ ក្នុងចំណោមថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ៣ នាក់ បានកត់សម្គាល់ក្នុងឆ្នាំទី៦ ថាស្ថាប័នរបស់ពួកគេបានបង្កើនសន្តិសុខ ឬទប់ស្កាត់ការឃ្លាំមើលពីសំណាក់រដ្ឋាភិបាល។

*តួលេខទី១៥៖ ភាគរយថ្នាក់ដឹកនាំ អង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាស្ថាប័នរបស់ពួកគេបានធ្វើសកម្មភាពកាលពីឆ្នាំមុនដើម្បីបង្កើនសន្តិសុខ ឬការពារការឃ្លាំមើលពីរដ្ឋាភិបាល*




## ២.២. សេរីភាពខាងការបញ្ចេញមតិ

នៅឆ្នាំទី៦ គម្រោងបានកត់ត្រានូវការរឹតត្បិតចំនួន ១៤០ ករណី លើសេរីភាពខាងការបញ្ចេញមតិ ដែលក្នុងនោះ ៩៦ ករណី (៦៩%) ពាក់ព័ន្ធនឹងការរំលោភបំពាន។ ការរឹតត្បិតទាំងនេះ មានដូចជាការគំរាមកំហែងប្រឆាំងនឹងអ្នកសារព័ត៌មាន[78] ជនដែលប្រឈមមុខនឹងទោសព្រហ្មទណ្ឌដោយការរិះគន់លើការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការឆ្លងរីករាលដាលជាសកលនៃជំងឺកូវីដ-១៩[79] និងបដាដែលត្រូវបានអាជ្ញាធរចាប់យកក្នុងអំឡុងពេលតវ៉ា។[80]

### *២.២.១. អ្នកសារព័ត៌មានទទួលរងការបៀតបៀនជាញឹកញាប់ នៅពេលរាយការណ៍អំពីបញ្ហាដែលគេចាត់ទុកថាមានលក្ខណៈ"រសើប"*




ពាក្យបណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈ[81] ត្រូវបានប្រើប្រាស់ចំនួន ២៨ លើក ក្នុងឆ្នាំទី៦ ប្រឆាំងនឹងបុគ្គលចំនួន ៤១ នាក់ ដើម្បីសងសឹកចំពោះការអនុវត្តសេរីភាពខាងការបញ្ចេញមតិ។ ក្នុងចំណោមនោះ មានពាក្យបណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈចំនួន ៦ (ឬ ២១%) បានតម្រង់មុខសញ្ញាលើអ្នកសារព័ត៌មានចំនួន ៨ នាក់។

[78] យុត សុគន្ធ "អ្នកសារព័ត៌មានថា គាត់រងការគំរាមកំហែងបន្ទាប់ពីរាយការណ៍អំពីករណីឈូសឆាយដី" (វីអូឌី, ថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២១) https://vodenglish.news/journalist-says-he-was-threatened-after-covering-land-clearing-case ។

[79] ប៊ុត ច័ន្ទស្មើគង្គា "ជាងកាត់កញ្ចក់ត្រូវបានចាប់ខ្លួនពីបទប្រមាថពាក់ព័ន្ធនឹងជំងឺកូវីដ-១៩" (ខ្មែរថាមស៍, ថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០២១) https://www.khmertimeskh.com/50838104/glass-cutter-arrested-for-insulting-c-19-initiatives ។

[80] Eugene Whong "ខួបលើកទី ៣០ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស មានចន្លោះប្រហោងសម្រាប់ប្រជាជនកម្ពុជាជាច្រើន" (អាស៊ីសេរី, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/paris10222021221126.html ។

[81] បណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈគឺជាបណ្តឹងដែលប្រើដើម្បីបន្តុចបង្អាក់ បំភិតបំភ័យ តតាំង រំខាន ឬបង្កើនចំណាយផ្នែកហិរញ្ញវត្ថុរបស់ភាគីចុងចម្លើយ បំបិទមាត់ការជំទាស់ ការរិះគន់ ឬការប្រឆាំងរបស់ពួកគេ។

នៅឆ្នាំទី៦ អ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាដីធ្លី រងការបង្ក្រាបយ៉ាងខ្លាំងលើសេរីភាពសារព័ត៌មាន៖ ក្នុងចំណោមហេតុការណ៍ចំនួន ៣៣ ករណី ដែលអ្នកសារព័ត៌មានត្រូវបានកំណត់មុខសញ្ញាក្នុងឆ្នាំទី៦ មាន ៤២% ទាក់ទងនឹងការរាយការណ៍អំពីបញ្ហាដីធ្លី។ អ្នកសារព័ត៌មានប្រឈមមុខនឹងការរឹតត្បិតជាច្រើន ដូចជាការគំរាមកំហែង[82] ការវាយដំលើរូបរាងកាយ [83] ការឃាត់[84] ការបំភិតបំភ័យ [85] និងបណ្ដឹងផ្លូវច្បាប់[86] ចំពោះការរាយការណ៍អំពីបញ្ហាដីធ្លី។

***ឧទាហរណ៍នៃការជ្រៀតជ្រែកដែលអ្នកសារព័ត៌មានរាយការណ៍អំពីបញ្ហាដីធ្លីបានប្រឈមមុខក្នុងឆ្នាំទី៦៖***

- *នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ អ្នកសារព័ត៌មានពីរនាក់ត្រូវបានឃាត់ដោយសារមានបំណងផ្សព្វផ្សាយជម្លោះដីធ្លីនៅបឹងទំពុន។ លោក អាន វិចិត្រ អ្នកសារព័ត៌មានខេមបូចា បានអះអាងថា នគរបាលបានរឹបអូសយកទូរស័ព្ទ និងបណ្ណសារព័ត៌មានរបស់គាត់ ហើយបានគំរាមចាប់ខ្លួនគាត់ ប្រសិនបើគាត់មិនលុបរូបភាពទាំងអស់ដែលគាត់បានថតនោះភ្លាមៗទេ។ លោក លាស់ លីបលីប អ្នកសារព័ត៌មានវីអូអេខ្មែរ បាននិយាយថា លោកក៏ត្រូវបានគេបង្ខំឱ្យលុបរូបភាពដែលលោកបានថតពីជម្លោះនោះដែរ។ អាជ្ញាធរក៏បានឆែកឆេរម៉ូតូរបស់គាត់ ហើយប្រាប់គាត់ឱ្យលុបរូបភាពទាំងអស់ចេញពីទូរស័ព្ទទីពីរដែលគេរកឃើញ។ បន្ទាប់មក លោក លាស់ លីបលីប ត្រូវបានគំរាមកំហែងថានឹងចាត់វិធានការផ្លូវច្បាប់ ប្រសិនបើគាត់មិនចាកចេញពីទីនោះភ្លាមៗ។ ក្រោយការប្រឈមមុខដាក់គ្នា អ្នកសារព័ត៌មានទាំងពីរត្រូវបានបញ្ជាឱ្យចេញពីកន្លែងកើតហេតុ។[87]*
- *លោក ឡោះ សេង អ្នកបោះពុម្ពផ្សាយព័ត៌មាន Los Seng និងជាម្ចាស់គេហទំព័រព័ត៌មាន LSN TV ២៤ Online បាននិយាយកាលពីខែកក្កដា ឆ្នាំ២០២១ ថា គាត់បានកំពុងរងសម្ពាធពីសំណាក់អាជ្ញាធរ ដោយសារតែការផ្សព្វផ្សាយពីវិវាទដីធ្លីដែលកំពុងកើតមានទាក់ទងនឹងការអតិវឌ្ឍអាកាស*

[82] យុត សុគន្ធ "អ្នកសារព័ត៌មានថា គាត់រងការគំរាមគំហែងបន្ទាប់ពីរាយការណ៍អំពីករណីឈូសឆាយដី" (វីអូឌី, ថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២១) https://vodenglish.news/journalist-says-he-was-threatened-after-covering-land-clearing-case/ ។

[83] វណ្ណ វិចារ "អ្នកសារព័ត៌មានត្រូវគេវាយដំពេលសម្រាន្តនៅខាងក្រៅវត្តអារាម" (វីអូឌី, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១) https://vodenglish.news/journalist-beaten-as-he-slept-outside-temple/។

[84] ម៉ិច ដារ៉ា "ក្រុមអ្នកតវ៉ារឿងដីធ្លីបិទផ្លូវខណៈដែលឧបករណ៍អ្នកសារព័ត៌មានត្រូវបានរឹបអូស" (វីអូឌី, ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១) https://vodenglish.news/land-protesters-block-road-as-reporters-equipment-confiscated/។

[85] យួន ណារីម "អ្នកសារព័ត៌មានពីរនាក់រាយការណ៍ពីការឃាត់ពីសំណាក់អាជ្ញាធរអំឡុងពេលរាយការណ៍អំពីវិវាទដីធ្លីដាច់ដោយឡែក" (ខេមបូចា, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១) https://cambojanews.com/two-journalists-report-harassment-by-authorities-during-coverage-of-separate-land-disputes/ ។

[86] យួន ណារីម "អ្នកបោះពុម្ពផ្សាយព័ត៌មានឌីជីថលត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពីវិវាទនៅខេត្តកោះកុង" (ខេមបូចា, ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១) https://cambojanews.com/digital-news-publisher-convicted-sentenced-to-prison-for-koh-kong-dispute/ ។

[87] ស៊ន សារ័ត្ន "អ្នកសារព័ត៌មានត្រូវបានឃាត់ពេលកំពុងបំពេញការងារ ខណៈដែលអាជ្ញាធរបោសសម្អាតសម្រាប់ការអតិវឌ្ឍនៅបឹងទំពុន" (ខេមបូចា, ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១) https://cambojanews.com/journalists-harassed-on-the-job-as-authorities-clear-homes-for-development-at-boeng-tompun/ ។

*យានដ្ឋានអន្តរជាតិភ្នំពេញថ្មីនៅខេត្តកណ្ដាល។ អាជ្ញាធរបានព្រមានគាត់ឱ្យបញ្ឈប់ការរាយការណ៍ព័ត៌មាននោះ។*[88]

អ្នកសារព័ត៌មានដែលបានរាយការណ៍ ឬមានបំណងរាយការណ៍អំពីជំងឺកូវីដ-១៩ ក៏ត្រូវបានកំណត់ជាមុខសញ្ញាក្នុងឆ្នាំទី៦ នេះផងដែរដូចជា៖ ២៧% នៃ ហេតុការណ៍ពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន គឺទាក់ទងនឹងការរាយការណ៍អំពីបញ្ហាទាក់ទងនឹងជំងឺកូវីដ-១៩។ មានការគំរាមដាក់ពាក្យបណ្ដឹងផ្លូវច្បាប់លើអ្នកសារព័ត៌មានដែលត្រូវបានហាមឃាត់ការរាយការណ៍ពីតំបន់ក្រហម លុះត្រាតែមានការអញ្ជើញពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា[89] ដែលនាំឱ្យមានការអះអាងពីការរើសអើងដោយលម្អៀងទៅខាងបណ្ដាញផ្សព្វផ្សាយដែលគាំទ្ររដ្ឋាភិបាល។[90] អាជ្ញាធរក៏បានព្រមានអ្នកសារព័ត៌មានផងដែរ មិនឱ្យផ្សាយបន្តផ្ទាល់ពីមណ្ឌលព្យាបាល និងមន្ទីរពេទ្យ ហើយមិនត្រូវធ្វើការសន្និដ្ឋានដោយគ្មានភស្តុតាងច្បាស់លាស់ ដែលអាចនាំឱ្យមានការភ័ន្តច្រឡំជាសាធារណៈ ចលាចលក្នុងសង្គម និងគ្រោះថ្នាក់ដល់សុខភាពសាធារណៈបន្ថែមទៀត។[91] គួរកត់សម្គាល់ថា អាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួន៦ ត្រូវបានដកហូតដោយសារតែពួកគេបានធ្វើការផ្សព្វផ្សាយអំពីបញ្ហាជំងឺកូវីដ-១៩៖

- អាជ្ញាប័ណ្ណរបស់សារព័ត៌មានសានព្រំ (San Prum News) និងសមាគមអ្នកសារព័ត៌មានតាមបណ្ដាញហ្វេសប៊ុកកម្ពុជា ត្រូវបានដកហូត បន្ទាប់ពីលោក សាន ព្រំ ដែលជាអ្នកគ្រប់គ្រងទំព័រហ្វេសប៊ុកទាំងនេះបានបង្ហោះរូបភាពនៅលើបណ្ដាញហ្វេសប៊ុកពីអ្វីដែលលោកបានយល់ខុស គឺការរុំខ្ចប់សាកសពអ្នកជំងឺកូវីដ-១៩ ដែលបានស្លាប់។ អ្នកនាំពាក្យក្រសួងព័ត៌មានបាននិយាយថាលោកបានបំភ្លៃព័ត៌មានអំពីការស្លាប់របស់អ្នកជំងឺកូវីដ-១៩ ដែលធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងការខិតខំប្រឹងប្រែងរបស់អាជ្ញាធរ។[92]

---

88 ម៉ិច ដារ៉ា "អ្នកសារព័ត៌មានដែលរាយការណ៍អំពីវិវាទដីធ្លីនៅអាកាសយានដ្ឋានថ្មីប្រឈមនឹងសម្ពាធ" (វីអូឌី, ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០២១) https://vodenglish.news/journalist-reporting-on-new-airports-land-dispute-faces-pressure/ ។

89 ការបិទខ្ទប់តំបន់ត្រូវបានប្រកាសនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។ "តំបន់ក្រហម" ត្រូវបានប្រកាសនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ដើម្បីកំណត់តំបន់ដែលមានចំនួនករណីឆ្លងជំងឺកូវីដ-១៩ ច្រើន។ ប្រជាជនទាំងអស់នៅក្នុងតំបន់ក្រហម ត្រូវបានហាមឃាត់មិនឱ្យចាកចេញពីផ្ទះរបស់ពួកគេ លើកលែងតែទៅធ្វើតេស្ត ឬទទួលវ៉ាក់សាំងលើកទី២ ឬក្នុងករណីមានអាសន្នផ្នែកវេជ្ជសាស្ត្រ។

90 ម៉ិច ដារ៉ា "ការរាយការណ៍ព័ត៌មានតំបន់ក្រហម ធ្វើឡើងដោយការអញ្ជើញតែប៉ុណ្ណោះ៖ ក្រសួងព័ត៌មាន" (វីអូឌី, ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១) https://vodenglish.news/red-zone-news-reporting-is-invite-only-information-ministry/

91 សំអឿន និស្ស័យបុណ្យ និង អ៊ុច សូនី "ការព្រមានអំពីចំណាត់ការផ្លូវច្បាប់ចំពោះការផ្សាយពីតំបន់ក្រហម ដោយតាមពីក្រោយរថយន្តសង្គ្រោះបន្ទាន់" (វីអូឌី, ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១) https://vodenglish.news/warning-of-legal-action-for-broadcasts-from-red-zones-following-ambulances/។ ការគំរាមបណ្ដឹងផ្លូវច្បាប់ពីការផ្សាយបន្តផ្ទាល់ពីមណ្ឌលព្យាបាល និងមន្ទីរពេទ្យហាក់ដូចជាមានលក្ខណៈហួសហេតុ វិធានការរឹតត្បិតតិចតួច អាចត្រូវបានអនុវត្តដើម្បីបង្ការការឆ្លងរីករាលដាលនៃមេរោគជំងឺកូវីដ-១៩ ខណៈដែលកំពុងលើកកម្ពស់សេរីភាពសារព័ត៌មាន។ ដូច្នេះហេតុការណ៍នេះត្រូវបានកត់ត្រាថាជាការរំលោភលើសេរីភាពខាងការបញ្ចេញមតិ។

92 ឃី សុវុឌ្ឍី "ដកហូតតំណែងនិងអាជ្ញាប័ណ្ណសារព័ត៌មានទីប្រឹក្សាក្រសួងព័ត៌មាន" (ខេមបូចា, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១) https://cambojanews.com/information-ministry-advisor-stripped-of-position-news-outlet-license/ ។

- បណ្តាញទូរទស្សន៍ K០១ TV ផ្សាយព័ត៌មានអនឡាញ ត្រូវបានបិទ ហើយអាជ្ញាប័ណ្ណរបស់ខ្លួន ត្រូវបានដកហូតដោយសារតែផ្សព្វផ្សាយ "ព័ត៌មានញុះញង់ក្នុងចេតនាមិនល្អ ដើម្បីបង្កឱ្យមានភាពចលាចលក្នុងសង្គម"។ ការដកហូតនេះធ្វើឡើងបន្ទាប់ពីម្ចាស់គេហទំព័រនេះ បានបង្ហោះវីដេអូជាច្រើន ដែលចាត់ទុកថា "ជាការបង្កហេតុ" លើការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩របស់កម្ពុជា។[93]
- ប្រព័ន្ធផ្សព្វផ្សាយចំនួនបីគឺ Angkor Today, Youth Techo និង Stoeng Chral Post ត្រូវបានដកហូតអាជ្ញាប័ណ្ណរបស់ខ្លួន ដោយសារតែផ្សព្វផ្សាយ "ព័ត៌មានមិនពិត" អំពីជំងឺកូវីដ-១៩។[94]

### ២.២.២. ការនិយាយតាមអនឡាញបន្តរងការរឹតត្បិត

*តួលេខទី១៦៖ ចំនួនភាគរយនៃហេតុការណ៍ដែលពាក់ព័ន្ធនឹងការរឹតត្បិតដោយរាជរដ្ឋាភិបាលលើសេរីភាពខាងការបញ្ចេញមតិតាមអនឡាញ*




គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានរកឃើញថា ហេតុការណ៍រឹតត្បិតពាក់ព័ន្ធនឹងការបញ្ចេញមតិតាមអនឡាញពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាមានការកើនឡើងជាបន្តបន្ទាប់ពី ៣៣% ក្នុងឆ្នាំទី៣ ដល់ ៧៧% ក្នុងឆ្នាំទី៦ ។[95] យោងតាមតួលេខទាំងនេះបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាកាន់តែមានការមិនអត់ឱនចំពោះការនិយាយរិះគន់តាមអ៊ីនធឺណិត។

---

តួលេខខ្ពស់នៃហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិតលើការបញ្ចេញមតិតាមអនឡាញពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក៏អាចបណ្តាលមកពីការពង្រីកសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការតាមដានការបញ្ចេញមតិតាមអនឡាញផងដែរ។ នៅអំឡុងខែកុម្ភៈ ឆ្នាំ២០២១ ក្រសួងព័ត៌មានបានប្រកាសថា បន្ថែមពីលើបណ្តាញហ្វេសប៊ុក ក្រសួងនឹងចាប់ផ្តើមត្រួតពិនិត្យបណ្តាញសង្គម TikTok ព្រមទាំងតាមមធ្យោបាយផ្សេងៗដូចជា WhatsApp, Messenger និង Telegram ។[96] ជាលទ្ធផលនៃការពង្រីកវិសាលភាពនៃការត្រួតពិនិត្យតាមដាននេះ គម្រោងបានកត់ត្រានូវហេតុការណ៍ចំនួន ៤ ដែលរាជរដ្ឋាភិបាលកម្ពុជាបានរឹតត្បិតលើការបញ្ចេញ

---

[93] "ក្រសួងព័ត៌មាន សម្រេចលុបអាជ្ញាប័ណ្ណគេហទំព័រ K01 ក្រោយផ្សព្វផ្សាយព័ត៌មានញុះញង់ " (ហ្រ្វេសញូវស៍, ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០២១ ) http://www.freshnewsasia.com/index.php/en/localnews/193183-2021-04-10-09-33-18.html ។

[94] ឃី សុវុឌ្ឍី "និពន្ធនាយកសារព័ត៌មានជាភាសាចិន នឹងត្រូវនិរទេសខ្លួនពីបទផ្សព្វផ្សាយ "ព័ត៌មានមិនពិត" អំពីការលក់វ៉ាក់សាំង( ខេមបូចា, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ )https://cambojanews.com/chinese-language-editor-to-be-deported-over-fake-news-vaccine-sales/; ណាត សុភាព «ក្រសួងដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួនពីរដោយមូលហេតុបំពានវិជ្ជាជីវៈធ្ងន់ធ្ងរ" (វីអូឌី, ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ) https://vodkhmer.news/2021/03/26/ministry-of-information-revokes-license-of-two-online-media-outlet-for-spreading-fake-news/ ។

[95] ទិន្នន័យនេះមិនអាចគណនាបានសម្រាប់ឆ្នាំទី១ និងឆ្នាំទី២ ។

[96] "កម្ពុជាពង្រីកវិសាលភាពនៃការតាមដាន "ព័ត៌មានមិនពិត" ( UCA News, ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ) https://www.ucanews.com/news/cambodia-expands-monitoring-of-fake-news/91186# ។

មតិតាម Telegram ក្នុងឆ្នាំទី៦ ដែលក្នុងនោះក្មេងជំទង់ម្នាក់អាយុ ១៦ ឆ្នាំ ដែលមានជំងឺអូទីហ្សឹម ត្រូវបានចាប់ខ្លួន[97] និង ផ្តន្ទាទោស[98] ពីបទទរិះគន់ថ្នាក់ដឹកនាំរដ្ឋាភិបាលនៅក្នុង Telegram។ មន្ត្រីរដ្ឋាភិបាលម្នាក់ត្រូវបានបណ្តេញចេញពីក្របខណ្ឌការងារ ដោយសារតែផ្សព្វផ្សាយ "ព័ត៌មានមិនពិត" តាមរយៈសារ Telegram[99] ហើយមនុស្សម្នាក់ត្រូវបានចាប់ខ្លួនពីបទរិះគន់រាជរដ្ឋាភិបាល ចំពោះការចាប់ខ្លួនជនដែលបង្ហាញពីទស្សនៈផ្ទាល់ខ្លួនជុំវិញជំងឺកូវីដ-១៩ នៅក្នុងសារជាសំឡេងដែលត្រូវបានបង្ហោះជាបន្តបន្ទាប់នៅក្នុងបណ្តាញទំនាក់ទំនងសង្គម។ [100]

*តួលេខទី១៧៖ ចំនួនភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរឹតត្បិតខ្លួនឯងកាលពីឆ្នាំមុន*




ស្របតាមរបកគំហើញ នេះមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេ ដែលមាន ៨៤% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព បានរាយការណ៍អំពីការរឹតត្បិតលើការនិយាយស្តីរបស់ខ្លួននៅឆ្នាំទី៦[101] ពោលគឺជ្រើសរើសមិននិយាយអ្វីដែលពួកគេចង់និយាយ ព្រោះពួកគេខ្លាចមានផលប៉ះពាល់។ ភាគរយដ៏ខ្ពស់នេះបង្ហាញថា បរិយាកាសបច្ចុប្បន្ននៅកម្ពុជា មិនអំណោយផលដល់ការអនុវត្ត និងការទទួលបានសេរីភាពខាងការបញ្ចេញមតិនោះទេ។

*តួលេខទី១៨៖ ចំនួនភាគរយនៃអ្នកឆ្លើយតបមានអារម្មណ៍ថាមិនមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួនតាមមធ្យោបាយផ្សេងៗ*




ក្រៅពីថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ការបង្កើនការរឹតបន្តឹងរបស់រដ្ឋាភិបាលលើប្រព័ន្ធអនឡាញក៏ទំនងជាបន្តបង្អាក់ដល់សាធារណជនទាំងមូលផងដែរ។ បណ្តាញទំនាក់ទំនងសង្គមគឺជា

[97] យួន ណារីម "កូនប្រុសអតីតមន្ត្រីគណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួនពីបទញុះញង់តាមបណ្តាញតេឡេក្រាម" (ខេមបូចា, ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០២១) https://cambojanews.com/former-cnrp-officials-son-arrested-on-charge-of-incitement-in-telegram-chat/។

[98] Eugene Whong "កម្ពុជាកាត់ទោសអនីតិជនដែលមានជំងឺអូទីហ្សឹមឱ្យជាប់ពន្ធនាគាររយៈពេលប្រាំបីខែ" (អាស៊ីសេរី, ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/kak-11012021171536.html ។

[99] ខន ចំប៉ា "អនុរដ្ឋលេខាធិការក្រសួងការងារមួយរូប ត្រូវអស់តំណែងក្រោយនិយាយព័ត៌មានមិនពិតជុំវិញកូវីដ-១៩" (ថ្មីថ្មី, ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២១) https://thmeythmey.com/?page=detail&id=103467 ។

[100] ការរាយការណ៍ពីហេតុការណ៍ IRCC៣១៤ ។

[101] ទិន្នន័យដែលបង្ហាញក្នុងក្រាហ្វនេះ រួមមានចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថា "ជានិច្ចកាល" "ជាប្រចាំ" ឬ "នៅពេលខ្លះ" ព្រួយបារម្ភនៅពេលនិយាយជាសាធារណៈត្រង់ចំណុចដែលពួកគេចង់និយាយ ។

មធ្យោបាយឆ្លើយឆ្លងទី ២ ដែលពួកគេអះអាងថា មិនមានសុវត្ថិភាពបំផុតនៅក្នុងឆ្នាំទី៦ បន្ទាប់ពីទូរទស្សន៍។[102]

## ២.៣. សេរីភាពខាងការជួបប្រជុំ

នៅឆ្នាំទី៦ គម្រោងបានកត់ត្រាការរឹតត្បិតចំនួន ៨៧ ករណីលើសេរីភាពខាងការជួបប្រជុំ ដែលក្នុងនោះ ៦០ ករណី (ឬ ៦៩%) មិនត្រូវបានអនុញ្ញាត ដែលជាការរំលោភលើសេរីភាពខាងការជួបប្រជុំ។ ការរឹតត្បិតទាំងនេះរាប់បញ្ចូលទាំងជនដែលត្រូវបានគំរាមកំហែងតាមរយៈបណ្តឹងផ្លូវច្បាប់ឬអំពើហិង្សាពីសំណាក់អាជ្ញាធរ ប្រសិនបើពួកគេធ្វើការតវ៉ា[103] ការប្រើកម្លាំងហួសហេតុពីសំណាក់អាជ្ញាធរ[104] ការជ្រៀតជ្រែកដោយឃ្លាំមើលលើការជួបប្រជុំគ្នា[105] និងទណ្ឌកម្មព្រហ្មទណ្ឌ។[106]

### *២.៣.១. ការជួបប្រជុំភាគច្រើនធ្វើឡើងដើម្បីតស៊ូមតិទាមទារសិទ្ធិដីធ្លី*

*តួលេខទី១៩៖ ចំនួននៃការជួបប្រជុំតាមប្រភេទនីមួយៗតាមត្រីមាស*




[102] ទិន្នន័យដែលបង្ហាញក្នុងក្រាហ្វនេះរួមមានចំនួនអ្នកឆ្លើយនឹងសំណួរដែលបានរាយការណ៍ថាពួកគេមានអារម្មណ៍ថា *"មិនមានសេរីភាពទាល់តែសោះ"* និង *"មានសេរីភាពតិចតួច"* ក្នុងការបញ្ចេញមតិរបស់ពួកគេនៅលើបណ្តាញទំនាក់ទំនងសង្គម ទៅកាន់សារព័ត៌មានប្រព័ន្ធផ្សព្វផ្សាយ ទូរទស្សន៍ ឬវិទ្យុ ឬកម្មវិធីទូរទស្សន៍។

[103] Isa Rohany "អ្នកភូមិដែលទាមទារសំណងដីធ្លីសមរម្យ ត្រូវបានគំរាមកំហែងដោយអំពើហិង្សា និងការបណ្តេញចេញ" (ខេមបូឌៀននីស, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១) https://cambodianess.com/article/villagers-demand-fair-compensation-for-land-threatened-with-violence-and-eviction ។

[104] Roseanne Gerin "អ្នកភូមិរងគ្រោះដោយកងកម្លាំងសន្តិសុខក្នុងជម្លោះដីចម្ការ" (អាស៊ីសេរី, ថ្ងៃទី៣ ខែមិថុនា ឆ្នាំ ២០២១) https://www.rfa.org/english/news/cambodia/land-dispute-06032021165939.html។

[105] ការរាយការណ៍ពីហេតុការណ៍ IRCC២៩៨ ។

[106] Roseanne Gerin "ពលរដ្ឋត្រូវបានចាប់ខ្លួនជុំវិញជម្លោះដីធ្លី" (អាស៊ីសេរី, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/villagers-arrested-09132021183947.html ។

ក្នុងអំឡុងឆ្នាំទី ៦ ការជួបប្រជុំគ្នាបានធ្វើឡើងដោយហេតុផលផ្សេងៗ។[107] ចំនួននៃការជួបប្រជុំគ្នាទាក់ទងនឹងជំងឺកូវីដ-១៩[108] កើនឡើងខ្ពស់ក្នុងត្រីមាសទី ២ ដោយសារតែមានការផ្ទុះរីករាលដាលជំងឺយ៉ាងខ្លាំងនៅកម្ពុជា នៅពេលដែលវិធានការរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគជំងឺកូវីដ-១៩ បានបង្កឱ្យមានការតវ៉ាជាច្រើន។ ចំនួននៃការជួបប្រជុំគ្នាទាក់ទងនឹងដីធ្លី បានកើនឡើងពីត្រីមាស១ ទៅត្រីមាស១ ហើយមានការជួបប្រជុំគ្នា ៥៦% នៃការជួបប្រជុំសរុបក្នុងឆ្នាំទី៦។ ការជួបប្រជុំដែលដឹកនាំដោយក្រុមស្ត្រីថ្ងៃសុក្រ[109] បានកើតឡើងពេញមួយឆ្នាំ ហើយក្នុងនោះមាន ១២% នៃចំនួនសរុប។

### ២.៣.២. ទោះបីជាសេរីភាពក្នុងការជួបប្រជុំគ្នា ភាគច្រើនត្រូវបានការពារក៏ដោយ ក៏បុគ្គលម្នាក់ៗមិនមានសេរីភាពក្នុងការអនុវត្តសិទ្ធិនេះដែរ។

*តួលេខទី២០៖ ចំនួនភាគរយនៃហេតុការណ៍ដែលការរឹតត្បិត ការរំលោភបំពាន ឬ ការការពារសេរីភាពខាងការជួបប្រជុំ*




សេរីភាពខាងការជួបប្រជុំត្រូវបានការពារយ៉ាងទូលំទូលាយ៖ លើកលែងតែនៅឆ្នាំទី៥ ការការពារសេរីភាពខាងការជួបប្រជុំគឺ ការរឹតត្បិតមានចំនួនច្រើនជាង។[110] ការការពារត្រូវបានកត់ត្រានៅពេលដែលបុគ្គលម្នាក់ៗ អាចអនុវត្តសេរីភាពខាងការជួបប្រជុំដោយសេរី និងដោយគ្មានការជ្រៀតជ្រែក ឬការរឹតត្បិតពីសំណាក់អាជ្ញាធរឬភាគីទីបី។

---

[107] តួលេខសរុបបន្ថែមរហូតដល់ ១៧៦ ខ្ពស់ជាងចំនួនសរុបនៃការជួបប្រជុំដែលបានកើតឡើងក្នុងឆ្នាំទី៦ដែលមានចំនួន ១៦៥ លើក។ នេះគឺដោយសារតែការជួបប្រជុំមួយចំនួនត្រូវបានកត់ត្រាត្រួតគ្នាលើសពីមួយប្រភេទ។ ជាឧទាហរណ៍ ការជួបប្រជុំគ្នាទាក់ទងនឹងការងារមួយចំនួនក៏ទាក់ទងនឹងបញ្ហាជំងឺកូវីដ-១៩ ផងដែរ។

[108] ការជួបប្រជុំទាក់ទងនឹងជំងឺកូវីដ-១៩ មានន័យថា ការជួបជុំទាំងឡាយដែលធ្វើឡើងដើម្បីឆ្លើយតបនឹងជំងឺកូវីដ-១៩។ មានដូចជា ការជួបប្រជុំគ្នាធ្វើឡើងដោយអាជីវករលក់ដូរនៅផ្សារ ដើម្បីស្នើសុំឱ្យបើកដំណើរការឡើងវិញបន្ទាប់ពីផ្សារត្រូវបានបិទដោយសារតែការផ្ទុះឡើងនូវជំងឺ ការប្រមូលផ្តុំគ្នារបស់ប្រជាពលរដ្ឋ ដើម្បីសុំជំនួយទ្រទ្រង់ជីវភាពក្នុងអំឡុងពេលបិទខ្ទប់ដោយសារជំងឺកូវីដ-១៩ ការតវ៉ាធ្វើឡើងដោយបុគ្គលិកតវ៉ាទាមទារប្រាក់ឈ្នួលដែលបាត់បង់ ឬការបញ្ឈប់ការងារដោយសារជំងឺកូវីដ-១៩ និងការជួបជុំសាច់ញាតិរបស់បុគ្គលជាប់ឃុំដែលសម្តែងការព្រួយបារម្ភចំពោះការឆ្លងរីករាលដាលនៃមេរោគជំងឺកូវីដ-១៩ នៅក្នុងពន្ធនាគារ។

[109] ក្រុមស្ត្រីថ្ងៃសុក្រ គឺជាក្រុមស្ត្រីដែលតែងប្រមូលផ្តុំគ្នាជាទៀងទាត់នៅមុខសាលាដំបូងរាជធានីភ្នំពេញនៅរៀងរាល់ថ្ងៃសុក្រ ដើម្បីស្នើសុំឱ្យមានការដោះលែងសាច់ញាតិរបស់ពួកគេចេញពីពន្ធនាគារ ដែលសុទ្ធសឹងជាសមាជិកអតីតគណបក្សសង្គ្រោះជាតិ។ ជួនកាល ក្រុមស្ត្រីថ្ងៃសុក្រ ក៏ប្រមូលផ្តុំគ្នាដើម្បីដាក់ញត្តិទៅស្ថានទូតនានា ដើម្បីស្វែងរកការអន្តរាគមន៍ពីរដ្ឋាភិបាលបរទេសដើម្បីឱ្យមានការដោះលែងសាច់ញាតិរបស់ពួកគេ។ ការតវ៉ារបស់ពួកគេដែលភាគច្រើនធ្វើឡើងនៅមុខសាលាដំបូងរាជធានីភ្នំពេញ ឬនៅមុខស្ថានទូតនានាក្នុងរាជធានីភ្នំពេញ តែងមានការរំខានពីសំណាក់អាជ្ញាធរ។

[110] មិនមានទិន្នន័យនេះទេសម្រាប់ឆ្នាំទី១ និងឆ្នាំទី២។

ទោះយ៉ាងណា យោងតាមទិន្នន័យផ្សេងទៀត បង្ហាញថា បុគ្គលម្នាក់ៗមិនមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំនោះទេ។ មានតែ ៥៥% នៃអ្នកឆ្លើយតបការស្ទង់មតិជាសាធារណៈ និង ៣៥% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពប៉ុណ្ណោះ បាននិយាយថា ពួកគេមានអារម្មណ៍ថា មានសេរីភាពក្នុងការអនុវត្តសេរីភាពក្នុងការជួបប្រជុំគ្នានៅឆ្នាំទី៦។

*តួលេខទី២១៖ ចំនួនភាគរយនៃបុគ្គលដែលមានអារម្មណ៍ថា មានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី*




*តួលេខទី២២៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលមានអារម្មណ៍សេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ*




មានការយល់ឃើញខុសៗគ្នាថា ការជួបប្រជុំគ្នាភាគច្រើនត្រូវបានការពារ ប៉ុន្តែបុគ្គលម្នាក់ៗនៅតែមិនមានសេរីភាពក្នុងការជួបប្រជុំគ្នា ដោយសារតែការជួបប្រជុំហាក់ដូចជាត្រូវបានការពារមិនស្មើគ្នា អាស្រ័យលើហេតុផលនៃការជួបប្រជុំជាក់ស្តែង (សូមមើលតួលេខទី២៨)។ ដូច្នេះហើយ បុគ្គលម្នាក់អាចមានអារម្មណ៍ថា គ្រាន់តែអាចចូលរួមក្នុងការជួបប្រជុំគ្នាមួយចំនួនប៉ុណ្ណោះ។

---

ចំនួនភាគរយដ៏ទាបនៃបុគ្គលម្នាក់ៗ និងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលមានអារម្មណ៍ថា មានសេរីភាពក្នុងការអនុវត្តសេរីភាពនៃការជួបប្រជុំ ក៏អាចបណ្តាលមកពីការគំរាមកំហែងឃុំខ្លួន និងចាប់ខ្លួនផងដែរ ចំពោះអ្នកដែលចូលរួមក្នុងការជួបប្រជុំ។ ការអនុវត្តសេរីភាពក្នុងការជួបប្រជុំបាននាំឱ្យមនុស្សចំនួន ៦២ នាក់ ត្រូវបានឃុំខ្លួន និង ៧២ នាក់ ត្រូវបានចាប់ខ្លួនក្នុងឆ្នាំទី៦ ដែលជាចំនួនខ្ពស់បំផុតក្នុងចំណោមសេរីភាពទាំងបី។[111]

*តួលេខទី២៣៖ ចំនួនបុគ្គលដែលត្រូវបានចាប់ខ្លួនពីការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេ*




*តួលេខទី២៤៖ចំនួនបុគ្គលដែលត្រូវបានឃុំខ្លួនដោយសារការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេ*




[111] ជារួមការចាប់ខ្លួនដែលបានធ្វើឡើងនៅក្នុងឆ្នាំទី៦ មានដីកាចាប់ខ្លួនចំនួន១១ ដែលបានចេញប្រឆាំងនឹងបុគ្គលដែលអនុវត្តសេរីភាពខាងសមាគមរបស់ខ្លួន ហើយដីកាចំនួន១០ ត្រូវបានចេញប្រឆាំងនឹងបុគ្គលដែលអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេ។

*ឧទាហរណ៍ ៖ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ មនុស្សចំនួន៩ នាក់ដែលចូលរួមធ្វើកូដកម្មនៅមុខអាគារណាហ្គាវើលដ៍ត្រូវបានអាជ្ញាធរចាប់ខ្លួនក្រោមបទ ញុះញង់ប្រព្រឹត្តបទឧក្រិដ្ឋ តាមមាត្រា ៤៩៤ និង៤៩៥ [112]នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយសារតែពួកគេបានរៀបចំកូដកម្មដែលអាជ្ញាធរអះអាងថា "ជាបាតុកម្មខុសច្បាប់"។[113] កូដកម្មនេះបានចាប់ផ្ដើមនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ដែលមានបុគ្គលិកនិងអតីតបុគ្គលិកកាស៊ីណូណាហ្គាវើលដ៍ រាប់រយនាក់ដែលតែងប្រមូលផ្ដុំរៀងរាល់ថ្ងៃនៅក្បែរកាស៊ីណូ ទាមទារឱ្យក្រុមហ៊ុនទទួលយកបុគ្គលិកជាង៣០០ នាក់ដែលក្រុមហ៊ុនបានបញ្ឈប់ឱ្យចូលធ្វើការវិញ។[114]*

### ២.៣.៣. ការជួបប្រជុំគ្នាដែលដឹកនាំដោយក្រុមស្ត្រីថ្ងៃសុក្រ ត្រូវបានអាជ្ញាធរកំណត់ជាមុខសញ្ញា

ទោះបីការជួបជុំរបស់ក្រុមស្ត្រីថ្ងៃសុក្រមានចំនួនត្រឹមតែ ១២% នៃការជួបប្រជុំទាំងអស់ដែលបានកើតឡើងក្នុងអំឡុងពេលនៃរបាយការណ៍(សូមមើលតួលេខទី២៥) ក៏ដោយក៏ការជួបជុំគ្នារបស់ពួកគេទទួលរងការ

*តួលេខទី២៥៖ ចំនួនភាគរយការជួបប្រជុំរបស់ក្រុមស្ត្រីថ្ងៃសុក្រនៅឆ្នាំទី៦*




*តួលេខទី២៦៖ ចំនួនភាគរយនៃការជួបប្រជុំរបស់ក្រុមស្ត្រីថ្ងៃសុក្រត្រូវបានជៀតជ្រែកក្នុងឆ្នាំទី៦*




*តួលេខទី២៧៖ ប្រភេទនៃការជួបប្រជុំដែលត្រូវបានជៀតជ្រែកក្នុងឆ្នាំទី៦*




---

[112] Gerald Flynn, "អាជ្ញាធរចាប់ខ្លួនសហជីពចំនួន៩នាក់មុនថ្ងៃឆ្លងឆ្នាំសកល" (ខេមបូឌៀននីស, ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ https://cambodianess.com/article/nine-nagaworld-unionists-arrested-on-new-years-eve ។

[113] អាជ្ញាធរអះអាងថាកូដកម្មធ្វើឡើងដោយខុសច្បាប់។ មុនពេលកូដកម្ម នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ សាលាដំបូងរាជធានីភ្នំពេញបានចាត់ទុកថាជាកូដកម្មខុសច្បាប់។ សហជីពទ្រទ្រង់សិទ្ធិកម្មករនៃក្រុមហ៊ុនណាហ្គាវើលដ៍ មិនមានឱកាសឆ្លើយតបទៅនឹងសំណើរបស់ក្រុមហ៊ុនណាវើលដ៍ក្នុងការហាមឃាត់មិនឱ្យធ្វើកូដកម្ម មុនពេលមានការសម្រេចចិត្តនោះទេ ដែលរំលោភលើមាត្រា ៥៤៨ វាក្យខ័ណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលតម្រូវឱ្យតុលាការណាត់ជួបគូភាគីដើម្បីទាញហេតុផលផ្ទាល់មាត់មុនពេលចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន។ ២ថ្ងៃបន្ទាប់មក ជាថ្ងៃដំបូងនៃការធ្វើកូដកម្ម អភិបាលរាជធានីភ្នំពេញលោក ឃួង ស្រេង ចេញលិខិតជូនដំណឹងដោយនិយាយថា "បាតុកម្ម" ធ្វើឡើងមិនគោរពតាមច្បាប់ស្ដីពីបាតុកម្មដោយសន្តិវិធី។ ទោះជាយ៉ាងណាក៏ដោយ ចំណុចទី ៣.១.២ ផ្នែកទី១ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្ដីពីបាតុកម្មដោយសន្តិវិធីមិនបានអនុវត្តមកលើវិវាទការងារ ដែលរៀបចំឡើងនៅក្រៅឬក្បែរសហគ្រាសនោះទេ។

[114] នៅខែមេសា ឆ្នាំ២០២១ ក្រុមហ៊ុនណាហ្គាវើលដ៍បានបញ្ឈប់បុគ្គលិកប្រមាណ ១,៣០០ នាក់ ដោយអះអាងថាក្រុមហ៊ុនបានធ្លាក់ចុះចំណូលដោយសារតែជំងឺរាតត្បាតកូវីដ-១៩ ។ ភាគច្រើននៃបុគ្គលិកដែលបានបញ្ឈប់គឺជាសមាជិកនិងថ្នាក់ដឹកនាំសហជីព។ បន្ទាប់ពីបរាជ័យក្នុងការចរចារជាច្រើនលើកជាមួយក្រុមហ៊ុននិងបរាជ័យក្នុងការប្ដឹងទៅអាជ្ញាធរពាក់ព័ន្ធ។ សហជីពក៏បានជូនដំណឹងទៅអាជ្ញាធរអំពីគម្រោងរបស់ពួកគេក្នុងការធ្វើកូដកម្មដោយសន្តិវិធីផងដែរ។

ជៀតជ្រែករហូតដល់ ៣៨% នៃការជួបប្រជុំសរុបដែលបានកត់ត្រាក្នុងឆ្នាំទី៦ (សូមមើលតួលេខទី២៧)។ ក្នុងចំណោមការជួបប្រជុំរបស់ក្រុមស្ត្រីថ្ងៃសុក្រ ទាំង ១៩ ដែលបានធ្វើឡើងនៅឆ្នាំទី៦ មាន ១៨ ករណី (ឬ ៩៥%) ត្រូវបានជ្រៀតជ្រែក (សូមមើលតួលេខទី២៦)។

ទិន្នន័យនេះបង្ហាញថា ការជួបប្រជុំគ្នារបស់ក្រុមស្ត្រីថ្ងៃសុក្រ ត្រូវរដ្ឋាភិបាលបានកំណត់មុខសញ្ញា។ នេះអាចបណ្តាលមកពីភាពរសើបនៃការទាមទារ ពោលគឺការអះអាងថា សមាជិកអតីតគណបក្សសង្គ្រោះជាតិប្រឈមនឹងការចោទប្រកាន់ពាក់ព័ន្ធនឹងរឿងនយោបាយ និងការឃុំខ្លួនតាមទំនើងចិត្ត។

រដ្ឋាភិបាលកំណត់មុខសញ្ញាទៅលើការតវ៉ារបស់ក្រុមស្ត្រីថ្ងៃសុក្រដោយពុំបានកំណត់មុខសញ្ញាទៅលើការជួបប្រជុំដទៃទៀតទេ ដែលនេះបង្ហាញថាការជួបប្រជុំរបស់ក្រុមស្ត្រីថ្ងៃសុក្រ បានរងការបង្ក្រាបយ៉ាងខ្លាំងនៅឆ្នាំទី៦។ ជាការពិតណាស់ ទោះបីជា ៩៥% នៃការជួបប្រជុំគ្នារបស់ក្រុមស្ត្រីថ្ងៃសុក្រ ត្រូវបានជ្រៀតជ្រែកក្នុងឆ្នាំទី៦ ក៏ដោយ ក៏ចំនួនភាគរយនេះគឺទាបជាងការជួបប្រជុំប្រភេទផ្សេងទៀតយ៉ាងច្រើន ដែលបង្ហាញថាសេរីភាពខាងការជួបប្រជុំគឺមិនត្រូវបានលើកកម្ពស់ដូចគ្នាទេ គឺអាស្រ័យលើបុព្វហេតុនៃការជួប្រជុំទាំងនោះ។

*តួលេខទី២៨៖ ចំនួនភាគរយនៃការជួបប្រជុំដែលត្រូវបានជ្រៀតជ្រែកតាមប្រភេទនៃការជួបប្រជុំ*




ការកំណត់ជាមុខសញ្ញាដោយមិនមានភាពសមាមាត្រពីសំណាក់អាជ្ញាធរ ចំពោះការជួបប្រជុំរបស់ក្រុមស្ត្រីថ្ងៃសុក្រ កាន់តែបង្ហាញយ៉ាងជាក់ស្តែងបន្ថែមទៀតនៅពេលពិនិត្យមើលពីការប្រើប្រាស់កម្លាំងរបស់រដ្ឋក្នុងអំឡុងពេលនៃការជួបប្រជុំ។ នៅឆ្នាំទី៦ គម្រោងបានកត់ត្រាការជួបប្រជុំគ្នាចំនួន ២២ លើកដែលអាជ្ញាធរបានប្រើកម្លាំងក្នុងអំឡុងពេលនោះ។ គ្រប់ករណីទាំងអស់សុទ្ធតែមានការប្រើអំពើហិង្សាក្នុងអំឡុងពេលការជួបប្រជុំគ្នា ក្នុងនោះការជួបប្រជុំអំពីបញ្ហាដីធ្លី (ប្រាំមួយដង) ឬក្នុងអំឡុងពេលនៃការជួបប្រជុំគ្នាទាមទារឱ្យមានការដោះលែងសមាជិកអតីតគណបក្សសង្គ្រោះជាតិដែលកំពុងជាប់ពន្ធនាគារ (១៥ ដង) ។ ការប្រើប្រាស់កម្លាំង មានដូចជាការរុញ និងទាញអ្នកតវ៉ា [115] ការវាយដំ[116] ឬការវាយដោយហិង្សា ដែលខ្លះបណ្តាលឱ្យមានរបួសធ្ងន់

[115] យុត សុគន្ធ "គ្រួសារអតីតសកម្មជនបក្សជំទាស់បន្តរងការរារាំងពីអាជ្ញាធរ ខណៈពួកគេតវ៉ាមុខតុលាការ" (វីអូឌី, ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២១) https://vodkhmer.news/2021/01/29/former-cnrp-activist-families-continues-their-protest-in-front-of-court/ ។

[116] ម៉ិច ដារ៉ា "កសិករបានប្រានចោលការចុះផ្សាយដីធ្លីបស់រដ្ឋ" ចាប់ខ្លួនស្រេចតែចិត្តអ្នក" ( វីអូឌី, ថ្ងៃទី២៦ ខែមករា ឆ្នាំ ២០២១)https://vodenglish.news/farmers-rip-out-state-land-post-if-you-want-to-arrest-us-its-up-to-you/ ។

ធូរ។[117] គ្រប់ករណីទាំងអស់ ការប្រើកម្លាំងរបស់អាជ្ញាធរត្រូវបានចាត់ទុកថាមិនមានភាពសមាមាត្រ ឬមិនសមហេតុផល ព្រោះលើសពីអ្វីដែលចាំបាច់ ដើម្បីសម្រេចបាននូវ *"គោលបំណងស្របច្បាប់នៃការបំបែកការជួបប្រជុំ ការការពារឧក្រិដ្ឋកម្ម ឬមានប្រសិទ្ធភាព ឬជួយក្នុងការចាប់ខ្លួនជនល្មើស ឬជនជាប់សង្ស័យដោយស្របច្បាប់"*។[118] ដូច្នេះ ការប្រើកម្លាំងទាំងនេះគឺជាការរំលោភលើសេរីភាពខាងការជួបប្រជុំ។ គួរកត់សម្គាល់ថា មកទល់ពេលនេះ មិនទាន់មាននរណាម្នាក់ ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះហេតុការណ៍ហឹង្សាបំពានទាំងនេះនៅឡើយទេ។

*តួលេខទី ២៩៖ ចំនួននៃការជួបប្រជុំគ្នាក្នុងអំឡុងពេលដែលកម្លាំងរបស់រដ្ឋត្រូវបានប្រើប្រាស់ដោយមិនមានភាពសមាមាត្រ តាមប្រភេទនៃការជួបប្រជុំគ្នា*




*ការជួបប្រជុំចំនួន ២ ក្នុងចំណោមនោះមានអំពើហិង្សាបានសំដៅមកក្រុមអ្នកឃ្លាំមើលរបស់ ម.ស.ម.ក ដោយត្រូវបានដេញចេញពីកន្លែងតវ៉ាដោយអាជ្ញាធរជាជាងសំដៅទៅរកក្រុមស្ត្រីថ្ងៃសុក្រ។*

***ឧទាហរណ៍៖*** *នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ក្រុមស្ត្រីថ្ងៃសុក្រ ប្រហែល ២០ នាក់បានប្រមូលផ្តុំគ្នាដោយសន្តិវិធីនៅខាងក្រៅស្ថានទូតបារាំង ដើម្បីតវ៉ា និងដាក់ញត្តិអំពាវនាវឱ្យរដ្ឋាភិបាលបារាំង និងកម្ពុជាបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ អំឡុងពេលតវ៉ា មន្ត្រីនគរបាលក្នុងសម្លៀកបំពាក់ឯកសណ្ឋាន និងស៊ីវិល បានឡោមព័ទ្ធស្ត្រីទាំងនោះ ដោយរុញពួកគេមួយចំនួនឱ្យដួលទៅលើដីដេរប្រមាថ និងយកជើងជាន់លើពួកគេ។*[119]

ការរឹតត្បិតជាច្រើនលើសេរីភាពមូលដ្ឋានដែលបានកត់ត្រាក្នុងឆ្នាំទី៦ បង្ហាញពីការអនុវត្តមិនត្រឹមត្រូវ និង តាមទំនើងចិត្ត ក្រៅពីក្របខ័ណ្ឌច្បាប់របស់កម្ពុជា។ ច្បាប់ត្រូវបានប្រើប្រាស់ ដើម្បីបង្រួញសិទ្ធិពលរដ្ឋ មិនមែនដើម្បីការពារសេរីភាពមូលដ្ឋានទេ។ សកម្មភាពរបស់អាជ្ញាធរតែងធ្វើលើសពីដែនកំណត់នៃការរឹតត្បិតដែលអាចអនុញ្ញាតបាន ដែលនោះគឺជាការរំលោភបំពាន។ សមាគមរងការជ្រៀតជ្រែក ហើយសមាជិករបស់សមាគមត្រូវបានកំណត់មុខសញ្ញា។ ក្រុមអ្នកតវ៉ាដែលធ្វើការទាមទារបញ្ហារសើបផ្នែកនយោបាយ ត្រូវបានអាជ្ញាធរកំណត់មុខសញ្ញាដោយមិនសមហេតុផល ដែលជារឿយៗនាំឱ្យមានអំពើហិង្សា។ រដ្ឋាភិបាលបានពង្រីកវិសាលភាពនៃត្រួតពិនិត្យនិងតាមដាន លើការនិយាយស្តីតាមអនឡាញព្រមទាំង ការជ្រៀតជ្រែកមកលើការងារអ្នកសារព័ត៌មាន បានបំពានលើបទដ្ឋានសេរីភាពខាងការបញ្ចេញមតិ។ ការប្រើច្បាប់ដើម្បីរារាំងបុគ្គលក្នុងការអនុវត្តពេញលេញនូវសិទ្ធិសេរីភាពមូលដ្ឋាន ទំនងជាមិននាំឱ្យមានជាលទ្ធផលនៅក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសមធម៌ ឬលទ្ធិប្រជាធិបតេយ្យដ៏រស់រវើកនោះទេ។

---

[117] យុត សុគន្ធ "ផ្ទះសម្បែងត្រូវបានរុះរើ ខណៈដែលអាជ្ញាធរប៉ះទង្គិចជាមួយអ្នកស្រុកបឹងសំរោង" (វីអូឌី, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១) https://vodenglish.news/homes-dismantled-as-authorities-clash-with-boeng-samrong-residents/ ។

[118] សេចក្តីពន្យល់ទូទៅលេខ ៣៧ (ឆ្នាំ២០២០) ស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធី (មាត្រា ២១) CCPR/C/GC/៣៧ (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០) កថាខណ្ឌទី ៧៩ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ https://undocs.org/CCPR/C/GC/37 ។

[119] Eugene Whong "ខួបលើកទី ៣០ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស មានចន្លោះប្រហោងសម្រាប់ប្រជាជនកម្ពុជាជាច្រើន" (អាស៊ីសេរី, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១) https://www.rfa.org/english/news/cambodia/paris-10222021221126.html ។

## ៣. ចំណុចគន្លឹះទី៣៖ តើបុគ្គលម្នាក់ៗយល់ដឹងអំពីសេរីភាពមូលដ្ឋាន និងយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសេរីភាពទាំងនេះដែរឬទេ?

ចំណុចគន្លឹះទី៣ វាយតម្លៃពីកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាអំពីសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ និងកម្រិតដែលពួកគេយល់ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពទាំងនោះ។[120] ទិន្នន័យចំណុចគន្លឹះទីបីត្រូវបានប្រមូលតាមរយៈការស្ទង់មតិជាសាធារណៈជាមួយពលរដ្ឋកម្ពុជាចំនួន ៩២៥ នាក់នៅទូទាំង ២៥ រាជធានី-ខេត្ត ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។[121] វិធីសាស្ត្រការជ្រើសរើសសំណាកងាយៗត្រូវបានប្រើសម្រាប់ធ្វើការស្ទង់មតិនេះ។

**របកគំហើញសំខាន់ៗ៖** ទិន្នន័យពីចំណុចគន្លឹះទី៣ បង្ហាញឱ្យឃើញថាការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅតែមានកម្រិតថេរដដែល។ ចំណេះដឹងរបស់សាធារណជនអំពីក្របខ័ណ្ឌច្បាប់ទាក់ទងនឹងសេរីភាពមូលដ្ឋានក៏មានកម្រិតដូចគ្នាដែរ។ ច្បាប់ទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ នៅតែជាចំណុចដែលត្រូវបានយល់ខុសយ៉ាងខ្លាំង។ ការស្ទង់មតិឆ្នាំទី៦នេះ បានបង្ហាញនូវការកើនឡើងនូវចំនួនភាគរយនៃអ្នកឆ្លើយតបដែលបានយល់ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ បន្ទាប់ពីបានធ្លាក់ចុះអស់រយៈពេលបួនឆ្នាំកន្លងមក ចំនួននៃអ្នកឆ្លើយតបជាស្ត្រីដែលបានរាយការណ៍ថាមានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ មានការកើនឡើងស្ទើរតែជិតទ្វេដងចាប់ពីឆ្នាំទី៥ ដល់ឆ្នាំទី៦។

### ៣.១. ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅតែមានកម្រិតថេរដដែល




*តួលេខទី៣០៖ ភាគរយនៃសាធារណជនដែលបានរាយការណ៍ថាមានការយល់ដឹងខ្លះអំពីសេរីភាពមូលដ្ឋាន*

នៅឆ្នាំទី៦ ការយល់ដឹងរបស់សាធារណជន អំពីសេរីភាពនីមួយៗនៅតែមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំង ក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ។[122] ដូចគ្នានឹងឆ្នាំមុនៗដែរ សេរីភាពខាងសមាគម នៅតែជាសេរីភាពដែលត្រូវបានយល់ដឹងតិចតួចបំផុត។ ស្របតាមការវិវឌ្ឍដែលបានអង្កេតនៅឆ្នាំកន្លងមកបានឱ្យឃើញថា ភាគរយនៃអ្នកឆ្លើយតបដែលបានឆ្លើយថាពួកគេដឹង *"ច្បាស់ណាស់"* ពីអត្ថន័យនៃសេរីភាពនីមួយៗមានកម្រិតទាបបំផុតគឺ

---

[120] ទិន្នន័យចំណុចគន្លឹះទី៣ បានមកពីការស្ទង់មតិជាសាធារណៈរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ដែលបានធ្វើឡើងក្នុងអំឡុងខែតុលា ឆ្នាំ២០១៦ (ឆ្នាំទី១) ខែមីនា ឆ្នាំ២០១៨ (ឆ្នាំទី២) ខែមីនា ឆ្នាំ២០១៩ (ឆ្នាំទី៣) ខែមីនា ឆ្នាំ២០២០ (ឆ្នាំទី៤) ខែធ្នូ ឆ្នាំ២០២០ (ឆ្នាំទី៥) និង ខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២១ (ឆ្នាំទី៦)។

[121] លទ្ធផលពីការស្ទង់មតិជាសាធារណៈឆ្នាំទី៦ ទាំងមូលមាននៅក្នុងឧបសម្ព័ន្ធទី ៣។

[122] ទិន្នន័យដែលបង្ហាញក្នុងក្រាហ្វិកនេះ រួមមានចំនួននៃអ្នកឆ្លើយតបដែលបានរាយការណ៍ថា បានដឹង *"ច្បាស់ណាស់"* ឬ *"តិចតួច"* អំពីសេរីភាពមូលដ្ឋាននីមួយៗ។ នៅក្នុងការស្ទង់មតិឆ្នាំទី១ ការសួរសំណួរនេះបានធ្វើឡើងខុសគ្នាពីឆ្នាំបន្តបន្ទាប់ ដូច្នេះមិនអាចកំណត់ជាក់លាក់បានទេ។

ត្រឹម ៤% សម្រាប់សេរីភាពខាងសមាគម ៨% សម្រាប់សេរីភាពខាងការបញ្ចេញមតិ និង ១១% សម្រាប់សេរីភាពខាងការជួបប្រជុំ។ ចំនួនភាគរយដ៏ទាបទាំងនេះ បង្ហាញថាពលរដ្ឋកម្ពុជាមួយភាគធំមិនអាចកំណត់ដឹងថាតើការរំលោភបំពានលើសេរីភាពមូលដ្ឋានកើតឡើងនៅពេលណានោះទេ ដែលនាំឱ្យពួកគេមិនបានត្រៀមខ្លួនឆ្លើយតបដើម្បីទាមទារសិទ្ធិ និងទាមទារឱ្យអ្នកប្រព្រឹត្តទទួលខុសត្រូវចំពោះការរំលោភបំពាននោះ។

## ៣.២ ចំណេះដឹងរបស់សាធារណជនអំពីច្បាប់ជាតិទាក់ទងនឹងសេរីភាពមូលដ្ឋានមានការកើនឡើង

ការស្ទង់មតិជាសាធារណៈពិនិត្យមើលពីកម្រិតនៃការយល់ដឹងអំពីច្បាប់ជាតិទាក់ទងនឹងសេរីភាពមូលដ្ឋានដោយសួរទៅកាន់អ្នកឆ្លើយតបអំពីសកម្មភាពជាក់លាក់ណាមួយថាតើសកម្មភាពនោះស្របច្បាប់ឬខុសច្បាប់។

### ៣.២.១. សេរីភាពខាងការបញ្ចេញមតិ

ចំនួនអ្នកឆ្លើយសំណួរនីមួយៗដែលឆ្លើយបានត្រឹមត្រូវក្នុងឆ្នាំទី៦ គឺស្ទើរតែដូចគ្នាទៅនឹងឆ្នាំមុន ដោយគ្រាន់តែមានការកើនឡើងតិចតួចនៃភាគរយអ្នកដែលបានឆ្លើយត្រឹមត្រូវថាស្របច្បាប់ក្នុងការជជែកអំពីនយោបាយ។[123]




*តួលេខទី៣១៖ ការយល់ដឹងរបស់សាធារណជនអំពីក្របខ័ណ្ឌច្បាប់ទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ*

ខណៈដែលអត្រាចម្លើយត្រឹមត្រូវចំពោះសំណួរទាំងអស់ទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិខ្ពស់ជាងឆ្នាំមុនៗក៏ដោយ ក៏មាន ២៨% នៃអ្នកឆ្លើយតបមិនដឹងថាការពិភាក្សាអំពីរឿងនយោបាយ គឺជារឿងស្របច្បាប់ ឬឆ្លើយសំណួរមិនត្រឹមត្រូវ។ ស្រដៀងគ្នានេះដែរ ៤៣% នៃអ្នកឆ្លើយតបការស្ទង់មតិមិនដឹងថា ជារឿងស្របច្បាប់ក្នុងការរិះគន់គោលនយោបាយរបស់រាជរដ្ឋាភិបាល ឬឆ្លើយខុសទៅនឹងសំណួរនេះ។

របកគំហើញទាំងនេះបង្ហាញថា សាធារណជនមួយភាគធំយល់ថាច្បាប់ជាតិមានភាពតឹងរ៉ឹងជាងភាពជាក់ស្តែង ដែលរារាំងដល់ការបញ្ចេញមតិដោយសេរីលើបញ្ហានយោបាយ។

[123] សំណួរទាំងនេះមិនមានសួរនៅក្នុងការស្ទង់មតិឆ្នាំទី១នោះទេ។

## ៣.២.២ សេរីភាពខាងការជួបប្រជុំ




*តួលេខទី៣២៖ ការយល់ដឹងរបស់សាធារណជនអំពីក្របខ័ណ្ឌច្បាប់ទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ*

ចាប់ពីដំណើរការគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានមកម្ល៉េះ មានអ្នកឆ្លើយតបតិចជាងមួយភាគបីបានឆ្លើយត្រឹមត្រូវថា ជារឿងស្របច្បាប់ ក្នុងការធ្វើកូដកម្មដោយគ្មានការអនុញ្ញាត។ ចំពោះភាគរយនៃអ្នកឆ្លើយតបដែលឆ្លើយត្រឹមត្រូវថា ជារឿងស្របច្បាប់ក្នុងការតវ៉ាដោយសន្តិវិធី នៅមានកម្រិតទាបនៅឡើយ ពោលគឺជាង ៥០% ។[124] កម្រិតនៃការយល់ដឹងទាបរបស់សាធារណជន អំពីច្បាប់ទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ អាចរារាំងពួកគេក្នុងការអនុវត្តសិទ្ធិមូលដ្ឋាននេះ។

---

**អ្នកឆ្លើយមិនត្រឹមត្រូវចំនួន១៥% បានរាយការណ៍ថា ជារឿងស្របច្បាប់ដែលអាជ្ញាធរប្រើប្រាស់កម្លាំង ដើម្បីបំបែកការជួបប្រជុំដោយសន្តិវិធី។**

នៅឆ្នាំទី ៦ មានអ្នកឆ្លើយមិនត្រឹមត្រូវចំនួន ១៥% ថាជារឿងស្របច្បាប់ដែលអាជ្ញាធរប្រើប្រាស់កម្លាំងដើម្បីបំបែកការជួបប្រជុំដោយសន្តិវិធី។ យោងតាមមាត្រា ១៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចែងថា អាជ្ញាធរ *"មិនត្រូវជ្រៀតជ្រែកដល់ការប្រព្រឹត្តទៅនៃការធ្វើបាតុកម្មដោយសន្តិវិធីឡើយ"*។

[124] សំណួរទាំងនេះមិនមានសួរនៅក្នុងការស្ទង់មតិឆ្នាំទី១នោះទេ។

### ៣.២.៣. សេរីភាពខាងសមាគម




*តួលេខទី៤៖ ការយល់ដឹងរបស់សាធារណជនអំពីក្របខណ្ឌច្បាប់ទាក់ទងនឹងសេរីភាពខាងសមាគម*

យោងតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចែងថាសមាគមទាំងអស់ រួមទាំងក្រុមសន្សំប្រាក់[125] ត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃដើម្បីដំណើរការស្របតាមច្បាប់។[126] ផ្អែកតាមលទ្ធផល ក្នុង រយៈពេលប្រាំឆ្នាំចុងក្រោយនេះ ហាក់ដូចជាបង្ហាញថា ទោះជាមនុស្សភាគច្រើនដឹងថា លក្ខខណ្ឌនៃការចុះបញ្ជីនេះត្រូវបានអនុវត្តចំពោះអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ក៏ចំនួននៃអ្នកដែលដឹងថាការអនុវត្តចំពោះក្រុមសន្សំប្រាក់ គឺមានកម្រិតទាបជាងនៅ ឡើយ។[127] ទោះយ៉ាងណា គួរកត់សម្គាល់ថា លក្ខខណ្ឌនៃការចុះបញ្ជីដែលបានកំណត់មកលើសមាគមក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល គឺមិនស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងបទដ្ឋាននៃសេរីភាពខាងសមាគមនោះទេ។

## ៣.៣. ពលរដ្ឋកម្ពុជាភាគច្រើនយល់ថាមានសេរីភាពកាន់តែខ្លាំងឡើងក្នុងការអនុវត្តសេរីភាពស្របច្បាប់របស់ខ្លួន

ការស្ទង់មតិជាសាធារណៈវាយតម្លៃថា តើបុគ្គលម្នាក់ៗមានអារម្មណ៍ថា មានសេរីភាពកម្រិតណាដែរក្នុងការអនុវត្តសេរីភាពរបស់ខ្លួន ដោយបានសួរពួកគេថា តើពួកគេមានសេរីភាពកម្រិតណាក្នុងការធ្វើសកម្មភាពតាមរយៈការអនុវត្តសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងសមាគម?

[125] ក្រុមសន្សំប្រាក់ គឺជាវិធីសាស្រ្តហិរញ្ញវត្ថុមួយរបស់សហគមន៍ ដែលក្នុងនោះសមាជិកសហគមន៍ប្រមូលប្រាក់របស់ខ្លួនដាក់បញ្ចូលរួមគ្នា ដែលអាចឱ្យពួកគេផ្តល់ប្រាក់កម្ចីដល់អ្នកភូមិសម្រាប់ប្រើប្រាស់ក្នុងការចំណាយលើការថែទាំសុខភាព ការអប់រំ ឧបករណ៍កសិកម្ម ឬបន្ទុកហិរញ្ញវត្ថុបន្ទាន់ផ្សេងទៀត។

[126] មាត្រា ៩ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ហាមឃាត់មិនឱ្យអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមដែលមិនបានចុះបញ្ជីធ្វើសកម្មភាពគ្រប់ប្រភេទ។ មាត្រា ៣២ ចែងពីការផ្តន្ទាទោសព្រហ្មទណ្ឌក្នុងករណីមានការរំលោភបំពានមាត្រា ៩ ដោយប្រការណាមួយ ។ ដូចបានកត់សម្គាល់ក្នុងរបាយការណ៍ឆ្នាំទី១ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបង្ហាញថា បញ្ញត្តិនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះរំលោភបំពានមាត្រា ២២ នៃ ក.អ.ស.ព.ន។ សូមមើល ម.ស.ម.ក សមាគមអាដហុក មជ្ឈមណ្ឌលសាគ្គីភាព និងអាយស៊ីអិនអិល, "គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន៖របាយការណ៍ឆ្នាំទី១" (ខែសីហា ឆ្នាំ២០១៧), https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf.

[127] សំណួរទាំងនេះមិនមានសួរនៅក្នុងការស្ទង់មតិឆ្នាំទី១នោះទេ។

## ៣.៣.១. សេរីភាពខាងការបញ្ចេញមតិ

ការស្ទង់មតិជាសាធារណៈឆ្នាំទី៦ មានសំណួរចំនួនប្រាំពីរបានសួរទៅអ្នកឆ្លើយតបទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ៖ ១) តើអ្នកគិតថា អ្នកមានសេរីភាពកម្រិតណា ក្នុងការស្លៀកពាក់តាមចំណង់ចំណូលចិត្តរបស់អ្នក? ២) តើអ្នកគិតថា អ្នកមានសេរីភាពកម្រិតណាក្នុងការនិយាយដោយបើកចំហគ្រប់ប្រធានបទនៅទីសាធារណៈ? ៣) តើអ្នកគិតថា អ្នកមានសេរីភាពកម្រិតណាក្នុងការនិយាយគ្រប់ប្រធានបទទាំងអស់ នៅលើបណ្តាញសង្គម? ៤) តើអ្នកគិតថា អ្នកមានសេរីភាពកម្រិតណាក្នុងការបញ្ចេញមតិទៅកាន់សារព័ត៌មាន? ៥) តើអ្នកគិតថា អ្នកមានសេរីភាពកម្រិតណាក្នុងការបញ្ចេញមតិ នៅក្នុងកម្មវិធីទូរទស្សន៍? ៦) តើអ្នកគិតថា អ្នកមានសេរីភាពកម្រិតណាក្នុងការបញ្ចេញមតិ នៅក្នុងកម្មវិធីវិទ្យុ? ៧) តើញឹកញាប់ប៉ុណ្ណាដែរ ដែលអ្នកមិនបាននិយាយចំពោះអ្វីដែលចង់និយាយជាសាធារណៈឬតាមអនឡាញ ដោយហេតុថាភ័យខ្លាចមានការសងសឹកណាមួយ?

**៤៦%** នៃអ្នកឆ្លើយតបសរុប ដែលបានឆ្លើយថា ពួកគេគិតថា *"មានសេរីភាពខ្លាំងណាស់"* ឬ *"មានសេរីភាពខ្លះដែរ"* ចំពោះ៦សំណួរដំបូង និងអ្នកដែលឆ្លើយតបសំណួរទី៧ថា "កម្រណាស់" ឬ "មិនដែលសោះ" ។ ដូច្នេះអាចសន្និដ្ឋានបានថា មនុស្សតិចជាងម្នាក់ក្នុងចំណោមមនុស្សពីរនាក់នៅក្នុងប្រទេសកម្ពុជាមានសេរីភាពក្នុងការបញ្ចេញមតិ។

*តួលេខទី៣៤៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថា មានសេរីភាពក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ*




*តួលេខទី៣៥៖ ភាគរយនៃអ្នកឆ្លើយតបដែលឆ្លើយថា មានសេរីភាពក្នុងការនិយាយគ្រប់ប្រធានបទទាំងអស់នៅលើបណ្តាញសង្គម*




បន្ទាប់ពីមានការធ្លាក់ជាបន្តបន្ទាប់ក្នុងរយៈពេលជាច្រើនឆ្នាំទាំងចំនួននៃអ្នកឆ្លើយតបដែលបង្ហាញថា ពួកគេមានអារម្មណ៍ថា មានសេរីភាពក្នុងការនិយាយដោយបើកចំហគ្រប់ប្រធានបទនៅទីសាធារណៈ (តួលេខទី៣៤) និងចំនួនអ្នកឆ្លើយតបដែលនិយាយថា ពួកគេមានអារម្មណ៍ថាមានសេរីភាពក្នុងការនិយាយដោយបើកចំហគ្រប់ប្រធានបទនៅលើបណ្តាញសង្គម (តួលេខទី៣៥) មានការកើនឡើងនៅឆ្នាំទី៦ ។[128]

[128] ទិន្នន័យនៅក្នុងតួលេខទី៥ និងតួលេខទី៦ រួមមានចំនួនអ្នកឆ្លើយតបដែលបានរាយការណ៍ថា *"មានសេរីភាពខ្លាំងណាស់"* ឬ *"មានសេរីភាពខ្លះដែរ"* ក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ ឬនៅលើបណ្តាញសង្គម។

*តួលេខទី៣៦៖ ភាគរយនៃអ្នកឆ្លើយតបដែលបានរាយការណ៍មិននិយាយនូវអ្វីដែលអ្នកចង់និយាយជាសាធារណៈ ឬតាមអ៊ីនធឺណិត ដោយសារខ្លាចមានការសងសឹក*




ខណៈដែលមានការកើនឡើងគួរឱ្យចាប់អារម្មណ៍បែបនេះក៏ដោយ ក៏គួរកត់សម្គាល់ដែរថា ចំនួនអ្នកដែលបានរាយការណ៍ អំពីការរឹតត្បិតខ្លួនឯងក្នុងការបញ្ចេញមតិ ដោយសារខ្លាចមានការសងសឹក មានការកើនឡើងពីឆ្នាំទី៥ ដល់ឆ្នាំទី៦ ដែលនេះនៅតែមានកម្រិតខ្ពស់ខ្លាំងនៅឡើយ។[129] នេះអាចបង្ហាញឱ្យឃើញថា ទោះបីជាសាធារណជនមានអារម្មណ៍ថា មានសេរីភាពក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ ឬនៅលើបណ្តាញសង្គមក៏ដោយ ក៏ពួកគេកាន់តែមានការប្រុងប្រយ័ត្នខ្លាំងឡើងចំពោះអ្វីដែលពួកគេនិយាយ។

## ៣.៣.២. សេរីភាពខាងការជួបប្រជុំ

ការស្ទង់មតិជាសាធារណៈនៅឆ្នាំទី៦ មានសំណួរចំនួនពីរបានសួរទៅកាន់អ្នកឆ្លើយតបទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ ៖ ១) តើអ្នកយល់ថា អ្នកមានសេរីភាពកម្រិតណាក្នុងការប្រមូលផ្តុំដោយសន្តិវិធី? ២) តើអ្នកយល់ថា អ្នកមានសេរីភាពក្នុងការធ្វើកូដកម្ម និង/ឬបាតុកម្មដោយសន្តិវិធីប្រឆាំងនឹងនិយោជករបស់អ្នក?

**៣៦%**

អ្នកឆ្លើយតបសរុបចំនួន ៣៦% ដែលបានឆ្លើយថា ពួកគេមានអារម្មណ៍ថា "មានសេរីភាពខ្លាំងណាស់" ឬ "មានសេរីភាពខ្លះដែរ" មកកាន់សំណួរទាំងពីរនេះ ។ នេះបង្ហាញថា បីភាគនៃសាធារណជនមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំរបស់ខ្លួន។

ភាគរយនៃអ្នកឆ្លើយតបដែលបានរាយការណ៍ថា ពួកគេមានអារម្មណ៍ថាមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីក្នុងឆ្នាំទី៦ មានការកើនឡើង បើប្រៀបធៀបនឹងឆ្នាំទី៥។ នេះបង្ហាញឱ្យឃើញថា សាធារណជនមិនត្រូវបានរារាំងបន្ថែមទៀតក្នុងការជួបជុំដោយសន្តិវិធីទេ ទោះបីជាមានការចាប់




*តួលេខទី៣៧៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថា មានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី*

[129] ទិន្នន័យនៅក្នុងក្រាហ្វិកនេះ រួមមានចំនួននៃអ្នកឆ្លើយតបដែលបានរាយការណ៍ថា *"ជានិច្ចកាល"* *"ជាប្រចាំ"* ឬ *"នៅពេលខ្លះ"* មិនបាននិយាយអ្វីដែលពួកគេចង់បានជាសាធារណៈ ឬតាមប្រព័ន្ធអ៊ីនធឺណិត ដោយសារខ្លាចមានការសងសឹក។ សំណួរនេះមិនបានសួរក្នុងការស្ទង់មតិឆ្នាំទី១ ឆ្នាំទី២ ឆ្នាំទី៣ និងឆ្នាំទី៤ នោះទេ។

ខ្លួនមនុស្សជាច្រើននាក់នៅឆ្នាំទី៥ក្នុងអំឡុងពេលតវ៉ាទាមទារឱ្យដោះលែងលោក រ៉ុង ឈុន ពីពន្ធនាគារក៏ដោយ។

ភាគរយនៃអ្នកឆ្លើយតបដែលមានអារម្មណ៍ *"មានសេរីភាពខ្លាំងណាស់"* ក្នុងការជួបប្រជុំដោយសន្តិវិធី បន្ទាប់ពីបានធ្លាក់ចុះជាលំដាប់ពីឆ្នាំទី២ ដល់ឆ្នាំទី៥ បានកើនឡើងនៅឆ្នាំទី៦ ដែលជាភាគរយខ្ពស់បំផុតទីពីរចាប់តាំងពីដំណើរការគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។ ទោះបីជាមានការកើនឡើងគួរឱ្យកត់សម្គាល់បែបនេះនូវចំនួនភាគរយនៃអ្នកដែលមានអារម្មណ៍ថា *"មានសេរីភាពខ្លាំងណាស់"* ក្នុងការជួបប្រជុំដោយសន្តិវិធីយ៉ាងណាក៏ដោយ ក៏មានតែ ១៥% នៃអ្នកដែលបានស្ទង់មតិប៉ុណ្ណោះ ដែលយល់បែបនេះ។

ក្នុងអំឡុងពេលប្រាំមួយឆ្នាំចុងក្រោយនេះ ជាមធ្យមមានមនុស្ស ៤៣% នៅទូទាំងរាជធានី-ខេត្តទាំងអស់ បានរាយការណ៍ថា មានអារម្មណ៍ថាមិនមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនោះទេ។[130] នៅខេត្តមួយចំនួន ដូចជាខេត្តពោធិ៍សាត់ ស្វាយរៀង បន្ទាយមានជ័យ និងតាកែវ បានបង្ហាញនូវភាគរយខ្ពស់ជាងគេ។ នៅរាជធានី-ខេត្តផ្សេងទៀត ដូចជាខេត្តក្រចេះ មណ្ឌលគិរី និងឧត្តរមានជ័យ មានភាគរយទាបជាងនេះ។




*តួលេខទី៣៨៖ ភាគរយនៃអ្នកដែលបានរាយការណ៍ថា មានអារម្មណ៍ថា មិនមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីពីឆ្នាំទី២ ដល់ឆ្នាំទី៦ ដោយបែងចែកតាមរាជធានី-ខេត្ត*

នៅរាជធានីភ្នំពេញ ចំនួនអ្នកដែលបានរាយការណ៍ថា មិនមានអារម្មណ៍ថា មានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីគឺទាបជាងមធ្យមភាគទូទាំងប្រទេសបន្តិចត្រឹម ៤០% ដែលបង្ហាញថា វត្តមាននៃកងកម្លាំងច្រើននៅទីប្រជុំជន គឺមិនមានផលប៉ះពាល់ខ្លាំងដល់ការយល់ឃើញរបស់សាធារណជនថា មិនមានសេរីភាពក្នុងការជួបប្រជុំនោះទេ។

---

[130] ទិន្នន័យនៅក្នុងក្រាហ្វិកនេះ រួមមានចំនួននៃអ្នកឆ្លើយតបដែលបានរាយការណ៍ថា មានអារម្មណ៍ *"មិនមានសេរីភាពទាល់តែសោះ"* និង *"មានសេរីភាពតិចតួច"* ក្នុងការជួបប្រជុំដោយសន្តិវិធី។

### ៣.២.៣. សេរីភាពខាងសមាគម

ការស្ទង់មតិជាសាធារណៈនៅឆ្នាំទី៦ មានសំណួរចំនួន ៦ បានសួរទៅកាន់អ្នកឆ្លើយតប ទាក់ទងនឹងសេរីភាពខាងសមាគម ១) តើអ្នកយល់ថា អ្នកមានសេរីភាពកម្រិតណាក្នុងការចូលរួមក្នុងក្រុមស្របច្បាប់ណាមួយ? ២) តើអ្នកយល់ថា អ្នកមានសេរីភាពកម្រិតណាក្នុងការបង្កើតក្រុមណាមួយ សម្រាប់គោលបំណងស្របច្បាប់? ៣) ប្រសិនបើអ្នកជាផ្នែកមួយនៃសមាគម តើអ្នកយល់ថា អ្នកមានសេរីភាពកម្រិតណាក្នុងការចាកចេញពីក្រុមនោះ? ៤) ប្រសិនបើអ្នកធ្វើការឱ្យនិយោជក តើអ្នកយល់ថា អ្នកមានសេរីភាពកម្រិតណាក្នុងការចូលរួមជាមួយសហជីព? ៥) ប្រសិនបើអ្នកជាផ្នែកមួយនៃសហជីព តើអ្នកមានសេរីភាពកម្រិតណាក្នុងការចាកចេញពីសហជីពនោះ? ៦) តើអ្នកយល់ថា អ្នកមានសេរីភាពកម្រិតណាក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ?

៤៣%

មានអ្នកឆ្លើយតបសរុបចំនួន ៤៣% បានឆ្លើយថា ពួកគេមានអារម្មណ៍ថា *"មានសេរីភាពខ្លាំងណាស់"* ឬ *"មានសេរីភាពខ្លះដែរ"* ចំពោះសំណួរទាំង៦នេះ ដែលបង្ហាញឱ្យឃើញពីបរិយាកាសដ៏លំបាកសម្រាប់ការអនុវត្តសេរីភាពខាងសមាគម។

*តួលេខទី៣៩៖ ភាគរយនៃអ្នកឆ្លើយតបដែលមានអារម្មណ៍ថា មានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ*




*តួលេខទី៤០៖ ភាគរយនៃអ្នកឆ្លើយតបដែលមានអារម្មណ៍ថា មិនមានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ*




ជាលើកទី១ហើយក្នុងអំឡុងពេល ៤ ឆ្នាំ ដែលចំនួននៃអ្នកឆ្លើយតបបង្ហាញថា ពួកគេមានអារម្មណ៍ថា មានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយមានការកើនឡើង (តួលេខទី៣៩) ។[131] ការកើនឡើងនេះ ស្របពេលគ្នាជាមួយនឹងការខិតចូលមកដល់នៃការបោះឆ្នោត និងការប្រមូលផ្តុំរបស់គណបក្សនយោបាយជាបន្តបន្ទាប់។ ក្នុងឆ្នាំទី៦ ក៏បានឃើញមានការថយចុះនូវចំនួនភាគរយនៃអ្នកឆ្លើយតបដែលឆ្លើយថា ពួកគេមានអារម្មណ៍ថា *"មិនមានសេរីភាពទាល់តែសោះ"* ក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ ជាកម្រិតដ៏ខ្ពស់មួយក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះសម្រាប់សង្គមប្រជាធិបតេយ្យ (តួលេខទី៤០)។ ទោះបីជាមានការធ្លាក់ចុះបែបនេះក៏ដោយ ក៏មួយភាគបួននៃសាធារណជន នៅតែមានអារម្មណ៍ថា *"មិនមានសេរីភាពទាល់តែ*

[131] ទិន្នន័យនៅក្នុងក្រាហ្វិកនេះ រួមបញ្ចូលចំនួនអ្នកឆ្លើយសំណួរដែលបានរាយការណ៍ថា មានអារម្មណ៍ថា *"មានសេរីភាពខ្លាំង"* និង *"មានសេរីភាពតិចតួច"* ក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ។

*សោះ"* ក្នុងការចូលរួមក្នុងសកម្មភាពនយោបាយដដែល ដែលចំនួនភាគរយខ្ពស់នេះកើតនៅក្នុងអំឡុងពេលនៃការបោះឆ្នោតឃុំសង្កាត់ដែលនឹងជិតមកដល់នៅឆ្នាំ២០២២ និងការបោះឆ្នោតជាតិនៅឆ្នាំ២០២៣ ខាងមុខ។

*តួលេខទី៤១៖ ភាគរយនៃអ្នកឆ្លើយតបដែលមានអារម្មណ៍ថា មានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយដោយបែងចែកតាមភេទ*




បន្ទាប់ពីបានធ្លាក់ចុះអស់រយៈពេលបួនឆ្នាំកន្លងមកចំនួនអ្នកឆ្លើយតបជាស្ត្រីដែលបានរាយការណ៍ថាមានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយស្ទើរតែកើនឡើងទ្វេដងពីឆ្នាំទី៥ ដល់ឆ្នាំទី៦។ នេះជារឿងមួយគួរឱ្យកត់សម្គាល់ ដោយសារតែកន្លងមកស្ត្រីមានការចូលរួមនយោបាយតិចតួចដែលបណ្តាលមកពីតួនាទីយេនឌ័រដែលមាននៅក្នុងប្រពៃណីនិងជំនឿវប្បធម៌នៅក្នុងសង្គមកម្ពុជា។ ការកើនឡើងនេះអាចបណ្តាលមកពីការរៀបចំការបោះឆ្នោតនាពេលខាងមុខ ដែលអាចជាកត្តាជំរុញដល់ស្ត្រី។

ទោះបីជាមិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់តាមរយៈការសង្កេតពីការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាន ក្នុងឆ្នាំទី ៦ ក៏ដោយ ប៉ុន្តែមានអ្នកឆ្លើយសំណួរតិចតួចណាស់ដែលបានឆ្លើយថា ពួកគេដឹង "ច្បាស់ណាស់" ពីអត្ថន័យនៃសេរីភាពនីមួយៗ ដែលនេះបង្ហាញថា បុគ្គលម្នាក់ៗមិនបានត្រៀមខ្លួនគ្រប់គ្រាន់ដើម្បីទាមទារសិទ្ធិរបស់ខ្លួននោះទេ។ ដូចគ្នានេះដែរ នៅមានចំណុចដែលត្រូវធ្វើឱ្យកាន់តែប្រសើរឡើងទាក់ទងនឹងចំណេះដឹងរបស់សាធារណជនអំពីក្របខ័ណ្ឌច្បាប់ទាក់ទងនឹងសេរីភាពមូលដ្ឋាន ដែលក្នុងស្ថានភាពបច្ចុប្បន្ន វាបានរាំងដល់ការអនុវត្តពេញលេញនូវសេរីភាពមូលដ្ឋាននេះ។ យោងតាមរបកគំហើញទាំងនេះបង្ហាញឱ្យឃើញថា មានការចាំបាច់ត្រូវអប់រំសាធារណជន ឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីសេរីភាពមូលដ្ឋាន និងដែនកំណត់របស់ច្បាប់មកលើសិទ្ធិទាំងនេះ។ ទិន្នន័យពីចំណុចគន្លឹះទី៣ ក៏បង្ហាញផងដែរថា ចំនួនភាគរយនៃអ្នកដែលមានអារម្មណ៍ថា មានសេរីភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេកំពុងតែមានការកើនឡើង។

## ៤. ចំណុចគន្លឹះទី៤៖ តើអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាលកម្ពុជាដែរឬទេ?[132]

ចំណុចគន្លឹះទី៤ ពិនិត្យមើលពីវិសាលភាពដែលរាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលអាចធ្វើការរួមគ្នាជាភាគីពាក់ព័ន្ធដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ទិន្នន័យនៅក្នុងចំណុចគន្លឹះទី៤ បានយកចេញពីការស្ទង់មតិអង្គការសង្គមស៊ីវិល និងសហជីព ដែលជាការស្ទង់មតិប្រចាំឆ្នាំធ្វើឡើងដើម្បីស្វែងយល់ពីការយល់ឃើញ និងបទពិសោធន៍របស់ថ្នាក់ដឹកនាំទាំងនោះអំពីលទ្ធភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ នៅក្នុងឆ្នាំទី៦នេះ អ្នកឆ្លើយតបនឹងការស្ទង់មតិសរុបមានចំនួន១៧១នាក់។

**របកគំហើញសំខាន់ៗ៖** ស្របជាមួយនឹងនិន្នាការដែលបានអង្កេតក្នុងឆ្នាំកន្លងមក ទិន្នន័យនៅចំណុចគន្លឹះទី៤ នេះបានបង្ហាញថាអង្គការសង្គមស៊ីវិលនិងសហជីពនៅតែមិនត្រូវបានរាជរដ្ឋាភិបាលមើលឃើញថាជាដៃគូនិងភាគីពាក់ព័ន្ធសំខាន់នៅឡើយ។ កិច្ចសហការរវាងរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលនៅតែមិនកើតឡើងជាញឹកញាប់នោះទេ។ នៅក្នុងនោះក៏មិនសូវមានការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងសហជីពក្នុងការសម្រេចចិត្តនិងដំណើរការតាក់តែងច្បាប់ ហើយមានតែថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពមួយចំនួនតូចដែលបានដឹងអំពីការអញ្ជើញរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមពិគ្រោះយោបល់ កិច្ចពិភាក្សាឬជាគណៈកម្មាធិការ។ ការដឹងលឺនិងការទទួលបានអំពីឱកាសទទួលបានហិរញ្ញវត្ថុនៅមានកម្រិតទាបនៅឡើយ។

### ៤.១ ថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីពមិនត្រូវបានរដ្ឋាភិបាលមើលឃើញថាជាដៃគូដែលមានសមត្ថភាព ដែលនាំឱ្យកិច្ចសហប្រតិបត្តិការមានកម្រិតទាប

*តួលេខទី៤២៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពយល់ថាត្រូវបានទទួលស្គាល់ជាដៃគូអភិវឌ្ឍន៍ស្របច្បាប់និងជាដៃគូអភិវឌ្ឍន៍ពេញសមត្ថភាព*




[132] ទិន្នន័យចំណុចគន្លឹះទី៤ បានមកពីការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលសហជីពនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានដែលបានធ្វើក្នុងខែធ្នូ ឆ្នាំ២០១៦ (ឆ្នាំទី១) ខែធ្នូ ឆ្នាំ២០១៧ (ឆ្នាំទី២) ខែមករា ឆ្នាំ២០១៩ (ឆ្នាំទី៣) ខែមករា ឆ្នាំ២០២០ (ឆ្នាំទី៤) ខែតុលា ឆ្នាំ២០២០ (ឆ្នាំទី៥)និង ខែកញ្ញា ឆ្នាំ២០២១(ឆ្នាំទី៦)។

ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពយល់ថារដ្ឋាភិបាលបានទទួលស្គាល់ខ្លួនជាងពេលមុនថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់[133]និងពេញសមត្ថភាព[134]។ ទោះជាបែបបនេះក្តី ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលជឿជាក់ថាស្ថាប័នរបស់ខ្លួនត្រូវបានទទួលស្គាល់ពីសំណាក់រដ្ឋាភិបាលថាមានសមត្ថភាព មានចំនួនតិចជាងភាគរយនៃថ្នាក់ដឹកនាំដែលជឿជាក់ថាស្ថាប័នរបស់ខ្លួនត្រូវបានរដ្ឋាភិបាលមើលឃើញថាជាដៃគូស្របច្បាប់។ លទ្ធផលទាំងនេះហាក់ដូចជាបង្ហាញថាថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពទាំងនោះមិនត្រូវបានរដ្ឋាភិបាលមើលឃើញថាជាដៃគូមានដ៏មានសមត្ថភាពពិតប្រាកដនៅឡើយទេ។

*តួលេខទី៤៣៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលបានសហការក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាល*




នេះជាឧទាហរណ៍អំពីការសហការដែលមានកម្រិតទាបទាំងផ្លូវការនិងក្រៅផ្លូវការរវាងរាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលនិងសហជីពដែលគម្រោងបានកត់ត្រា។ ការលើកឡើងអំពីកិច្ចសហការគឺមិនមានលើសពី ៥០% ឡើយ[135]។ របកគំហើញទាំងនេះហាក់ដូចជាបង្ហាញអំពីឱកាសតិចតួចក្នុងកិច្ចសហការរវាងរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលនិងសហជីព ដែលនេះបណ្តាលឱ្យជំនាញ ចំណេះដឹង និងឯកទេសរបស់សង្គមស៊ីវិលមិនត្រូវបានរដ្ឋាភិបាលទាញយកជាសក្តានុពលឡើយ។

សម្រាប់សហជីព កម្រិតនៃកិច្ចសហការរបស់សហជីពមានតិចតួចជាងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនៅក្នុងឆ្នាំទី៦នេះ។ ភាពខុសគ្នានេះលេចឡើងកាន់តែច្បាស់នៅពេលដែលពិនិត្យមើលពីកម្រិតនៃកិច្ចសហប្រតិបត្តិការក្រៅផ្លូវការ(តួលេខទី៤៤)[136]។

---

133 ការដែលបានគេយល់ឃើញថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់នោះគឺត្រូវបានទទួលស្គាល់ថាជាអង្គភាពដែលមានសុពលភាពផ្លូវការ និងស្របច្បាប់។

134 ការដែលត្រូវបានគេយល់ឃើញថាជាដៃគូអភិវឌ្ឍន៍ពេញសមត្ថភាពនោះគឺត្រូវបានឱ្យតម្លៃថាមានជំនាញ ចំណេះដឹង និងសមត្ថភាពពាក់ព័ន្ធដើម្បីក្លាយជាដៃគូអភិវឌ្ឍន៍ដ៏មានប្រយោជន៍ដល់រាជរដ្ឋាភិបាល។

135 ទិន្នន័យបង្ហាញក្នុងក្រាហ្វិកនេះបានរួមបញ្ចូលចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលបានរាយការណ៍ថា "ញឹកញាប់ណាស់" "ញឹកញាប់" ឬ "ពេលខ្លះ" បានសហការក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាលកាលពី១ឆ្នាំមុន។ សំនួរនេះមិនបានដាក់បញ្ចូលក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពឆ្នាំទី១នោះទេ។

136 ទិន្នន័យបង្ហាញក្នុងក្រាហ្វិកនេះបានរួមបញ្ចូលចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលបានរាយការណ៍ថា "ញឹកញាប់ណាស់" "ញឹកញាប់" ឬ "ពេលខ្លះ" បានសហការក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាលកាលពី១ឆ្នាំមុន ដោយបែងចែកតាមប្រភេទអ្នកឆ្លើយតប។ ភាគរយដែលមានក្នុងក្រាហ្វិកឆ្នាំទី៤ និងឆ្នាំទី៥ ខុសប្លែកពីភាគរយដូចមានបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំទី៤ និងឆ្នាំទី៥ ដោយសារការគណនាខុស។ គម្រោងក៏បានកែតម្រូវចំណុចខុសឆ្គងនេះរួចហើយដែរ។

*តួលេខទី៤៤៖ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ថាបានសហការក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាល*




*តួលេខទី៤៥៖ ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ថាបានសហការផ្លូវការជាមួយរាជរដ្ឋាភិបាល*




បើពិនិត្យមើលអំពីកម្រិតនៃកិច្ចសហការជាផ្លូវការជាមួយរាជរដ្ឋាភិបាលក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ[137] ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលដែលមានស្ថាប័នធ្វើការងារស្នូលលើវិស័យសិទ្ធិការងារបានរាយការណ៍អំពីការសហការជាដៃគូផ្លូវការជាមួយរាជរដ្ឋាភិបាលមានកម្រិតទាបបំផុត (១៨%) បន្ទាប់មកគឺថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យសិទ្ធិមនុស្ស (២៩%)។ លទ្ធផលទាំងនេះបង្ហាញថាកិច្ចសហការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលធ្វើការលើវិស័យដែលរាជរដ្ឋាភិបាលចាត់ទុកថាជារឿងរសើបមិនត្រូវបានលើកទឹកចិត្តនោះទេ។

*តួលេខទី៤៦៖ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលដែលរាយការណ៍ថាបានសហការជាដៃគូជាមួយរាជរដ្ឋាភិបាលចន្លោះឆ្នាំទី២ និងឆ្នាំទី៦ ដោយបែងចែកតាមវិស័យការងារស្នូល*




137 សំណួរនេះមិនបានដាក់បញ្ចូលក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពឆ្នាំទី១នោះទេ។

## ៤.២ ជំនាញ និងធាតុចូលរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលជាដៃគូដ៏សំខាន់ ពុំសូវបានបញ្ចូលនោះទេ

នៅក្នុងឆ្នាំទី៦ នេះ មានអ្នកឆ្លើយតប៥៤% ដែលជាភាគរយខ្ពស់បំផុតទី២ចាប់តាំងពីគម្រោងបានចាប់ផ្តើម ដោយបានរាយការណ៍ថាកាលពីឆ្នាំមុនពួកគេមិនបានពាក់ព័ន្ធនៅក្នុងដំណើរការតាក់តែងច្បាប់ជាមួយរាជរដ្ឋាភិបាលនោះទេ។ របកគំហើញនេះបង្ហាញថាដំណើរការនេះកំពុងចាកឆ្ងាយពីដំណើរការដែលមានការចូលរួមពីពហុភាគី។

*តួលេខទី៤៧៖ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ថា"មិនធ្លាប់" ចូលរួមនៅក្នុងសេចក្តីសម្រេចចិត្តឬដំណើរការតាក់តែងច្បាប់ជាមួយរដ្ឋាភិបាលកាលពីឆ្នាំមុន*




*តួលេខទី៤៨៖ ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលបានដឹងពីឱកាសចូលរួមពិគ្រោះយោបល់ គណៈវិនិច្ឆ័យ ឬគណៈកម្មាធិការ*




នៅក្នុងឆ្នាំទី៦ គម្រោងបានកត់ត្រានូវភាគរយទាបបំផុតនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ថាខ្លួនបានដឹងអំពីឱកាសចូលរួមក្នុងការពិគ្រោះយោបល់ កិច្ចពិភាក្សាឬគណៈកម្មាធិការ[138] ដែលជាឧទាហរណ៍មួយតម្រូវឱ្យរាជរដ្ឋាភិបាលគួរផ្សព្វផ្សាយឲ្យកាន់តែប្រសើរថែមទៀតអំពីឱកាសនោះ។ ឱកាសទាំងនេះអនុញ្ញាតឱ្យមានទស្សនវិស័យផ្សេងៗមកបំពេញបន្ថែមដល់រាជរដ្ឋាភិបាល ដែលនាំការពិគ្រោះយោបល់ កិច្ចពិភាក្សាឬគណៈកម្មាធិការទាំងនោះនឹងមានសមាសភាពចម្រុះបែប ដូចនេះលទ្ធផលនឹងទទួលបាននូវធាតុចូលកាន់តែច្រើនថែមទៀតផងដែរ។

## ៤.៣ ឱកាសទទួលបានហិរញ្ញប្បទានរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពមិនត្រូវបានផ្សព្វផ្សាយនិងពិបាកស្វែងរក

ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលដឹងអំពីឱកាសទទួលបានមូលនិធិពីរាជរដ្ឋាភិបាលសម្រាប់សមាគមដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅតែមានភាគរយដូចគ្នានៅឆ្នាំទី៥ និងឆ្នាំទី៦[139]។

*តួលេខទី៤៩៖ ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដឹងអំពីព័ត៌មានឱកាសទទួលមូលនិធិពីរាជរដ្ឋាភិបាល*




នៅឆ្នាំទី៦ កម្រិតដឹងឮរបស់អង្គការសង្គម ស៊ីវិលអំពីឱកាសទទួលហិរញ្ញប្បទានមានភាពខុសគ្នា និងមានកម្រិតទាបនៅឡើយ អាស្រ័យទៅលើវិស័យការងារស្នូលរបស់ខ្លួន។ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យជាក់លាក់ណាមួយដូចជា កាត់បន្ថយភាពក្រីក្រ ចំណាកស្រុក និងសិទ្ធិជនភៀសខ្លួន និង

[138] សំនួរនេះមិនបានដាក់បញ្ចូលក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពឆ្នាំទី១នោះទេ។

[139] សំនួរនេះមិនបានដាក់បញ្ចូលក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពឆ្នាំទី១នោះទេ។

ការអភិវឌ្ឍជនបទបានរាយការណ៍អំពីការបានដឹងឮពីឱកាសទទួលបានហិរញ្ញប្បទានដែលសាកសមសម្រាប់ស្ថាប័នខ្លួន ច្រើនជាងថ្នាក់ដឹកនាំអង្គការសង្គម ស៊ីវិលដទៃទៀត។

*តួលេខទី៥០៖ ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលបានដឹងពីឱកាសទទួលបានហិរញ្ញប្បទានពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំទី៦ដោយបែងចែកតាមវិស័យការងារស្នូល*




ការដឹងឮកម្រិតទាបអំពីការទទួលបានហិរញ្ញប្បទានបង្ហាញឱ្យឃើញអំពីភាពចាំបាច់ដែលរដ្ឋាភិបាលត្រូវបង្កើនពីការផ្សព្វផ្សាយអំពីព័ត៌មាននៃឱកាសហិរញ្ញប្បទានទាំងនោះពីព្រោះថា ការដឹងអំពីព័ត៌មានទទួលបានហិរញ្ញប្បទានមានកម្រិតទាបនេះក៏នាំឱ្យមានអត្រាចូលរួមតិចតួច ហើយអត្រាជោគជ័យក៏រឹតតែទាបផងដែរ។ នេះក៏ឆ្លុះបញ្ចាំងអំពីភាគរយខ្ពស់ដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលបានរាយការណ៍ថាមិនអាចទទួលបានហិរញ្ញប្បទានពីរាជរដ្ឋាភិបាលសម្រាប់ការកសាងសមត្ថភាពក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ[140]។ មូលហេតុពីក្រោយដែលអង្គការសង្គមស៊ីវិល និងសហជីពមិនមានសមត្ថភាពក្នុងការទទួលបានហិរញ្ញប្បទានបែបនេះគឺនៅមិនទាន់ដឹងនៅឡើយទេ។ អង្គការសង្គមស៊ីវិលនិងសហជីពត្រូវការគាំទ្រដើម្បីកសាងសមត្ថភាពរបស់ខ្លួន ការគាំទ្រមិនគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពដូច្នេះរារាំងដល់ការងារនិងការរីកចម្រើនរបស់ពួកគេ ដែលជាហេតុរាំងផលប្រយោជន៍ដែលសង្គមស៊ីវិលចូលរួមចំណែក។

*តួលេខទី៥១៖ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ថាមិនអាចទទួលបានហិរញ្ញប្បទានពីរាជរដ្ឋាភិបាលដើម្បីកសាងសមត្ថភាព*




ទិន្នន័យពីចំណុចគន្លឹះទី៤ បង្ហាញពីកង្វះខាតរបស់រាជរដ្ឋាភិបាលក្នុងការទទួលស្គាល់សង្គមស៊ីវិល និងសហជីពថាជាដៃគូដ៏មានទំនុកចិត្ត ជំនាញ និងជាអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ការសហការរវាងរាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល និងសហជីព នៅតែបន្តរួមតូចដែលបង្ហាញថាជំនាញនិងចំណេះរបស់អង្គការទាំងនោះមិនបានរដ្ឋាភិបាលប្រើជាប្រយោជន៍ឱ្យបានពេញលេញនៅឡើយ។ កង្វះខាតឱកាសសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងសហជីពក្នុងដំណើរការជាមួយរាជរដ្ឋាភិបាលមានន័យថាដំណើរនេះមិនសូវមានបរិយាបន្ន និងភាពចម្រុះបែប ដែលនាំឱ្យរាជរដ្ឋាភិបាលមិនទទួលបានធាតុចូលសំខាន់ៗ។ ភាពស្ទាក់ស្ទើររបស់រាជរដ្ឋាភិបាលនៅតែបន្តមានក្នុងការទទួលស្គាល់សង្គមស៊ីវិលថាជា ដៃគូដ៏សំខាន់ធ្វើឱ្យមានការរីកចម្រើនប្រកបដោយនិរន្តរភាពនិងវិជ្ជមាន ដែលនេះជាការរារាំងយ៉ាងខ្លាំងដល់ការអភិវឌ្ឍប្រទេសកម្ពុជា។

140 សំនួរនេះមិនបានដាក់បញ្ចូលក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពឆ្នាំទី១នោះទេ។

# សេចក្តីសន្និដ្ឋាន

នៅក្នុងឆ្នាំទី៦នេះ លម្ហក្នុងការអនុវត្តសេរីភាពមូលដ្ឋាននៅតែរងការរឹតត្បិត ហើយលម្ហនៃការចូលរួមរបស់ពលរដ្ឋនៅតែបន្តធ្លាក់ចុះ។ ទោះបីជារដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការគោរព ការពារ និងលើកកម្ពស់សេរីភាពខាងសមាគម ការបញ្ចេញមតិ និងការជួបប្រជុំក្តី គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រានូវករណីនៃការរឹតត្បិត និងការរំលោភបំពានលើសេរីភាពមូលដ្ឋានចំនួនជាង ៣០០ ករណី នៅគ្រប់ខេត្តក្រុងនៃប្រទេសកម្ពុជា។

ការអនុម័ត*អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ* ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងសង្ឃប្រកាសបានរឹតត្បិតថ្មីថែមទៀតលើលទ្ធភាពរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ ច្បាប់ និងបទប្បញ្ញត្តិទាំងនេះភ្ជាប់ជាមួយក្របខ័ណ្ឌច្បាប់ជាធរមានដែលរឹតត្បិតសេរីភាពមូលដ្ឋាននានា និងមិនអនុលោមជាមួយច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

នៅក្នុងឆ្នាំទី៦នេះ សេរីភាពខាងសមាគម ជាសេរីភាពមូលដ្ឋានមួយដែលរងការរឹតត្បិតធ្ងន់ធ្ងរជាងគេ។ អង្គការសង្គមស៊ីវិល សហជីព និងគណបក្សនយោបាយនានារងការរឹតត្បិតពីសំណាក់រដ្ឋាភិបាល និងភាគីទីបីដែលបង្កើតនូវបរិយាកាសមិនអំណោយផលដល់ការអនុវត្តសេរីភាពខាងសមាគម។ ចំណុចនេះបង្ហាញនូវភាគរយទាបនៅក្នុងការស្ទង់មតិជាមួយសាធារណជនដោយមាន ៤៣% បានលើកឡើងថាមានសេរីភាពខាងការបង្កើតសមាគម។ ទោះបីជាសេរីភាពខាងការជួបប្រជុំទទួលបានការការពារច្រើននៅក្នុងឆ្នាំទី៦នេះក្តី ក៏មានត្រឹមតែ ៥៥% នៃសាធារណជន និង ៣៥% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពប៉ុណ្ណោះ បានលើកឡើងថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ។ អាជ្ញាធរបានប្រើកងកម្លាំងក្នុងចំនួនពុំសមាមាត្រ និងមិនច្បាស់លាស់មកលើការជួបប្រជុំ១៣% ដែលចំនួននេះកើនឡើងជាងនៅក្នុងឆ្នាំទី៥ មាន ១១%។ ចំណែកសេរីភាពខាងការបញ្ចេញមតិនៅលើបណ្តាញអ៊ីនធឺណិតរងការឃ្លាំមើល និងការបង្ក្រាបកាន់តែខ្លាំងឡើងៗ ដោយក្នុងចំណោមករណីបញ្ចេញមតិទាំងអស់ មាន៧៧% នៃករណីដែលទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិនៅលើអ៊ីនធឺណិត។ អត្រានៃការរឹតត្បិតខ្លួនឯងនៅតែស្ថិតក្នុងកម្រិតខ្ពស់ ដោយ ៥៩% ពីការស្ទង់មតិជាមួយសាធារណជន និង ៨៤% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានលើកឡើងថាពួកគេតែងតែដាក់កំហិតលើខ្លួនឯង។

ការយល់ដឹងស៊ីជម្រៅអំពីអត្ថន័យនៃសេរីភាពមូលដ្ឋានក្នុងចំណោមពលរដ្ឋនៅតែមានកម្រិត ដែលជាហេតុធ្វើឱ្យពួកគេមិនអាចអនុវត្តសិទ្ធិសេរីភាពឱ្យបានពេញលេញ។ បុគ្គលជាច្រើននៅតែជឿថាច្បាប់ដែលគ្របដណ្តប់ទៅលើសេរីភាពមូលដ្ឋានមានការរឹតត្បិតខ្លាំងជាងគោលបំណងពិតនៃច្បាប់ទាំងនោះទៅទៀត ដែលជាការរារាំងដល់ការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេឱ្យបានពេញលេញ។

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានក៏បានរកឃើញថា រដ្ឋាភិបាលនៅតែមានភាពស្ទាក់ស្ទើរក្នុងការទទួលស្គាល់អង្គការសង្គមស៊ីវិល និងសហជីពថាជាដៃគូសហការសំខាន់ដែលគួរឱ្យទុកចិត្ត ជាហេតុនាំឱ្យកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការសង្គស៊ីវិល/សហជីពនៅមានកម្រិតនៅឡើយ។ ដូច្នោះហើយអ្នកដែលមានជំនាញ និងមានសមត្ថភាពទាំងនេះមិនត្រូវបានប្រើប្រាស់សក្តានុភាពរបស់ខ្លួនឱ្យបានពេញលេញនោះទេ។

តាមរយៈការផ្តល់ទឡ្ហីករណ៍អំពីស្ថានភាពនៃសេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជា គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានមានបំណងផ្តល់នូវព័ត៌មានដែលជាមូលដ្ឋានគ្រឹះសម្រាប់ពិចារណា ពិភាក្សាក្នុងន័យស្ថាបនាពិតប្រាកដដែលអាចធ្វើឱ្យច្បាប់កម្ពុជាស្របជាមួយច្បាប់អន្តរជាតិ។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានស្នើឱ្យមានវិធានការដាក់លាក់ប្រកបដោយអត្ថន័យឆ្ពោះទៅរកការបង្កើតបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលធ្វើប្រតិបត្តិការ ដើម្បីឱ្យដំណើរការលទ្ធិប្រជាធិបតេយ្យប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា។

# ឧបសម្ព័ន្ធទី១ ៖ វិធីសាស្រ្ត និងការប្រមូលទិន្នន័យ

ឧបសម្ព័ន្ធនេះ បង្ហាញអំពីវិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ ដែលបានប្រើប្រាស់ដើម្បីប្រមូលនិងវិភាគទិន្នន័យរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។

## វិធីសាស្រ្ត

ក្រុមការងារគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានប្រើប្រាស់នូវឧបករណ៍តាមដានការឃ្លាំមើលផ្សេងៗដើម្បីឃ្លាំមើលស្ថានភាពសេរីភាពមូលដ្ឋាននេះ។ ទិន្នន័យទាំងនេះត្រូវបានប្រមូលចងក្រងរៀបចំជាប្រព័ន្ធ និងវាយតម្លៃយ៉ាងត្រឹមត្រូវស្របតាមគោលការណ៍នៃឧបករណ៍តាមដានការឃ្លាំមើល ដែលមានគោលបំណងផ្តល់នូវតុល្យភាព និងសត្យានុម័តជាក់លាក់មួយ សម្រាប់ត្រួតពិនិត្យតាមដានអំពីសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំនិងសរីភាពខាងការបញ្ចេញមតិ ("សេរីភាពមូលដ្ឋាន") នៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យនេះក៏ផ្តោតសំខាន់ទៅលើសង្គមស៊ីវិល (រួមមានសហជីពនិងសមាគមអ្នកធ្វើការក្រៅប្រព័ន្ធ) និងការចូលរួមរបស់ប្រជាពលរដ្ឋផងដែរ។

ឆ្នាំទី៦ របស់គម្រោងគឺរាប់ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ លទ្ធផលដែលបានពីការឃ្លាំមើលនេះត្រូវបានយកមកប្រៀបធៀប និងពិនិត្យឡើងវិញជារៀងរាល់ត្រីមាស៖ ត្រីមាសទី១ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១, ត្រីមាសទី២ ចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១, ត្រីមាសទី៣ ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១, និងត្រីមាសទី៤ ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

ឧបករណ៍តាមដានការឃ្លាំមើលនេះមានសូចនាករ ១៥២ ដែលឆ្លើយតបចំពោះចំណុចគន្លឹះចំនួន ៤[141]៖

**ចំណុចគន្លឹះទី១ ៖** ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិ

**ចំណុចគន្លឹះទី២ ៖** ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្តនិងប្រតិបត្តិតាមត្រឹមត្រូវ

**ចំណុចគន្លឹះទី៣ ៖** បុគ្គលយល់ដឹងអំពីសេរីភាពមូលដ្ឋាននិងសិទ្ធិដែលពាក់ព័ន្ធនិងយល់ថាខ្លួនអាចអនុវត្តសេរីភាពនេះដោយសេរី និង

**ចំណុចគន្លឹះទី៤ ៖** អង្គការសង្គមស៊ីវិលនិងសហជីពត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល។

---

[141] ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្ត្រ សូមមើល៖ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ 'គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបាយការណ៍ឆ្នាំទី៣'(ខែកក្កដា ឆ្នាំ២០១៩) ឧបសម្ព័ន្ធទី១ <https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=130&id=5>។

ឧបករណ៍តាមដានការឃ្លាំមើល បានគូសបញ្ជាក់អំពីសកម្មភាពសំខាន់ៗជាលម្អិតសម្រាប់ក្រុមការងារអនុវត្តផងដែរ។ ឧបករណ៍នេះបង្កើតនិយមន័យដើម្បីជានាទូវការអនុវត្តស៊ីសង្វាក់គ្នានូវគោលគំនិតជាគន្លឹះ ព្រមទាំងបង្ហាញយ៉ាងច្បាស់នូវជាតុទាំងឡាយនៃចំណុចគន្លឹះទាំង៤។ ឧបករណ៍តាមដានការឃ្លាំមើលនេះលម្អិតអំពីសូចនាករ និងមានតារាងវិភាគដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃនូវការផ្លាស់ប្តូរធៀបជាមួយជាតុនីមួយៗ និង ចំណុចគន្លឹះទាំងនោះ ក៏ដូចជាធ្វើការប្រៀបធៀបជាមួយប្រភពទិន្នន័យ បុគ្គលទទួលខុសត្រូវចំពោះការប្រមូលទិន្នន័យនិងភាពញឹកញាប់នៃការប្រមូលទិន្នន័យផងដែរ។[142]

## វិធីសាស្រ្តប្រមូលទិន្នន័យ

ក្រុមការងារអនុវត្តគម្រោងបានប្រើប្រាស់នូវវិធីសាស្រ្តប្រមូលទិន្នន័យចំនួន ៦ យ៉ាងដើម្បីវាស់វែងសូចនាករពាក់ព័ន្ធជាមួយជាតុនីមួយៗនៅក្រោមចំណុចគន្លឹះទាំងនោះ។




### ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ការតាមដានប្រព័ន្ធផ្សព្វផ្សាយផ្តោតលើការផ្សព្វផ្សាយព័ត៌មានអំពីសេរីភាពមូលដ្ឋាន។ វិធីសាស្រ្តនេះត្រូវបានប្រើជាពីរវិធី៖ ទីមួយប្រើដើម្បីប្រមូលទិន្នន័យ សម្រាប់សូចនាករដែលវាស់វែងការផ្លាស់ប្តូរ នៅក្នុងការអនុវត្តរបស់រដ្ឋាភិបាលឬការបកស្រាយច្បាប់ដែលជះឥទ្ធិពលដល់សេរីភាពមូលដ្ឋាន។ ទីពីរផ្តល់នូវមធ្យោបាយនៃការតាមដានចំនួន និងប្រភេទនៃហេតុការណ៍ដែលសេរីភាពមូលដ្ឋានត្រូវបានរំលោភឬរឹតត្បិត។ ក្រុមការងារគម្រោងបានអនុវត្តជាប្រចាំថ្ងៃក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

ភាគច្រើនជាសារព័ត៌មានក្នុងស្រុក និងប្រភពបណ្តាញផ្សព្វផ្សាយដទៃទៀតត្រូវបានតាមដានឃ្លាំមើលដើម្បីរកនូវអត្ថបទរឿងរ៉ាវ ផ្សេងៗដែលពាក់ព័ន្ធ ។[143]

ក្រុមការងាររបស់គម្រោងបានកំណត់និងត្រួតពិនិត្យទៅលើអត្ថបទរឿងដែលពាក់ព័ន្ធនានា ហើយបញ្ចូលព័ត៌មានសំខាន់ៗទាំងនោះចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ ប្រព័ន្ធទិន្នន័យនេះក៏បានធ្វើចំណាត់ថ្នាក់ អត្ថបទ

---

[142] សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្រ្តនៃឧបករណ៍តាមដានការឃ្លាំមើលអាចរកបានតាមការស្នើសុំ។

[143] ប្រភពព័ត៌មានរួមបញ្ចូល៖ កាសែតភ្នំពេញប៉ុស្តិ៍ (ខ្មែរ និងអង់គ្លេស) កាសែតខ្មែរថាមស៍ វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិ កាសែតដើមអម្ពិល វិទ្យុសំឡេងប្រជាធិបតេយ្យ (ខ្មែរ និងអង់គ្លេស) វិទ្យុសំឡេងសហរដ្ឋអាមេរិកវីអូអេ វិទ្យុវាយោ សារព័ត៌មានកោះសន្តិភាព កាសែតរស្មីកម្ពុជា កាសែតថ្មីថ្មី កាសែតកម្ពុជាថ្មី, សារព័ត៌មានហ្វ្រេសញូវ, សារព័ត៌មានដើមត្នោត, មជ្ឈមណ្ឌលព័ត៌មានស្រ្តីកម្ពុជា, កាសែតព្រៃនគរ, ស្ទឹហ្វ៍ញូវដេលី, TVFB, ខ្លីខ្លី, ស៊ីអ៊ីអិន, ខេមញូវ, ខេមបូចារ, Cambodia Peace Channel, ខេមបូណូមីស, ខេមបូឌៀននីស អង្រុត ខ្មែរណាស់ ញូវរ៉ូម ខេធីដេលី ខ្មែររីផត និងនគរវត្ត។ ចំណុតសំខាន់ដែលកំណត់នៅក្នុងវិធីសាស្រ្តនេះគឺការថយចុះចំនួនប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ ដែលការរាយការណ៍អាចមានភាពលំអៀង។ ប្រភពព័ត៌មានអន្តរជាតិរួមមាន៖ Al Jazeera, The Diplomat, UCA News, The Star and Reuters ។

រឿងនីមួយៗទៅតាមប្រភេទដែលឆ្លើយតបជាមួយសូចនាករនីមួយៗ និងជាតុទាំងឡាយដែលមាននៅក្នុងឧបករណ៍តាមដានការឃ្លាំមើល។ ប្រព័ន្ធទិន្នន័យនេះត្រូវបានពិនិត្យមើលជារៀងរាល់ត្រីមាសនីមួយៗ។

**យន្តការរាយការណ៍អំពីហេតុការណ៍**

ការរាយការណ៍អំពីហេតុការណ៍ កត់ត្រាអំពីហេតុការណ៍នៃការរឹតត្បិត និងការរំលោភបំពានលើសេរីភាពមូលដ្ឋានដែលមិនមានចុះផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ការរាយការណ៍អំពីហេតុការណ៍ត្រូវបានប្រមូលតាមរយៈទម្រង់រាយការណ៍អំពីហេតុការណ៍ដែលរាយការណ៍ទៅក្រុមការងាររបស់គម្រោង។ ទម្រង់រាយការណ៍ហេតុការណ៍នេះផ្តល់ជាមធ្យោបាយសម្រាប់បុគ្គល ឬសមាគមដែលជឿថាសេរីភាពមូលដ្ឋានរបស់ខ្លួនត្រូវបានរំលោភបំពាន។

ទម្រង់រាយការណ៍អំពីហេតុការណ៍នេះត្រូវបានបំពេញនៅពេលដែលជនរងគ្រោះទៅជួបជាមួយក្រុមការងារគម្រោង ហើយក្រុមការងារនឹងស្វែងយល់ពីបញ្ហានេះ ព្រមទាំងធ្វើការសាកសួរព័ត៌មានលម្អិតជាមួយជនរងគ្រោះបន្ថែមទៀត។ ទម្រង់រាយការណ៍ពីហេតុការណ៍កត់ត្រានូវទិន្នន័យទាំងបែបគុណភាព និងបរិមាណ រួមមានព័ត៌មានអំពីហេតុការណ៍ ទីតាំង មនុស្សដែលពាក់ព័ន្ធរួមទាំងប្រភេទនៃសមាគម(ប្រសិនបើពាក់ព័ន្ធ) និងប្រភេទនៃការរំលោភបំពានផងដែរ។ ព័ត៌មានសំខាន់ៗ ដែលមាននៅក្នុងទម្រង់រាយការណ៍អំពីហេតុការណ៍នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យនៃយន្តការរាយការណ៍អំពីហេតុការណ៍ ដែលនឹងវិភាគដោយក្រុមការងារ។

នៅក្នុងឆ្នាំទី៦ គម្រោងបានកត់ត្រានូវហេតុការណ៍ជាក់លាក់ចំនួន ១០៣ ករណីតាមរយៈការរាយការណ៍អំពីហេតុការណ៍។

**ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព**

ការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព គឺជាការស្ទង់មតិប្រចាំឆ្នាំដែលត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីទស្សនៈនិងបទពិសោធន៍របស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពអំពីលទ្ធភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវបានជ្រើសរើសដោយចៃដន្យដើម្បីចូលរួមក្នុងការស្ទង់មតិនេះ តាមរយៈការប្រើប្រាស់នូវសំណាកបច្ចេកទេស ដោយផ្អែកលើព័ត៌មានពីសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលនិងសហព័ន្ធសហជីព។

នៅក្នុងឆ្នាំទី៦ នេះ ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។ ការស្ទង់មតិគឺត្រូវបានធ្វើតាមអនឡាញ និងតាមរយៈការសម្ភាសផ្ទាល់ជាមួយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលមានអ្នកឆ្លើយតបសរុបចំនួន ១៧១ នាក់។ លទ្ធផលនៃស្ទង់មតិនេះត្រូវបានវិភាគដើម្បីកំណត់ការវិវត្តផ្សេងៗគ្នារបស់អង្គការសង្គមស៊ីវិល ឬសហជីពដែលបានចូលរួមនៅក្នុងការស្ទង់មតិ រួមទាំងនៅក្នុងសូចនាករនៃឧបករណ៍តាមដានការឃ្លាំមើល។

**ការស្ទង់មតិជាសាធារណៈ**

ការស្ទង់មតិជាសាធារណៈត្រូវបានធ្វើឡើងរៀងរាល់ឆ្នាំក្នុងគោលបំណងយល់ដឹងអំពីការយល់ឃើញរបស់សាធារណៈជនទូទៅទាក់ទងនឹងការអនុវត្តសេរីភាពមូលដ្ឋាន។ ការជ្រើសរើសសំណាកដែលមានលក្ខណៈ

ងាយៗ ត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងលើដំណើរការស្ទង់មតិនេះ។ ការស្ទង់មតិនេះធ្វើឡើងនៅទីតាំងសាធារណៈទូទាំងប្រទេសកម្ពុជា។ ក្រុមការងារគម្រោងបានចុះទៅទីតាំងដែលប្រជាពលរដ្ឋធ្វើដំណើរទៅមក និងជ្រើសរើសដោយចៃដន្យនូវប្រជាពលរដ្ឋយល់ព្រមចូលរួមនៅក្នុងការស្ទង់មតិនេះ។

ការស្ទង់មតិជាសាធារណៈនៅឆ្នាំទី៦នេះ បានចាប់ផ្តើមធ្វើឡើងចន្លោះថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ទូទាំង ២៥ ខេត្ត/ក្រុង និងមានអ្នកចូលរួមឆ្លើយចំនួន ៩២៥ នាក់។ លទ្ធផលនៃការស្ទង់មតិត្រូវបានវិភាគដើម្បីកំណត់ពីនិន្នាការ របស់អ្នកឆ្លើយតបផ្សេងៗគ្នា ក៏ដូចជាសូចនាករ ។

**ការពិនិត្យឡើងវិញនៅលើច្បាប់**

ការពិនិត្យឡើងវិញទៅលើច្បាប់ គឺជាការវិភាគទៅលើច្បាប់ ប្រកាស សារាចរ សេចក្តីណែនាំ គោលនយោបាយ របាយការណ៍ និងបទប្បញ្ញត្តិផ្សេងទៀតដែលប៉ះពាល់ដល់ការអនុវត្តសេរីភាពមូលដ្ឋាន។ ការពិនិត្យ និងសិក្សាឯកសារច្បាប់ដើម្បីវាយតម្លៃអំពីកម្រិតដែលក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជា អាចធានាបាននូវសេរីភាពមូលដ្ឋានដូចដែលបានតម្រូវនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដូចនេះការពិនិត្យទៅលើច្បាប់គឺផ្តោតសំខាន់ទៅលើខ្លឹមសារដែលចែងនៅច្បាប់ ជាជាងការអនុវត្តច្បាប់។[144]

របាយការណ៍ចេញពីការសិក្សាលើការពិនិត្យច្បាប់ពាក់ព័ន្ធនេះនឹងធ្វើឡើងជាប្រចាំត្រីមាស ដើម្បីធ្វើបច្ចុប្បន្នភាពនៃការវិភាគច្បាប់និងលិខិតបទដ្ឋានគតិយុត្តិដែលត្រូវបានធ្វើវិសោធនកម្ម ក៏ដូចជាការបញ្ចូលការវិភាគទៅលើច្បាប់ថ្មី ឬលិខិតបទដ្ឋានគតិយុត្តិទាំងឡាយណាដែលបានពិនិត្យឡើងវិញថ្មីៗនេះផងដែរ ។[145]

**ការវាយតម្លៃការចុះបញ្ជីសហជីព**

ការចុះបញ្ជីគឺជាដំណើរការចាំបាច់មួយដែលច្បាប់ស្តីពីសហជីពតម្រូវឱ្យអនុវត្ត ហើយក៏ជាឱកាសមួយសម្រាប់រដ្ឋាភិបាលបដិសេធសិទ្ធិសហជីពផងដែរ។ ការត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការចុះបញ្ជីបង្ហាញឱ្យឃើញថាតើសិទ្ធិក្នុងការបង្កើតសហជីពត្រូវបានការពារ និងអនុវត្តដោយរបៀបណា។

ក្រុមការងារអនុវត្តគម្រោងបានកត់ត្រាទិន្នន័យទាំងនេះ តាមរយៈការអនុវត្តដោយ "សាកសួរព័ត៌មានពីដំណើរការចុះបញ្ជី" ចំពោះសហជីពដែលបានជ្រើសរើស និងវាយតម្លៃពីបទពិសោធន៍នៃការចុះបញ្ជីតាមច្បាប់ស្តីពីសហជីព ដោយប្រើប្រាស់ទម្រង់វាយតម្លៃរបស់ក្រុមការងារគម្រោង។ ទម្រង់វាយតម្លៃ តាមដានទាំងមន្ត្រីរាជរដ្ឋាភិបាលនិងសហជីពនៅពេលដែលសហជីពកំពុងដំណើរការនៃការចុះបញ្ជី។ នៅក្នុងឆ្នាំទី៦នេះ ឧបករណ៍វាយតម្លៃបានកត់ត្រាបទពិសាធន៍ការចុះបញ្ជីរបស់សហជីពចំនួន ៣ ដែលបានព្យាយាមចុះបញ្ជីតាមច្បាប់ស្តីពីសហជីព។ គម្រោងក៏មិនបានកត់ត្រាបទពិសោធន៍ចុះបញ្ជីរបស់អង្គការសមាគមណាមួយក្នុងការព្យាយាមចុះបញ្ជីស្ថាប័នរបស់ពួកគេតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងឆ្នាំទី៦ នេះឡើយ។

[144] ឧបសម្ព័ន្ធទី ២

[145] ព័ត៌មានបន្ថែមទាក់ទងនឹងការពិនិត្យច្បាប់គឺអាចរកបានតាមការស្នើសុំ។

## ឧបសម្ព័ន្ធទី ២ ៖ តារាងលទ្ធផលនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន

តារាងខាងក្រោមនេះ ផ្តល់នូវទិន្នន័យសង្ខេបដែលគម្រោងបានប្រមូលចងក្រងក្នុងអំឡុងពេល "ឆ្នាំទី៦" (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១)។ សូចនាករទាំងនេះសុទ្ធតែពឹងផ្អែកទៅលើប្រភពទិន្នន័យផ្សេងៗ ដូចមាននៅក្នុងឧបសម្ព័ន្ធទី១ ។

ការពិនិត្យមើលទៅលើច្បាប់ដែលពាក់ព័ន្ធ៖ នៅពេលបញ្ចប់ការវិភាគច្បាប់ឬលិខិតបទដ្ឋានពាក់ព័ន្ធ ពិន្ទុ ៥ នឹងត្រូវវាស់ទៅលើក្របខ័ណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានដែលស្របតាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ (ពិន្ទុ ១= ស្ថិតក្នុងកម្រិតខ្សោយ, ពិន្ទុ៣= កម្រិតពិន្ទុមធ្យម, ៥= កម្រិតពិន្ទុខ្ពស់)។ គម្រោងឱ្យពិន្ទុដោយមិនលំអៀងទៅលើកម្មវត្ថុនិងសូចនាករ ផ្អែកលើច្បាប់និងលិខិតបទដ្ឋានដែលមានស្រាប់។ ចំពោះច្បាប់ឬលិខិតបទដ្ឋានដែលលំបាកនឹងរកបាន សូចនាករនេះត្រូវបានបញ្ជាក់ថាមិនអាចវាស់វែងបាន។

ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយនិងការរាយការណ៍ពីហេតុការណ៍៖ ទិន្នន័យត្រូវបានកត់ត្រារយៈពេលពេញ ១ឆ្នាំ និងជាត្រីមាសដែលត្រូវបានប្រើប្រាស់សម្រាប់ការវិភាគ។

ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ការស្ទង់មតិជាសាធារណៈ ការវាយតម្លៃការចុះបញ្ជីអង្គការសង្គមស៊ីវិល ៖ ការឆ្លើយតបរបស់អ្នកចូលរួមទៅលើការស្ទង់មតិ និងការវាយតម្លៃ ការចុះបញ្ជីត្រូវបានរួមបញ្ចូលនិងវិភាគ។ ចំនួនតួលេខនិងភាគរយដែលបង្ហាញទាំងអស់ត្រូវបានយកចេញពីការវិភាគចម្លើយរបស់អ្នកឆ្លើយតប។

លទ្ធផលរបាយការណ៍ប្រចាំឆ្នាំត្រូវរួមបញ្ចូលគ្នានូវសូចនាករទាំងអស់ ហើយត្រូវបានឱ្យពិន្ទុតាមលេខកូដពណ៌ដូចខាងក្រោម៖

| | |
|---|---|
| | កម្រិតពិន្ទុខ្ពស់ |
| | កម្រិតពិន្ទុមធ្យម |
| | ស្ថិតក្នុងកម្រិតខ្សោយ |
| | មិនអាចឱ្យពិន្ទុបាន |

ការវាយតម្លៃលើឧបករណ៍តាមដានវាយតម្លៃធ្វើឡើងនៅចុងបញ្ចប់ឆ្នាំទី៤ ដែលនាំឱ្យមានការពិនិត្យឡើងវិញសូចនាករមួយចំនួនរួមទាំងការបន្ថែមសូចនាករថ្មីចំនួន១១ ទៀត ។ សូចនាករត្រូវបានសម្គាល់ថា "មិនមានចម្លើយ" សម្រាប់ឆ្នាំផ្សេងៗក្រៅពីឆ្នាំទី៥។

| | ចំណុចគន្លឹះទី១ ៖ ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ស្របតាមបទដ្ឋានអន្តរជាតិ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ធាតុផ្សំ | សូចនាករ | ប្រភពទិន្នន័យ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | ឆ្នាំទី៦ | *កំណត់សម្គាល់* |
| សេរីភាពខាងការបង្កើតសមាគម | កម្រិតនៃច្បាប់ជាតិ ឬគោលនយោបាយ បានគោរពដល់សេរីភាពខាងការបង្កើតសមាគមសេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | ៣ | ៣ | ៣ | ៣ | ២,៥ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញនៅឡើយទេ។ សិទ្ធិសេរីភាពខាងសមាគម ការជួបប្រជុំ និងការបញ្ចេញមតិត្រូវបានធានាក្នុងមាត្រា៤២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ)[146]។ ទោះជាយ៉ាងណាមាត្រា៤២ នេះ អនុវត្តចំពោះប្រជាពលរដ្ឋកម្ពុជាដោយមិនមានវិសាលភាពសម្រាប់ជនជាតិផ្សេងទៀតដែលកំពុងរស់នៅកម្ពុជានោះឡើយ[147]។ ប៉ុន្តែ ការធានាទាំងនេះត្រូវបានធ្វើឱ្យខ្សោយចុះគួរឱ្យកត់សម្គាល់ដោយសារការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិមួយចំនួននៃរដ្ឋធម្មនុញ្ញនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨[148]។ ម្យ៉ាងទៀត ច្បាប់ជាតិដែលគ្រប់គ្រងមកលើសេរីភាពខាងសមាគមដូចជាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពក៏មានបទប្បញ្ញត្តិមួយចំនួនរឹតត្បិតលើសេរីភាពមូលដ្ឋានផងដែរ[149]។ វិសោធនកម្មច្បាប់ស្តីពីសហជីពឆ្នាំ២០២០ មានការរឹតត្បិតតិចជាងមុនទៅលើសេរីភាពខាងសមាគម[150]។ សេរីភាពខាងការបញ្ចេញមតិត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅក្នុងច្បាប់មួយចំនួនដូចជាច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការអប់រំ ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ និងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ខណៈបញ្ញត្តិខ្លះស្របនឹងបទដ្ឋានអន្តរជាតិនោះ ក៏មានបទប្បញ្ញត្តិមួយចំនួនមានខ្លឹមសារមិនច្បាស់លាស់ដែលអាចធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការជួបប្រជុំ។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន (ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្ន) បានកាត់បន្ថយលទ្ធភាពក្នុងការអនុវត្តសេរីភាពខាងការសមាគម ជួបប្រជុំ និងបញ្ចេញមតិក្នុងកំឡុងពេលអាសន្ន។ នៅឆ្នាំទី៦ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានអនុម័តឡើងដោយផ្តល់អំណាចយ៉ាងខ្លាំងដល់អាជ្ញាធរ ដើម្បីរឹតត្បិតសិទ្ធិសេរីភាពខាងសមាគម និងសេរីភាពខាងការជួបប្រជុំ ក្រោមហេតុផលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ការអនុម័ត អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិក៏ប៉ះពាល់យ៉ាងខ្លាំងលើសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំតាមអនឡាញ។ ចំណែកឯ សង្ឃប្រកាសដែលបានចេញផ្សាយកាលពីឆ្នាំ២០២១ ប៉ះពាល់ធ្ងន់ធ្ងរទៅលើសេរីភាពខាងការជួបប្រជុំផងដែរ។[151] |
| **សេរីភាពខាងការបង្កើតសមាគម** | | | | | | | | | |
| ១.២ ដំណើរការចុះបញ្ជីអង្គការសមាគមមានភាពត្រឹមត្រូវ និងតម្លាភាព | កម្រិតនៃដំណើរការនៃការចុះបញ្ជី និងតម្លៃសម្រាប់ការចុះបញ្ជីសមាគម ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងចែងយ៉ាងច្បាស់លាស់ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ១ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះ។ លក្ខខណ្ឌនៃការចុះបញ្ជីសម្រាប់អង្គការសង្គមស៊ីវិលនិងសហជីពក្រោមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនិងច្បាប់ស្តីពីសហជីពមានខ្លឹមសារស្រពេចស្រពិលលំបាក និងមានបន្ទុកច្រើន ព្រមទាំងមិនស្របជាមួយបទដ្ឋានអន្តរជាតិ[152]។ ជាពិសេស មាត្រា ៥ នៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបានរាំងបុគ្គលមួយចំនួនដូចជា បុគ្គលដែលពុំមែនជាសញ្ជាតិខ្មែរ និងបុគ្គលដែលមានអាយុក្រោម ១៨ ឆ្នាំ ពីការបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ព្រមទាំង កង្វះវិធានផ្នែកនីតិវិធីការពារក្នុងដំណើរការចុះបញ្ជីដែលកំណត់ក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែន រដ្ឋាភិបាល[153] ក្នុងនោះរួមទាំងការចែងពុំច្បាស់លាស់ពីមូលហេតុនៃការបដិសេធលើសំណើសុំចុះបញ្ជីជាដើម ដែលប្រការនេះទុកចន្លោះប្រហោងសម្រាប់ការបដិសេធតាមតែអំពើចិត្ត។ ផ្ទុយពីនេះ វិសោធនកម្ម |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ច្បាប់ស្តីពីសហជីពឆ្នាំ២០២០ បានលុបចោលការរឹតត្បិត២ ចំណុចមកលើសហជីព ប៉ុន្តែនៅតែមានភាពលំបាកក្នុងការចុះបញ្ជីដដែល។ មាត្រា ២០ បានរឹតត្បិតលទ្ធភាពក្នុងការអនុវត្តសកម្មភាព ដោយតម្រូវឱ្យថ្នាក់ដឹកនាំមានអាយុចាប់១៨ ឆ្នាំ មានសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅ ដែលទាំងនេះមិនស្របតាមការអនុវត្តអន្តរជាតិល្អបំផុតនោះទេ និងមិនស្របតាមសិទ្ធិក្នុងការជ្រើសរើសតំណាងរបស់ពួកគេដោយសេរី[154]។ ជាចុងក្រោយច្បាប់ស្តីពីសហជីពបង្កើតគ្រាន់តែជានីតិវិធីសម្រាប់សហជីពដែលតម្រូវឱ្យមានការយល់ព្រមពីរដ្ឋាភិបាលផ្ទុយពីច្បាប់សិទ្ធិមនុស្សអន្តរជាតិតែប៉ុណ្ណោះ[155]។ |
| ១.៣ ពុំមានការរឹតត្បិតលើចំនួនសមាគមដែល មានគោលបំណងប្រហាក់ប្រហែលគ្នា | កម្រិតនៃ ច្បាប់ ឬគោលនយោបាយដែល រឹតត្បិតមិនឱ្យបង្កើតសមាគមដែលមាន គោលបំណងប្រហាក់ប្រហែលគ្នា | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញចំណុចនេះព្រោះពុំមានការកម្រិតលើចំនួនសមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលអាចមានគោលបំណងស្រដៀងគ្នាក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលឬច្បាប់ដទៃទៀតដែរ។ មាត្រា ៧ នៃច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចែងថាឈ្មោះជាអក្សរពេញ ឬអក្សរកាត់ និងនិមិត្តសញ្ញានៃសមាគមឬអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") នឹងមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញឬអក្សរកាត់របស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីមុនរួចហើយ ឬ រូបសញ្ញា បដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិឡើយ។ ការរឹតត្បិតនេះបង្ហាញពីហេតុផលសមស្រប និងសមាមាត្រដរាបណាត្រូវបានគេអនុវត្តក្នុងលក្ខខណ្ឌត្រឹមត្រូវ តម្លាភាពនិងសង្គតិភាព។ |

146 សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧ បានបកស្រាយតាមសមត្ថកិច្ចលើមាត្រា៣១ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងអត្ថន័យសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ក្នុងនោះរួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលត្រូវអនុវត្តដោយផ្ទាល់ក្នុងច្បាប់កម្ពុជា។ សូមមើលសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧) ។

147 អនុក្រឹត្យលេខ១៤៨ ស្តីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសបានពង្រីកវិសាលភាពមកលើកម្មករនិយោជិតដែលធ្វើការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

148 ការប្រើពាក្យពេចន៍មានអត្ថន័យទូលំទូលាយខ្លាំងពេក តម្រូវឱ្យបុគ្គលនិងគណបក្សនយោបាយ "តម្កល់ផលប្រយោជន៍ជាតិ" និងហាមប្រាមការធ្វើសកម្មភាពណាមួយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋ ទោះដោយផ្ទាល់ឬដោយប្រយោលក្តី"។ ហ្វ្រេសញូវ 'សេចក្តីព្រាងវិសោធនកម្មក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងការប្រមាថព្រះមហាក្សត្រ និងវិសោធនកម្មបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ (ហ្វ្រេសញូវ, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨) <https://bit.ly/2DZYnKM>

149 ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី (មាត្រា៦) ចែងលក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីមានបន្ទុកច្រើន លំបាក និងមិនច្បាស់លាស់ (ជំពូក២ និងជំពូក៣)។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលព្រមទាំងចែងបែបទូលាយពីការត្រួតពិនិត្យរបស់រដ្ឋាភិបាលក្នុងការបដិសេធលើការចុះបញ្ជី(មាត្រា៨) និងកំណត់នូវសកម្មភាពលំបាក និងលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ហិរញ្ញវត្ថុ (មាត្រា២៥) ព្រមទាំងកំណត់ទោសទណ្ឌដោយពុំសមាមាត្រ (មាត្រា៣០)។ ច្បាប់ស្តីពីសហជីពកំណត់លក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីមានបន្ទុកច្រើននិងស្មុគស្មាញ និងមូលហេតុទូលំទូលាយសម្រាប់ការបដិសេធលើការចុះបញ្ជី (មាត្រា១៥ និងប្រកាសលេខ២៤៩) និងលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍មានបន្ទុកច្រើន (មាត្រា១៧)។

150 វិសោធនកម្មបានបន្ថយវិសាលភាពរបស់ច្បាប់ដែលមិនរួមបញ្ចូលការធ្វើដំណើរតាមអាកាសនិងការធ្វើដំណើរទៅបរទេស ហើយបានដកចេញចំណុចដែលតម្រូវឱ្យថ្នាក់ដឹកនាំសហជីពមិនធ្លាប់ត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌពីមុនមក ហើយការតម្រូវឱ្យបង់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងទៀតត្រូវធ្វើមុនពេលការរំលាយសហជីព និងដកចេញចំណុចដែលសហជីពត្រូវរំលាយនៅពេលមានថ្នាក់ដឹកនាំឬគណៈគ្រប់គ្រងត្រូវបានកាត់ទោសពីបទល្មើសព្រហ្មទណ្ឌ។ សូមមើលចំណុចគន្លឹះទី១ ។

151 សូមមើលចំណុចគន្លឹះទី១។

152 សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីពីរស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង អាយ.ស៊ី.អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ៤-៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf.។

153 មាត្រា៨ ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានរកឃើញថាមាន "គោលបំណង និងទិសដៅ" ដែលអាចធ្វើឱ្យ "ប៉ះពាល់ដល់សន្តិសុខ ស្ថិរភាពនិងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា"។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ទុកចន្លោះនូវនីតិវិធីចុះបញ្ជីជាក់ស្តែង សម្រាប់ការកំណត់របស់ក្រសួងមហាផ្ទៃ តាមរយៈបញ្ញារដ្ឋបាល ឬ ប្រកាស។

154 អនុសញ្ញាលេខ៨៧ នៃអង្គការពលកម្មអន្តរជាតិ ស្តីពីសេរីភាពខាងសមាគម និងការការពារការរៀបចំ អនុម័តថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៤៨, មានសុពលភាពអនុវត្តថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៥០) <http://www.refworld.org/docid/425bc1914.html>

155 មាត្រា៨ នៃអនុសញ្ញាសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មានសុពលភាពអនុវត្តថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦) ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១.៤ សមាគមអាចបង្កើតបណ្តាញនៃអង្គការ សម្ព័ន្ធ សហព័ន្ធ ឬ សហជីពប្រភេទដទៃទៀតដោយសេរី | កម្រិតនៃច្បាប់ ឬគោលនយោបាយអនុញ្ញាតឱ្យសមាគមបង្កើតបណ្តាញនៃអង្គការ សម្ព័ន្ធ សហព័ន្ធ សហជីពនៃប្រភេទដទៃទៀត | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | កម្ពុជាបានបំពេញផ្នែកខ្លះលើចំណុចនេះ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែន រដ្ឋាភិបាលកំណត់ថា សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបង្កើតឡើងដោយ "រូបវន្ត ឬ/និងនីតិបុគ្គល" ដែលនេះបង្ហាញថាទោះជាបណ្តាញរបស់អង្គការមិនមែនរដ្ឋាភិ បាល ឬសម្ព័ន្ធនៃអង្គការដាដើម នឹងទទួលបានការអនុញ្ញាត។ ទន្ទឹមនេះច្បាប់ស្តីពីសហជីពទទួលស្គាល់ជាក់លាក់នូវសិទ្ធិរបស់សហជីពនិងសមាគមនិយោជកក្នុងការប្រឹក្សាយោបល់គ្នាដោយសេរី និងចូលជាសមាជិកជាមួយសហជីពនិងសមាគមនិយោជកដទៃទៀត ច្បាប់ស្តីពីសហជីពក៏ចែងផងដែរពីលក្ខខណ្ឌរឹតត្បិតដែលពុំអនុលោមតាមច្បាប់ ដែលបង្កជាឧបសគ្គពុំសមហេតុផលចំពោះការបង្កើតបណ្តាញនេះ[156]។ |
| ១.៥ ការចុះបញ្ជីសមាគមគឺជាការស្ម័គ្រចិត្ត | កម្រិតនៃ ច្បាប់ ឬគោលនយោបាយ អនុញ្ញាតដល់ការចុះបញ្ជីសមាគមដោយស្ម័គ្រចិត្ត | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ១ | ១ | ១ | ១ | ១ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះ ពីព្រោះថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីគណបក្សនយោបាយ ហើយនិងច្បាប់ស្តីពីសហគមន៍កសិកម្មតម្រូវឱ្យចុះបញ្ជីតាមលក្ខន្តិកៈច្បាប់។ និយមន័យនៃពាក្យសមាគមក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល មានអត្ថន័យទូលំទូលាយពេក ដែលអាចអនុវត្តទៅលើក្រុមក្នុងវិស័យក្រៅប្រព័ន្ធនៅកម្ពុជា[157]។ នៅក្រោមច្បាប់ទាំងនេះ ការខកខានមិនបានចុះបញ្ជីការធ្វើឱ្យសមាគមក្លាយជាសមាគមដែលខុសច្បាប់។ ការបដិសេធលើសមត្ថភាពផ្លូវច្បាប់និងការហាមប្រាមស្ថាប័ននានាដែលពុំបានចុះបញ្ជីពីការអនុវត្តសកម្មភាពណាមួយគឺពុំស្របជាមួយសិទ្ធិសេរីភាពខាងសមាគម ដែលសមាគមទាំងនោះគួរតែត្រូវបានចាត់ទុកថាកំពុងធ្វើប្រតិបត្តិការដោយស្របច្បាប់ លើកលែងតែបានបង្ហាញសកម្មភាពផ្ទុយពីនោះ។ ការចុះបញ្ជីគួរតែត្រូវបានធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយផ្អែកលើប្រព័ន្ធនៃការជូនដំណឹង ជាជាងសុំការអនុញ្ញាត និងក្នុងគោលបំណងទទួលបានសមត្ថភាពផ្លូវច្បាប់តែប៉ុណ្ណោះ ដែលនេះពុំគួរតម្រូវឱ្យមានការស្នើសុំការអនុញ្ញាតជាមុន ចំពោះការអនុវត្តសកម្មភាពស្របច្បាប់ឡើយ។ |
| ១.៦ បទប្បញ្ញត្តិដែលមានការត្រួតត្រាលើសមាគម អនុលោមតាមបទដ្ឋានអន្តរជាតិ | កម្រិតនៃច្បាប់ ឬគោលនយោបាយដែលត្រួតត្រាមកលើសមាគម ដែលស្របទៅតាមបទដ្ឋានអន្តរជាតិ | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ២ | ១ | ២ | ២ | ២ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ ការអនុវត្តល្អប្រសើរជាអន្តរជាតិបង្ហាញពីតម្រូវការតិចតួចក្នុងការតាមដាន ព្រមទាំងការប៉ុនប៉ងត្រួតពិនិត្យយ៉ាងជិតដល់ដើម្បីរារាំងសមាគមនិងសមាជិកក្នុងការបង្កើតជម្រើសសម្រាប់អង្គការនិងការងាររបស់អង្គការ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល តម្រូវឱ្យសមាគមឬអង្គការមិនមែនរដ្ឋាភិបាលជូនដំណឹងជាមុនអំពីសកម្មភាពជាក់លាក់ដែលធ្វើឡើងក្នុងដែនសមត្ថកិច្ចរដ្ឋបាលរាជធានី ឬ ខេត្តណាមួយត្រូវជូនដំណឹងដោយផ្ទាល់ទៅរដ្ឋបាលរាជធានីខេត្តនោះ និងទាមទារឱ្យអង្គការអន្តរជាតិនៅកម្ពុជាធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល។ ច្បាប់ស្តីពីសហជីពបញ្ជាក់ពីខ្លឹមសារនៃលក្ខន្តិកៈរបស់សហជីពកំណត់ចំនួននៃសមាជិក និងអាណត្តិសម្រាប់អ្នកដឹកនាំគ្រប់គ្រង។ យន្តការត្រួតពិនិត្យច្បាប់នេះនៅមិនបានធ្វើឱ្យថមថយនៅក្នុងវិសោធនកម្មច្បាប់ស្តីពីសហជីពនោះទេ។ ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងមួយនៅក្នុងខែតុលា ឆ្នាំ២០១៧ ជាការអនុវត្តលើការជូនដំណឹងជាមុនសម្រាប់សកម្មភាពរបស់អង្គការសង្គមស៊ីវិលទាំងអស់ ដែលសេចក្តីប្រកាសនេះផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ ព្រោះជាការគ្រប់គ្រងលើសកម្មភាពសមាគម។ នេះនាំឱ្យពិន្ទុ |

[156] មាត្រា១០ នៃច្បាប់ស្តីពីសហជីព។

[157] លិខិតរបស់ ម.ស.ម.ក ស្នើក្រសួងមហាផ្ទៃបញ្ជាក់នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ និងលិខិតឆ្លើយតបដែលម.ស.ម.កបានទទួលនៅថ្ងៃទី២២ ខែកញ្ញា។ ជាការលើកទឹកចិត្ត លិខិតឆ្លើយតបពីក្រសួងមហាផ្ទៃបានចង្អុលបង្ហាញថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនឹងមិនអនុវត្តចំពោះសហគមន៍មូលដ្ឋានទេ។ ទោះយ៉ាងណាក៏ដោយ នៅតែមានវិសាលភាពគួរឱ្យកត់សំគាល់សម្រាប់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីក្នុងការអនុវត្តផ្ទុយ ដោយសារតែពាក្យដែលមិនច្បាស់លាស់នៃច្បាប់៖ សូមអាន ម.ស.ម.ក លិខិតរបស់ ម.ស.ម.ក ស្នើក្រសួងមហាផ្ទៃបញ្ជាក់ពីការប្រើប្រាស់ពាក្យថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ (<https://cchrcambodia.org/index_old.php?title=CCHR-Open-Letter-Seeks-Clarification-Regarding-Application-of-the-LANGO-to-CBOs-and-Informal-Groups&url=media/media.php&p=press_detail.php&prid=569&id=5>

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ទាក់ទងនឹងការគោរពសេរីភាពមូលដ្ឋានធ្លាក់ចុះរហូតមកដល់ ១ ក្នុងរបាយការណ៍អង្កេតនៅក្នុងឆ្នាំទី២ ប៉ុន្តែរបៀបរបបនៃការជូនដំណឹងជាមុននេះត្រូវបាននិរាករណ៍វិញ តាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។ វិសាលភាពនៃសេចក្តីជូនដំណឹងឆ្នាំ២០១៨ នោះ បានកំណត់លើក្រុមសង្គមស៊ីវិលដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ដែលនោះជាការទុកចន្លោះប្រហោង អាចឱ្យអាជ្ញាធរមូលដ្ឋានរារាំងសកម្មភាពនានារបស់ក្រុម ឬសហគមន៍តូចៗដែលពុំបានចុះបញ្ជី។ |
| ១.៧ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ទៅរដ្ឋាភិបាលអនុលោមតាមបទដ្ឋានអន្តរជាតិ | កម្រិតនៃលក្ខខណ្ឌធ្វើរបាយការណ៍អនុលោម តាមបទដ្ឋានអន្តរជាតិ | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ២ | ២ | ២ | ២ | ២ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍សម្រាប់អង្គការសង្គមស៊ីវិល និងសហជីពក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពគឺជាលក្ខខណ្ឌលំបាកនិងមិនអនុលោមតាមបទដ្ឋានអន្តរជាតិ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុញ្ញាតរដ្ឋអាចតម្រូវឱ្យសមាគមរាយការណ៍ ប្រសិនបើពួកគេបង្កើតឡើងក្នុងគោលបំណងស្របច្បាប់ តម្លាភាព និងគណនេយ្យភាព[158]។ ទោះជាយ៉ាងណាក៏ដោយបទដ្ឋានអន្តរជាតិតម្រូវឱ្យមានកាតព្វកិច្ចរាយការណ៍ដោយមិនតាមទំនើងចិត្ត[159]ឬជាបន្ទុក[160]។ អង្គការតូចៗ ឬក្រុមនៅតាមមូលដ្ឋានអាចរងការប៉ះពាល់ដោយពុំសមាមាត្រព្រោះពួកគេមានធនធានតិចតួចក្នុងការគោរពតាមលក្ខខណ្ឌតម្រូវជាច្រើនទាំងនោះ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពតម្រូវឱ្យអង្គការសង្គមស៊ីវិលឬសហជីពធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុទៅក្រសួងមហាផ្ទៃ[161]។ នៅឆ្នាំទី៤ មាត្រា១៧ នៃច្បាប់ស្តីពីសហជីពត្រូវបានកែសម្រួលឡើងវិញពីប្រើពាក្យថា "រៀបចំ" ជំនួសឱ្យ "ដាក់ជូន" នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍សកម្មភាពសម្រាប់សវនករតាមសំណើរបស់ម្ចាស់ជំនួយឬសំណើររបស់សមាជិកសរុបយ៉ាងតិច១០% សម្រាប់សហជីពមូលដ្ឋាន ឬ ៥% នៃសមាជិកសរុបសម្រាប់សហព័ន្ធឬសហភាព។ មាត្រា១៧ ដដែលនេះក៏នៅតែបន្តរឹតត្បិតនៃដល់កិច្ចការផ្ទៃក្នុងរបស់សមាគមដដែល។ |
| ១.៨ ទណ្ឌកម្មមកលើសមាគមត្រូវបានចែងដោយច្បាប់សមាមាត្រផ្សព្វផ្សាយជា | កម្រិតនៃ ទណ្ឌកម្មគតលើសមាគមដែលត្រូវកំណត់ដោយច្បាប់ដែលមានលក្ខណៈសមាមាត្រ ផ្សព្វផ្សាយជាសាធារណៈមាននិយមន័យច្បាស់លាស់ | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ២ | ១,៥ | ១,៥ | ១,៥ | ១ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ ទោសទណ្ឌចំពោះអង្គការសង្គមស៊ីវិលនិងគណបក្សនយោបាយក្រោមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីព និងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ពុំសមាមាត្រ និងពុំស្របតាមបទដ្ឋានអន្តរជាតិ[162]។ ទោសទណ្ឌជាច្រើនក្រោមច្បាប់ស្តីពីសហជីព ហើយនិងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏ពុំបានពន្យល់អត្ថន័យឱ្យបានល្អិតល្អន់ ងាយយល់ និងតម្លាភាព។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់ទោសទណ្ឌជាច្រើន រួមទាំងការរំលាយសហជីពនិងការលុបបញ្ជិកា ដែលមានខ្លឹមសារស្រពេចស្រពិល និយមន័យមិន |

[158] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២(, កថាខណ្ឌ៦៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

[159] ដូចយោងខាងលើ។

[160] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិឡើកឡើងថាកាតព្វកិច្ចរាយការណ៍មិនត្រូវរារាំងដល់ស្វយ័តភាពរបស់សមាគម។ UN Doc A/HRC/២២/L.១៣ (ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១៣ កថាខណ្ឌទី៩ (<https://documents-dds-ny.un.org/doc/RESOLUTION/LTD/G13/120/26/PDF/G1312026.pdf?OpenElement>

[161] សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ផលិតរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង ICNL (ខែសីហា ឆ្នាំ២០១៨) ទំព័រ ៤ - ៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

[162] សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង ICNL (ខែសីហា ឆ្នាំ២០១៨) ទំព័រ៤ - ៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/ admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សាធារណៈ មាននិយមន័យ ច្បាស់លាស់ មានតម្លាភាព និងងាយស្រួលយល់ | | | | | | | | | ច្បាស់លាស់ហើយពិបាកយល់ពីចំណាត់ការទាំងនោះដូចជាពាក្យ "អព្យាក្រឹតផ្នែកនយោបាយ" ជាដើម។ ខណៈដែលវិសោធនកម្មច្បាប់ស្តីពីសហជីពនៅក្នុងឆ្នាំទី៤ បានដកចេញការរំលាយដោយស្វ័យប្រវត្តិប្រសិនបើថ្នាក់ដឹកនាំឬគណៈគ្រប់គ្រងណាម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋ[163] ច្បាប់ស្តីពីសហជីពក៏ចែងចំណាត់ការដែលនាំទៅរកការដាក់ទោសទណ្ឌដោយស្រដៀងគ្នានេះដែរពីនិយមន័យមិនច្បាស់លាស់និងចំណាត់ការដូចជាការហាមប្រាមការក្នុងការរៀបចំទាំងឡាយណាក្នុងគោលបំណងបំរើនិន្នាការនយោបាយ ឬមហិច្ឆតាផ្ទាល់ខ្លួន" ជាដើម។ម្យ៉ាងវិញទៀតក្រមព្រហ្មទណ្ឌពិពណ៌នាអំពីទោសទណ្ឌក្នុងអត្ថន័យមិនច្បាស់លាស់និងពុំសមាមាត្រដែលអាចអនុវត្តទៅលើសមាគមនិងអ្នកដឹកនាំដូចជា "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស" "ការប្រមាថ" "ការរិះគន់លើសេចក្តីបង្គាប់របស់តុលាការ" និងបទបរិហារកេរ្តិ៍។ ច្បាប់ស្តីពីទូរគមនាគមន៍[164] ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម[165] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏មានចែងពីទោសទណ្ឌនានា ចំពោះចំណាត់ការដែលពុំសមាមាត្រ ទូលំទូលាយនិងមិនច្បាស់លាស់នេះផងដែរ[166]។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្នបង្កើតការដាក់ទោសទណ្ឌមកលើអង្គការនិងអាជីវករដែលមិនគោរពតាមវិធានការពេលប្រទេសជាតិជួបប្រទះភាពអាសន្ន។ នីតិបុគ្គលដែលប្រព្រឹត្តិទោសព្រហ្មទណ្ឌដោយចេតនា "ការប៉ុនប៉ងប្រព្រឹត្តអំពើរាំងដល់កិច្ចប្រត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន"[167] និង "ការប៉ុនប៉ងមិនគោរពតាមវិធានដែលដាក់ចេញដោយរាជរដ្ឋាភិបាល"[168]។ ទោសទណ្ឌក្រោមបញ្ញត្តិច្បាប់រួមបញ្ចូលទាំងការពិន័យដ៏ធំរហូតដល់១លានរៀលបន្ថែមពីលើ "ទោសមួយឬច្រើនដូចមានចែមក្នុងមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ"។ មាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌផ្តល់អំណាចក្នុងការរំលាយឬបង្ខំឱ្យបិទស្ថាប័ន។ ការរំលាយឬបិទស្ថាប័នអង្គការសង្គមស៊ីវិលជាការរំលោភបំពានច្បាប់មួយផ្នែកដែលមិនស្របនឹងសេរីភាពខាងការបង្កើតសមាគម[169]។ មាត្រា៥ នៃច្បាប់កូវីដ-១៩ អាជ្ញាធរអាចផ្អាកឬដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម និងអាចបិទអាជីវកម្មដែលជាទណ្ឌកម្មប្រឆាំងនឹងជនដែលមិនអនុវត្តតាមបទបញ្ញតិ ធានការសុខភាព និងវិធានការរដ្ឋបាលនេះ"។ |
| ១.៩ ការការពារផ្នែកនីតិវិធីត្រូវបានដាក់ឱ្យអនុវត្តសម្រាប់សមាគមដែល | កម្រិតនៃការការពារត្រូវបាន ដាក់ឱ្យអនុវត្តសម្រាប់សមាគម ដែលប្រឈមនឹងទណ្ឌកម្ម | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ២ | ២ | ២ | ២ | ២ | ២ | កម្ពុជាមិនបំពេញចំណុចនេះទេ។ មានកិច្ចការពារមួយចំនួនត្រូវបានបញ្ចូលក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដូចជាការបង្កើនទោស និងសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងករណីលុបឈ្មោះចេញពីបញ្ជី ប៉ុន្តែកិច្ចការពាររួមទាំងនេះពុំទាន់គ្រប់គ្រាន់នៅឡើយ។ ច្បាប់ស្តីពីសហជីពពុំមានចែងពីសិទ្ធិប្តឹងទាស់ទៅសាលាឧទ្ធរណ៍ចំពោះការពិន័យផ្នែករដ្ឋបាល ឡើយ ទោះបីជាប្រកាសលេខ ២៥១ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតសិទ្ធិមានដែនកំណត់ទាក់ទងនឹងបណ្តឹងទាស់ផ្នែករដ្ឋបាលទៅក្រសួងការងារនៅពេលទទួលបានលិខិតព្រមាន ឬការ |

163 មាត្រា២៩ នៃច្បាប់ស្តីពីសហជីព។

164 មាត្រា១០៧ នៃច្បាប់ស្តីពីទូរគមនាគមន៍។

165 មាត្រា៧ មាត្រា ៧៦ មាត្រា៧៧ និងមាត្រា៧៨ នៃច្បាប់ស្តីពីប្រឆាំងនឹងអំពើភេរវកម្ម។

166 មាត្រា៧៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់។

167 មាត្រា៧ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

168 មាត្រា៨ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

169 ការរំលាយដោយមិនស្ម័គ្រចិត្តគឺជាវិធីចុងក្រោយដែលគួរប្រើប្រាស់តែចំពោះការបំពានធ្ងន់ធ្ងរនិងគួរតែធ្វើបន្ទាប់ពីបានជូនដំណឹងនិងឱកាសក្នុងការតវ៉ា។ សូមអាន គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ A/HRC/20/27, ‘របាយការណ៍អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងសមាគម’, Maina Kiai’ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២, កថាខណ្ឌទី៧៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ប្រយោមនឹងទណ្ឌកម្ម | | | | | | | | | ដាក់វិន័យក៏ដោយ។ សម្រាប់ទោសមានចែងក្នុងក្រមព្រហ្មទណ្ឌមានសិទ្ធិប្ដឹងទាស់។ ច្បាប់ស្ដីពីគណបក្សនយោបាយចែងពីកិច្ចការពារមានដែនកំណត់ចំពោះទោសទណ្ឌនានា បើទោះជាស្ថាប័ននីតិប្រតិបត្តិទទួលបានឆន្ទានុសិទ្ធិខ្ពស់ក្នុងការដាក់ទោសទណ្ឌ ដែលមានអត្ថន័យទូលំទូលាយ និងមិនច្បាស់លាស់យ៉ាងណាក៏ដោយ។ |
| ១.១០ សិទ្ធិក្នុងការរំលាយដោយស្ម័គ្រចិត្ត ត្រូវបានការពារដោយច្បាប់ | កម្រិតនៃការរំលាយដោយស្ម័គ្រចិត្តត្រូវបាន ការពារដោយច្បាប់ | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ជាទូទៅកម្ពុជាបានបំពេញចំណុចនេះ។ មាត្រា ២៦ នៃច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចែងថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក "អាចផ្អាកសកម្មភាពរបស់ខ្លួនដោយត្រូវជូនដំណឹងជា លាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃហើយមុននឹងផ្អាកសកម្មភាពត្រូវធ្វើរបាយការណ៍សកម្មភាពការងារនិងរបាយការណ៍ហិរញ្ញវត្ថុ"។ ប៉ុន្តែបទប្បញ្ញត្តិមិនច្បាស់លាស់នៃមាត្រា២៦ (២) អាចបង្កើតជាឧបសគ្គដល់ការរំលាយសមាគមឬអង្គការមិនមែនរដ្ឋាភិបាលដោយស្ម័គ្រចិត្ត ព្រោះបទប្បញ្ញត្តិទាំងនោះតម្រូវថា "សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន"។ ក្រមរដ្ឋប្បវេណីធានាដល់ការរំលាយស្ថាប័ននីតិបុគ្គលដោយស្ម័គ្រចិត្តមាត្រា ៦៤ (១)។ តាមមាត្រា៦៤ (១) នីតិបុគ្គលត្រូវរំលាយ "ដោយមូលហេតុនៃការរំលាយដែលបានកំណត់នៅក្នុងលក្ខន្តិកៈ"។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលអាចរំលាយតាមសេចក្ដីសម្រេចនៃមហាសន្និបាតសមាជិក ដោយទទួលបានការគាំទ្រភាគច្រើនពីសមាជិកទាំងអស់ ត្រូវមានការយល់ព្រមពីសមាជិកចាប់ពីពាក់កណ្ដាលឡើងទៅ ដោយមានសំឡេងចាប់ពី ៣ ភាគ ៤ (បីភាគបួន) ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ (មាត្រា ៦៤ (២) និង (៣)។ |
| ១.១១ ការរំលាយអាចធ្វើទៅបានបន្ទាប់ពីបានប្រើប្រាស់ច្បាប់ដទៃទៀតអស់លទ្ធភាពនិងបង្ហាញថាសមាគមអាចបង្កគ្រោះថ្នាក់ | កម្រិតនៃ ដំណើរការរំលាយ សមាគមត្រូវបានដាក់ឱ្យអនុវត្ត | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ១ | ១ | ១ | ១ | ១ | ១ | កម្ពុជាខកខានបំពេញចំណុចនេះ។ ការរំលាយសមាគមឬអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើទៅបានក្រោមក្រមព្រហ្មទណ្ឌ ច្បាប់ស្ដីពីការប្រឆាំងនឹងអំពើភេរវកម្ម ច្បាប់ស្ដីពីគណបក្សនយោបាយ និងច្បាប់ស្ដីពីសហជីព។ ក្នុងករណីនីមួយៗ ការរំលាយអាចត្រូវបានគេកំណត់ថាជាវិធានការវិន័យតែប៉ុណ្ណោះ ពុំមែនជាការឆ្លើយតបដោយ សមាមាត្រនិងជាដំណោះស្រាយចុងក្រោយចំពោះគ្រោះថ្នាក់លើការបន្តប្រតិបត្តិការរបស់សមាគមឬអង្គការមិនមែន រដ្ឋាភិបាលឡើយ។ ជាពិសេស វិធានការនៃការផ្អាក ឬការរំលាយសហជីពតាមអំណាចផ្នែករដ្ឋបាលបង្កការប៉ះពាល់ធ្ងន់ធ្ងរលើគោលការណ៍សេរីភាពខាងសមាគម[170]។ |
| ១.១២ សមាគមត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពសេដ្ឋកិច្ច | កម្រិតនៃច្បាប់ ឬគោលនយោបាយ អនុញ្ញាតឱ្យសមាគមធ្វើ សកម្មភាពសេដ្ឋកិច្ច | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ៥ | ៤ | ៤ | ៤ | ៤ | ៤ | ជាទូទៅកម្ពុជាបំពេញចំណុចនេះ។ ពុំមានច្បាប់កំណត់ឱ្យមានការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងសកម្មភាពសេដ្ឋកិច្ចនោះទេ។ ទោះបីជាសិទ្ធិនេះពុំត្រូវបានការពារ តែសិទ្ធិនេះក៏ពុំត្រូវបានហាមប្រាមផងដែរ។ តែយ៉ាងណាក្ដី ច្បាប់ស្ដីពីសហជីពរារាំងសហជីពក្នុងការបង្កើតមុខជំនួញលើកលែងតែបុគ្គលដែលទទួលបានភាពជាតំណាងបំផុតនៅកន្លែងការងារ។ |

[170] អត្ថបទស្ដីពីសេរីភាពខាងសមាគមរបស់អង្គការពលកម្មអន្តរជាតិឆ្នាំ២០១៦ កថាខ័ណ្ឌ៦៨៣ <http://www.ilo.org/wcmsp5/groups/public/@ed_norm/@normes/documents/publication/wcms_090632.pdf>។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១.១៣ ការទទួល មូលនិធិបរទេស ត្រូវបានអនុញ្ញាត នៅក្រោម ច្បាប់ | កម្រិតនៃការទទួលបានមូលនិធិបរទេសត្រូវ បានអនុញ្ញាតដោយច្បាប់ | ការពិនិត្យ និងសិក្សា ឡើងវិញនូវ ឯកសារ ច្បាប់ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញចំណុចនេះ។ ពុំមានការហាមប្រាមផ្នែកច្បាប់លើសមាគមក្នុងការទទួលមូលនិធិបរទេសឡើយ។ ប៉ុន្តែជាការសំខាន់ត្រូវកត់សម្គាល់ថា មាត្រា ២៧ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកំណត់បន្ថែមទៀតនូវលក្ខខណ្ឌតឹងរ៉ឹងក្នុងការធ្វើរបាយការណ៍សម្រាប់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលស្វែងរក និង / ឬទទួលមូលនិធិបរទេស។ ម្យ៉ាងទៀត មាត្រា ២៥ នៃច្បាប់ដដែលតម្រូវថាសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលទទួលការគាំទ្រពីម្ចាស់ជំនួយ ត្រូវធ្វើរបាយការណ៍ដែលចម្លងចេញពីឯកសារដើមដែលផ្ញើទៅកាន់ម្ចាស់ជំនួយមកក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេស ក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទានជាមួយម្ចាស់ជំនួយដោយចម្លងចេញពីឯកសារដើមឱ្យបានក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។ ព្រោះថាការផ្តល់មូលនិធិពីភាគីទីពាក្រភាគច្រើនបំផុតសម្រាប់សមាគមគឺមានប្រភពមកពីបរទេសដែលការអនុវត្តនេះអាចបង្កជាឧបសគ្គក្នុងការទទួលមូលនិធិពីបរទេសជាពិសេសសម្រាប់អង្គការតូចៗ។ ម្យ៉ាងទៀត បទប្បញ្ញត្តិទាំងនេះ អាចត្រូវបានរំលោភបំពានដើម្បីយាយីដល់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលទទួលការគាំទ្រពីបរទេស។ |
| ១.១៤ សមាគមមិនប្រឈមនឹងការរឹតត្បិតមិនសមហេតុផលពីការទទួលមូលនិធិឯកជន (ក្នុងស្រុក) | កម្រិតនៃ ច្បាប់ ឬគោលនយោបាយអនុញ្ញាតឱ្យ សមាគមទទួលមូលនិធិពីប្រភពឯកជនដោយគ្មានការរឹតត្បិត មិនសមហេតុផល | ការពិនិត្យ និងសិក្សា ឡើងវិញនូវ ឯកសារ ច្បាប់ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញចំណុចនេះ។ កម្ពុជាពុំមានច្បាប់ហាមប្រាមក្នុងការទទួលមូលនិធិពីប្រភពឯកជនក្នុងស្រុកឡើយ។ ប៉ុន្តែការទទួលការគាំទ្រពីម្ចាស់ជំនួយ ទោះក្រៅប្រទេស ឬ ក្នុងប្រទេសនឹងនាំឱ្យមានលក្ខខណ្ឌធ្វើរបាយការណ៍ដែលតាមការអនុវត្តជាក់ស្តែង អាចបង្កជាឧបសគ្គមួយជាពិសេសចំពោះអង្គការតូចៗ។ ជាងនេះទៅទៀត មាត្រា ២៥ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តម្រូវថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលទទួលការគាំទ្រពីម្ចាស់ជំនួយត្រូវបញ្ជូនច្បាប់ថតចម្លងនៃឯកសារដើមដែលបានបញ្ជូនទៅម្ចាស់ជំនួយមកក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេសឱ្យបានក្នុងអំឡុងពេល៣០ ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ |
| ១.១៥ កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ មិនមានលក្ខណៈស្មុគស្មាញ | កម្រិតនៃ លក្ខខណ្ឌតម្រូវសម្រាប់ការធ្វើ របាយការណ៍ហិរញ្ញវត្ថុ ស្របទៅតាមបទអន្តរជាតិ | ការពិនិត្យ និងសិក្សា ឡើងវិញនូវ ឯកសារ ច្បាប់ | ២ | ២ | ២ | ២ | ២ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញទេ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ក្នុងនោះរួមទាំងបទប្បញ្ញត្តិទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងព័ត៌មានលម្អិតអំពីការទទួលមូលនិធិផងដែរ។ ការកំណត់លក្ខខណ្ឌតម្រូវក្នុងការធ្វើរបាយការណ៍ផ្នែកហិរញ្ញវត្ថុនេះក៏មានចែងក្នុងច្បាប់ស្តីពីសហជីពផងដែរ និងជាកម្មវត្ថុអាចត្រូវកែប្រែពីក្រសួងការងារនៅពេលណាមួយក៏បាន។ មាត្រា១៧ នៃវិសោធនកម្មច្បាប់ស្តីពីសហជីពត្រូវបានកែសម្រួលឡើងវិញពីប្រើពាក្យថា "រៀបចំ" ជំនួសឱ្យ "ដាក់ជូន" នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍សកម្មភាពសម្រាប់សវនករតាមសំណើរបស់ម្ចាស់ជំនួយឬសំណើរបស់សមាជិកសរុបយ៉ាងតិច១០% សម្រាប់សហជីពមូលដ្ឋាន ឬ៥% នៃសមាជិកសរុបសម្រាប់សហព័ន្ធឬសហភាព។ មាត្រា១៧ ដដែលនេះក៏នៅតែបន្តរឹតត្បិតនៃដល់កិច្ចការផ្ទៃក្នុងរបស់សមាគមដដែល។ ទាំងអង្គការសង្គមស៊ីវិលនិងសហជីពឱ្យយោបល់ដែលពួកគេបានប្រឹងប្រែងគោរពតាមតម្រូវការរបាយការណ៍របស់រាជរដ្ឋាភិបាលក្រោមច្បាប់អង្គការសមាគម និងច្បាប់ស្តីពីសហជីព។ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយក៏ចែងពីកាតព្វកិច្ចថ្មីមួយក្នុងការប្រកាសទ្រព្យសម្បត្តិ និងទំនួលខុសត្រូវចំពោះអង្គភាពប្រឆាំងអំពើពុករលួយ។ ជាចុងក្រោយ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ក៏មានចែងក្នុងសេចក្តីប្រកាសស្តីពីគោលការណ៍ណែនាំ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | អនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ចាត់ទុកជាបន្ទុកការងារបន្ថែមទៀតលើលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ ដែលអាចរឹតត្បិតលើសេរីភាពខាងសមាគមដែលពុំអនុលោមតាមច្បាប់។ |
| ១.១៦ យន្តការសម្រាប់ការដោះស្រាយការរំលោភទៅលើសេរីភាពខាងការបង្កើតសមាគមត្រូវបានអនុវត្ត | កម្រិតនៃប្រព័ន្ធដោះស្រាយសម្រាប់ការរំលោភលើ សេរីភាពខាងការបង្កើតសមាគម ត្រូវបានធានាដោយ ច្បាប់ និងគោលនយោបាយ | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ៣ | ២,៥ | ២,៥ | ២,៥ | ២,៥ | ២,៥ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញនៅឡើយទេ។ រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋឱ្យតតាំង នឹងការរំលោភបំពានណាមួយលើសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែ នីតិវិធីត្រួតពិនិត្យផ្នែកតុលាការពុំត្រូវបានពន្យល់ឱ្យបានច្បាស់លាស់ ដែលធ្វើឱ្យការធានានេះមានប្រសិទ្ធភាពតិចតួច។ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញអនុញ្ញាតឱ្យពលរដ្ឋតតាំងចំពោះច្បាប់ឬសេចក្តីសម្រេចដែលបង្កឱ្យមានការរំលោភលើសិទ្ធិក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែច្បាប់នេះត្រូវបានធ្វើវិសោធនកម្មក្នុងខែកុម្ភៈ ឆ្នាំ២០១៨ លុបចេញបញ្ញត្តិដែលអនុញ្ញាតឱ្យគណបក្សនយោបាយអាចប្តឹងទាស់ទៅនឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃដែលបដិសេធលើសំណើសុំចុះបញ្ជី។ ក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមិនមានយន្តការដាក់ទោសរដ្ឋបាលមកលើការបដិសេធការចុះបញ្ជីសមាគមនោះទេ។ សម្រាប់សមាគមក្នុងស្រុកមានវិធានការមួយប៉ុណ្ណោះសម្រាប់តវ៉ាមកលើការបដិសេធការចុះបញ្ជីរបស់ពួកគេដែលត្រូវតវ៉ាចំពោះការបដិសេធតាមប្រព័ន្ធតុលាការ។ សម្រាប់សមាគមបរទេសឬអង្គការអន្តរជាតិពួកគេអាចតវ៉ាពីការសម្រេចនេះទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ ប្រកាសលេខ២៥០ និង២៥១ ពង្រីកវិសាលភាពដល់ច្បាប់ស្តីពីសហជីព ដែលកម្រិតការតវ៉ាត្រឹមតែក្រសួងបណ្តុះបណ្តាលការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែមិនបានផ្តល់សិទ្ធិឱ្យពួកគេតវ៉ាពីការសម្រេចនេះដល់តុលាការនោះទេ។ ហើយទាំងនេះគឺមិនស្របតាមការអនុវត្តល្អបំផុតជាអន្តរជាតិដែលអនុញ្ញាតឱ្យ "សមាគមអាចតវ៉ាអំពីការបដិសេធមិនចុះបញ្ជីដោយមិនលំអៀង និងឯករាជ្យ"[171]។ |
| ១.១៧ សមាជិកភាពនៅក្នុងអង្គការសមាគម សម្ព័ន្ធឬសហព័ន្ធមិនមែនជាកាតព្វកិច្ចឡើយ | កម្រិតនៃសមាជិកភាពនិងការដកខ្លួនពីសមាជិកភាពដោយ ស្ម័គ្រចិត្តក្រោមការកំណត់របស់ច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៤ | ៤ | កម្ពុជាបំពេញបានផ្នែកខ្លះនៃធាតុផ្សំនេះ។ ទាំងច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីសហជីពធានាសេរីភាពក្នុងការមិនចូលរួមនិងចាកចេញពីសហជីពកម្មករឬសមាគមនិយោជក[172]។ ច្បាប់ស្តីពីសហជីពតម្រូវឱ្យបុគ្គលនីមួយៗដាក់លិខិតជាមួយហត្ថលេខាឬក៏ស្នាមមេដៃរបស់ពួកគេទៅសហជីពនិងនិយោជកដើម្បីប្រាប់ពីការចាកចេញពីសមាជិកភាពនោះ។ ច្បាប់នោះក៏បានសង្កត់ធ្ងន់ថា "គ្មាននរណាម្នាក់អាចជ្រៀតជ្រែកសិទ្ធិរបស់កម្មករនិយោជិតក្នុងការចូលរួមឬចាកចេញពីសហជីពឡើយ"[173]។ ស្រដៀងគ្នានេះ ច្បាប់ស្តីពីគណបក្សនយោ បាយបានចែងថា "ការចូលជាសមាជិកភាពនៃគណបក្សនយោបាយគឺជាការស្ម័គ្រចិត្ត"។ សមាជិកនៃគណបក្សនយោបាយអាចលាឈប់ពីសមាជិកភាពបានគ្រប់ពេលវេលាដោយមិនតម្រូវឱ្យមានបង្ហាញពីមូលហេតុ"។[174] ច្បាប់ស្តីពីអង្គការសមាគមនៅតែបន្តស្ងៀមស្ងាត់អំពីការដកខ្លួនចេញពីសមាជិកភាពដោយស្ម័គ្រចិត្ត។ ផ្នែកមួយនៃសមាគមទាំងបីប្រភេទរួមមាន សហជីព សមាគមនិយោជក និងគណបក្សនយោបាយ សិទ្ធិក្នុងការចាកចេញពីសមាជិកភាពគឺមិនត្រូវបានការពារនៅក្នុងច្បាប់នោះទេ។ ទោះជាបែប |

[171] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២(, កថាខណ្ឌ៩៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

[172] " សេរីភាពសហជីពរបស់បុគ្គលម្នាក់ៗក៏បង្ហាញពីសេរីភាពនៃការមិនចូលរួមជាមួយសហជីពកម្មករឬនិយោជក និងសេរីភាពក្នុងការចាកចេញពីសមាគមបានគ្រប់ពេល" មាត្រា២៧៣ នៃច្បាប់ស្តីពីការងារ និង " សេរីភាពរបស់បុគ្គលម្នាក់ក្នុងមាត្រា៥ (សិទ្ធិក្នុងការបង្កើតនិងចូលរួមជាមួយសហជីពឬសមាគមនិយោជក) នៃច្បាប់នេះហើយក៏បង្កប់នូវសេរីភាពក្នុងការមិនចូលរួមជាមួយសហជីពកម្មករឬសមាគមនិយោជកនិងសេរីភាពក្នុងការដកខ្លួនចេញពីសហជីពឬសមាគមនិយោជកនោះបានគ្រប់ពេលទាំងអស់ " មាត្រា៧ នៃច្បាប់ស្តីពីសហជីព។

[173] មាត្រា១៣ នៃច្បាប់ស្តីពីសហជីព។

[174] មាត្រា៧ នៃច្បាប់ស្តីពីគណបក្សនយោបាយ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | នេះក្តីសូចនាករមួយនេះបានឱ្យពិន្ទុចំនួន៤ ។ មាត្រា៤២ នៃរដ្ឋធម្មនុញ្ញធានានិងការពារប្រជាជនខ្មែរក្នុងការបង្កើតសមាគម និងគណបក្សនយោបាយ ប៉ុន្តែមិនបាននិយាយពីការដកខ្លួនចេញពីសមាជិកភាពរបស់សមាគមនោះទេ។ ស្របពេលដែលសិទ្ធិក្នុងការមិនចូលរួមគួរតែបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់ជាតិដើម្បីធានាការការពាររបស់ខ្លួន។ |
| សេរីភាពខាងការជួបប្រជុំ | | | | | | | | | |
| ១.១៨<br>ការសន្មតមុនដែលគាំទ្រដល់ការរៀបចំការប្រមូលផ្តុំដោយសន្តិវិធីគឺត្រូវបានកំណត់យ៉ាងច្បាស់លាស់ | តម្រូវនៃ ក្របខ័ណ្ឌច្បាប់កំណត់នូវការសន្មតមុនដែលគាំទ្រ ចំពោះការប្រមូលផ្តុំដោយសន្តិវិធីដែលត្រូវបានអនុញ្ញាត | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | ២,៥ | ២ | កម្ពុជាខកខានក្នុងការគោរពចំណុចនេះឱ្យបានពេញលេញ។ ច្បាប់កម្ពុជាចែងពុំច្បាស់លាស់ពីការសន្មត់ជាមុនក្នុងការគាំទ្រដល់ការរៀបចំបាតុកម្មដោយសន្តិវិធី។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងពីការសន្មត់ទុកជាមុនក្នុងការគាំទ្រដល់ការរៀបចំបាតុកម្មដោយសន្តិវិធីដែលចែងថា អាជ្ញាធរមានសមត្ថកិច្ច "ត្រូវឆ្លើយតបជាវិជ្ជមានជាលាយលក្ខណ៍អក្សរ"[175]។ ប៉ុន្តែការសន្មត់ទុកជាមុននេះមិនអនុវត្ត ទោះការប្រមូលផ្តុំដោយសន្តិវិធីធ្វើឡើងនៅក្នុងអំឡុងពេលថ្ងៃឈប់សម្រាក (ពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ពិធីឡើងគ្រងរាជ បុណ្យឯករាជ្យជាតិ បុណ្យចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌ)។ ម្យ៉ាងទៀត ប្រសិនបើមាន "ព័ត៌មានច្បាស់លាស់" បញ្ជាក់ថាបាតុកម្ម "អាចបង្កគ្រោះថ្នាក់" ឬ " អាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ" ការសន្មត់ទុកជាមុននោះក៏នឹងត្រូវមោឃៈភាពផងដែរ[176]។ ម្យ៉ាងទៀត ច្បាប់នេះមានវិសាលភាពតូចចង្អៀតពេក ដែលមិនរាប់បញ្ចូលការជួបប្រជុំក្នុងយុទ្ធនាការបោះឆ្នោត ឬការជួបប្រជុំទាក់ទងនឹងវិវាទការងារជាដើមដែលផ្ទុយទៅនឹងគោលការណ៍សន្មត់ទុកជាមុនដែលបានលើកឡើងខាងលើ។[177]<br><br>ស្រដៀងគ្នានេះច្បាប់ការងារក៏មិនរាប់បញ្ចូលនូវសកម្មភាពមួយចំនួនក្រៅពីវិសាលភាពនៃកិច្ចការពារដែលមានចែងក្នុងច្បាប់នេះដែរ[178]។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន បន្ថែមពីលើនូវការសន្មតនៃការអនុញ្ញាតឱ្យមានការប្រជុំដោយសន្តិវិធីដោយកំណត់អំណាចយ៉ាងទូលាយនិងគ្មាន "ហាមឃាត់ឬរឹតត្បិតសិទ្ធិជួបប្រជុំនិងជាក្រុម" នៅក្នុងពេលប្រទេសជាតិភាពអាសន្ន[179]។ ការវិវឌ្ឍបទបញ្ញតិនៅឆ្នាំទី៦ បង្កើតបានជាមូលដ្ឋានបន្ថែមសម្រាប់ជំទាស់នឹងអ្នករិះគន់។ មាត្រា៤ នៃច្បាប់កូវីដ-១៩ ផ្តល់អំណាចដ៏សម្បើមដល់អាជ្ញាធរក្នុងការរឹតត្បិតឬហាមឃាត់ "ការប្រជុំ និងការប្រមូលផ្តុំរបស់មនុស្ស ដែលសកម្មភាពនេះអាចបណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩"។ បន្ថែមពីនេះមានត្រា ៦ នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ រដ្ឋាភិបាលអាចប្រើប្រាស់វាក្នុងការបិទអ៊ីនធឺណិតឬបិទការផ្តល់សេវាដែលប្រើប្រាស់សម្រាប់អនុវត្តការជួបប្រជុំ។ ហើយជាចុងក្រោយ សង្ឃប្រកាស បានហាមឃាត់ព្រះសង្ឃពីការចូលរួមក្នុងការតវ៉ាផ្សេងៗ។ ដោយសារមូលហេតុនេះ ពិន្ទុ |

[175] មាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[176] ក្នុងករណីនេះ ក្រោមមាត្រា ១១ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថាអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីរាជធានី ឬខេត្ត ត្រូវធ្វើការឆ្លើយតបដោយជូនដំណឹង "ជាបន្ទាន់" ទៅអ្នកដែលបានដាក់លិខិតជូនដំណឹង "ដើម្បីឱ្យពួកគេអាចមានពេលជួបជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ធ្វើការពិចារណាដើម្បីពិភាក្សាគ្នាដោះស្រាយ" ។ ប្រសិនបើពុំមានការឯកភាពគ្នាទេ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវផ្តល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងយូរត្រឹមម្ភៃបួន (២៤) ម៉ោងមុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី (មាត្រា១២)។

[177] មាត្រា ៣ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[178] ទន្ទឹមនេះ ច្បាប់ការងារចែងក្នុងមាត្រា៣២០ ថា សិទ្ធិធ្វើកូដកម្ម ត្រូវបាន "ធានា" សិទ្ធិនេះក៏ត្រូវបានអនុវត្តដែរ នៅពេលដែលសហជីពជាតំណាងកម្មករនិយោជិតយល់ឃើញថាត្រូវយកសិទ្ធិនេះ មកប្រើ ដើម្បីបង្ខំឱ្យមានការគោរពតាមអនុសញ្ញារួម ឬតាមច្បាប់។ ជាពិសេស សិទ្ធិធ្វើកូដកម្មអាចអនុវត្តទៅបាន លុះត្រាតែបានប្រើប្រាស់អស់លទ្ធភាពក្នុងការដោះស្រាយជំលោះដោយ មធ្យោបាយសន្តិវិធីជាមួយនិយោជក។

[179] មាត្រា ១៥ នៃច្បាប់ពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន (២០២០)។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ត្រូវបានធ្លាក់ចុះមកត្រឹម ២ ដែលបង្ហាញពីការប្រើអំណាចខ្លាំងក្នុងការរឹតត្បិតនិងហាមឃាត់ដល់ការជួបប្រជុំដោយសសន្តិវិធី។ |
| ១.១៩ ការរឹតត្បិតតម្រូវឱ្យមានហេតុផលច្បាស់លាស់ និងទាន់ពេលវេលា | ក្របខ័ណ្ឌ ច្បាប់តម្រូវឱ្យមានហេតុផលច្បាស់លាស់ទាន់ពេលវេលាចំពោះការរឹតត្បិត លើការជួបប្រជុំ | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | មិនមានចម្លើយ | ៣,៥ | ៤ | ៤ | ៣ | ៣ | កម្ពុជាខកខានក្នុងការបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី[180] ច្បាប់ស្តីពីការងារ[181] និងច្បាប់ស្តីពីការបោះឆ្នោតបង្ហាញពីនីតិវិធីនៃការជូនដំណឹងមុនសម្រាប់ការជួបប្រជុំ[182] ដែលស្របតាមច្បាប់អន្តរជាតិអំពីនីតិវិធីនៃការជូនដំណឹងមុន។ ទោះជាបែបនេះក្តីការអនុវត្តល្អជាអន្តរជាតិបានផ្តល់អនុសាសន៍ អំពីការជូនដំណឹងមុនចំពោះការជួបប្រជុំដែលមានចំនួនអ្នកចូលរួមច្រើន ឬការជួបប្រជុំដែលអ្នករៀបចំរំពឹងថាមានការរំខានតែប៉ុណ្ណោះ[183]។ ខណៈដែលច្បាប់ជាតិមិនបានអនុវត្តការអនុញ្ញាតជាមុន ការពិតដែលថាការជួបប្រជុំដោយសន្តិវិធីអាចត្រូវបានបញ្ឈប់ដោយអាជ្ញាធរ ប្រសិនបើមានការជូនដំណឹងត្រឹមត្រូវមិនបានដាក់ស្នើ មិនស្របតាមច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ[184]។ ច្បាប់ស្តីពីការបោះឆ្នោតរឹតត្បិតមកលើការជួបប្រជុំដោយមិនសមាមាត្រ ដូចជាតម្រូវឱ្យជូនដំណឹងមុនដែលនេះមិនមែនជាការតម្រូវផ្លូវការដែលទាមទារឱ្យមានការជូនដំណឹងគ្រប់ការជួបប្រជុំ ដូចជាការជួបប្រជុំដែលមានអ្នកចូលរួមតិចតួចដោយមិនមានការវិនិច្ឆ័យត្រឹមត្រូវ[185]។ ទោះជាបែបនេះក្តីច្បាប់ស្តីពីគណបក្សនយោបាយទាមទារឱ្យបង្ហាញអត្តសញ្ញាណអ្នកដឹកនាំចំនួន៣ នាក់បាតុកម្មដោយសន្តិវិធីក៏តម្រូវឱ្យមានព័ត៌មានលំអិតនៃអត្តសញ្ញាណរបស់ថ្នាក់ដឹកនាំទាំងបីដែលជាតម្រូវការមួយដែលហាក់ដូចជាមិនសមាមាត្រនិងមិនចាំបាច់[186]។ នេះដូចមិនច្បាស់ថាហេតុអ្វីបានជាព័ត៌មានលម្អិតអំពីបុគ្គលចំនួន ៣ នាក់ចាំបាច់ត្រូវទាមទារ សម្រាប់ការជួបប្រជុំតូចៗ អាចមិនពាក់ព័ន្ធឬជាបន្ទុក ដូច្នេះវាជាឧបសគ្គដល់សេរីភាពខាងការជួបប្រជុំ។ លើសពីនេះទៀត ច្បាប់តម្រូវឱ្យមានការជូនដំណឹងជាមុនត្រូវធ្វើយ៉ាងហោចណាស់ប្រាំថ្ងៃនៃថ្ងៃធ្វើការមុនពេលព្រឹត្តិការណ៍កើតឡើង[187]។ ការកំណត់រយៈពេលបែបនេះគឺជាសកម្មភាពនៃការរឹតត្បិតសេរីភាពខាងការជួបប្រជុំដែលរារាំងអ្នករៀបចំក្នុងការទទួលបានការឆ្លើយតបមកលើព្រឹត្តិការណ៍ដែលពួកគេបានរៀបចំ។ ខណៈដែលច្បាប់ជាតិក្រោមសូចនាករនេះមិនមានការផ្លាស់ប្តូរឡើយនៅក្នុងឆ្នាំទី៥ នេះ ហើយពិន្ទុបានផ្តល់ឱ្យនៅក្នុងកម្រិតពិន្ទុទាប ៣ ការវាយតម្លៃឡើងវិញនូវច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធីនិងការឆ្លើយតបតាមបទដ្ឋានអន្តរជាតិ។ |

[180] មាត្រា៦,៧,១០,១៤,២០ និង២៨ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[181] មាត្រា៣២៤ និង៣២៧ នៃច្បាប់ស្តីពីសហជីព។

[182] មាត្រា៧៨,៧៩ និង៨១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា។ មាត្រា៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់។

[183] OSCE-ODIHR and Venice Commission, 'គោលការណ៍ណែនាំអំពីសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី', (បោះពុម្ពលើកទី២ ២០១០), កថាខណ្ឌ១១៥។ <https://www.osce.org/odihr/73405?download=true> គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍លើកទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai' (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣) UN Doc A/HRC/23/39 កថាខណ្ឌ៥២។

[184] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍លើកទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai' (ថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១២) UN Doc A/HRC/20/27, កថាខណ្ឌ២៩ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf> ។

[185] មាត្រា៦,៧,១០,១៤,២០ និង២៨ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[186] មាត្រា៦ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[187] មាត្រា៧ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១.២០<br>ការហាមឃាត់ការប្រមូលផ្តុំត្រូវបានកំណត់ថាជាវិធានការចុងក្រោយចាំបាច់និងសមាមាត្រទៅនឹងគោលបំណង | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលហាមឃាត់ក្នុងលក្ខខណ្ឌដែលបានកំណត់ថាជាវិធានចុងក្រោយសមាមាត្រ ទៅនឹងគោលបំណង | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | មិនមានចម្លើយ | ២,៥ | ៣ | ៣ | ២,៥ | ២ | កម្ពុជាពុំបានគោរពចំណុចនេះឱ្យបានពេញលេញ។ មាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងនូវលក្ខខណ្ឌចំនួនពីរដែលការជូនដំណឹងពីការប្រមូលផ្តុំអាចត្រូវបានបដិសេធដែលលក្ខខណ្ឌទាំងពីរនោះមានខ្លឹមសារស្រពិចស្រពិល[188]។ សៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីកំណត់ពីស្តង់ដារ អនុវត្តលើប្រភេទព័ត៌មានដែលអាចនាំទៅរកការហាមប្រាម ហើយបើមានសំណើរដែលមិនស្ថិតក្នុងការហាមប្រាមត្រូវពិភាក្សាជាមុន[189]។ នៅក្នុងផ្នែកទាក់ទងនឹងការណែនាំការអនុវត្តនេះក៏គូសបញ្ជាក់ផងដែរថា ប្រសិនបើអាជ្ញាធរជឿថាមានព័ត៌មានដូចបានបញ្ជាក់ក្នុងមាត្រា៩ (២) អាជ្ញាធរត្រូវ "ពិចារណានិងវាយតម្លៃលើព័ត៌មាននោះដើម្បីកំណត់ថាតើព័ត៌មាននោះមានភស្តុតាងដែរឬយ៉ាងណា" ហើយអាជ្ញាធរត្រូវជូនដំណឹងនិងផ្តល់កិច្ចសហប្រតិបត្តិការតាមការបង្កើត "ដំណោះស្រាយដែលលុបបំបាត់គ្រោះថ្នាក់ដែលអាចកើតឡើង ធ្វើយ៉ាងណាឱ្យបាតុកម្មនោះអាចដំណើរការទៅបាន"[190]។ ផ្ទុយទៅវិញ ប្រសិនបើមានការអនុវត្តតាមមាត្រា៩(២) នេះក៏ពុំមានបទប្បញ្ញត្តិដើម្បីអាចឱ្យអាជ្ញាធរឆ្លើយតបវិញឡើយ។ ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចដ៏ធំក្នុងការហាមឃាត់ការជួបប្រជុំក្នុងពេលដែលប្រទេសជាតិជួបភាពអាសន្នផ្ទុយពីច្បាប់អន្តរជាតិ។ ច្បាប់នេះមិនបានពិចារណាទៅលើពីភាពចាំបាច់ឬសមាមាត្រ ដែលអាចឱ្យអាជ្ញាធរមានសិទ្ធិហាមឃាត់មិនឱ្យមានការជួបប្រជុំ នៅពេលដែលការជួបប្រជុំមិនមែនជាវិធានការចុងក្រោយឬរឹតត្បិតតិចតួចបំផុត។ មាត្រា៤ នៃច្បាប់ស្តីពីកូវីដ-១៩ អនុញ្ញាតឱ្យរដ្ឋាភិបាលមានអំណាចក្នុងការហាមឃាត់បណ្តោះអាសន្ន "ការប្រជុំ និងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនោះនាំឱ្យមានការរីករាលដាលជំងឺកូវីដ-១៩"។ កង្វះខាតនៃការពន្យល់អំពីមូលហេតុដែលហាមឃាត់ការជួបប្រជុំ ដែលអាចបណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩ គួបផ្សំនឹងអំណាចដែលផ្តល់ឱ្យអាជ្ញាធរក្នុងការហាមឃាត់ការជួបប្រជុំ។ ទោះបីជាវិធានការកាត់បន្ថយការរីករាលដាល ក៏បង្កើតជាលក្ខខណ្ឌហាមឃាត់ការប្រមូលផ្តុំ។[191] បន្ថែមពីនេះ ការហាមឃាត់ព្រះសង្ឃក្នុងការចូលរួមការជួបប្រជុំតាមរយៈសង្ឃប្រកាសគឺមិនសមាមាត្រនិងមិនស្របតាមគោលបំណងស្របច្បាប់នោះទេ។<br>នេះបង្ហាញថាបទបញ្ញាតិទាំង២នេះ ទទួលបានពិន្ទុមកត្រឹមតែ ២ ប៉ុណ្ណោះ ។ |
| ១.២១<br>ការរឹតត្បិតតម្រូវឱ្យមានហេតុផលច្បាស់លាស់និងទាន់ពេលវេលា | កម្រិតនៃ ក្របខ័ណ្ឌច្បាប់តម្រូវឱ្យមាន ហេតុផលច្បាស់លាស់ទាន់ពេលវេលា ចំពោះការរឹតត្បិតលើការជួបប្រជុំ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | មិនមានចម្លើយ | ៣,៥ | ៤ | ៤ | ៣ | ២,៥ | កម្ពុជាបានបំពេញតាមចំណុចនេះបានខ្លះ។ ក្របខ័ណ្ឌច្បាប់ដែលមានស្រាប់តម្រូវឱ្យមានការឆ្លើយតបពីអាជ្ញាធរមកលើការជូនដំណឹងអំពីការជួបប្រជុំ។ ការឆ្លើយតបចាំបាច់ត្រូវប្រាប់ពីមូលហេតុដែលអាជ្ញាធររឹតត្បិត ទោះជាបែបនេះក្តីក៏នៅតែមិនមានចែងជាក់លាក់នោះទេ។ ច្បាប់ជាតិបានសន្មត់ថាបានផ្តល់សិទ្ធិប្រសិនបើមិនទទួលបានការឆ្លើយតបពីការជូនដំណឹងនោះទេ[192]។ នៅក្នុងមាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ចត្រូវតែឆ្លើយតបនូវលិខិត ជូនដំណឹងយ៉ាងយូរត្រឹម៣ថ្ងៃនៃការងារ ដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានដាក់ជូន។ ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចខកខានក្នុងការឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី "មានន័យថាអាជ្ញាធរ ដែន |

[188] មាត្រា ៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចែងថាអាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ចត្រូវឆ្លើយតបជាវិជ្ជមាន ចំពោះលិខិតជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែ៖ ១) ការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវចំលើថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក ពិធីបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ២) មានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

[189] ផ្នែក៣ មាត្រា ២ មាត្រា៤ មាត្រា៧ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[190] ផ្នែក៣ មាត្រា ២ មាត្រា៤ មាត្រា៧ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[191] សូមមើលចំណុចគន្លឹះទី១។

[192] សូមមើលមាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុម្មដោយសន្តិវិធី។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ដីរាជធានី ឬខេត្តមានសមត្ថកិច្ចបានព្រមព្រៀងហើយ˝[193]។ លើសពីនេះទៀត ក្នុងករណីដែលចែងនៅក្នុងមាត្រា៩(២) ប្រសិនបើមិនមានការព្រមព្រៀងគ្នា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជាបុគ្គលម្នាក់គត់ដែលជាអ្នកធ្វើសេចក្តីសម្រេចចុងក្រោយជាលាយលក្ខណ៍អក្សរនិងយ៉ាងយូរបំផុតម្ភៃបួន(២៤)ម៉ោងមុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី[194]។ សេចក្តីសម្រេចនេះមិនបានអនុញ្ញាតឱ្យមានការតវ៉ានៅមុខតុលាការមិនលំអៀងដូចមានចែងក្នុងច្បាប់អន្តរជាតិនោះទេ[195]។ ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នខកខានក្នុងការរាប់បញ្ចូលការទទួលខុសត្រូវ ឬតម្លាភាពរបស់អាជ្ញាធរដែលកំណត់ថាតើត្រូវដាក់កម្រិតលើការជួបប្រជុំគ្នាទេច្បាប់មិនតម្រូវឱ្យអាជ្ញាធរផ្តល់ហេតុផលណាមួយឡើយ។ មិនខុសពីការពន្យល់ខាងលើ ច្បាប់កូវីដ-១៩ បានអនុញ្ញាតឱ្យអាជ្ញាធររឹត្បិត "ការប្រជុំ និងការប្រមូលផ្តុំមនុស្សដែលនាំឱ្យមានរីករាលដាលជំងឺកូវីដ-១៩˝។ កង្វះខាតនៃការពន្យល់អំពីមូលហេតុដែលហាមឃាត់ការជួបប្រជុំដែលអាចបណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩˝ ប៉ុន្តែមិនបានផ្តល់មូលហេតុគ្រប់គ្រាន់ពីក្រោយការហាមឃាត់ដោយអាជ្ញាធរនោះទេ។ [196]ពិន្ទុនេះត្រូវបានបន្ថយត្រឹម ២ពិន្ទុ។ |
| ១.២២ ការរឹតត្បិតលើពេលវេលា និង ទីកន្លែង មិនមែនជាកាតព្វកិច្ចនោះទេ | កម្រិតនៃក្របខណ្ឌច្បាប់ដែលរឹតត្បិតមកលើពេលវេលា និង/ឬទីកន្លែង ត្រូវបានចែងនៅក្នុងក្របខណ្ឌច្បាប់ | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | មិនមាន ចម្លើយ | ៤ | ៤ | ៤ | ៣ | ២,៥ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ មាត្រា៩(១) នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបង្ហាញពីការហាមឃាត់ទៅលើការធ្វើបាតុកម្មដោយសន្តិវិធីនៅថ្ងៃបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក បុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ការហាមឃាត់ទាំងអស់នេះមិនមាននៅក្នុងគោលបំណងណាមួយដែលមាននៅក្នុងមាត្រា២១ ក.អ.ស.ព.ន ប៉ុន្តែនៅតែអាចធ្វើបាន។ ករណីខ្លះទៀត ការហាមឃាត់ទៅលើការធ្វើបាតុកម្មដោយសន្តិវិធីទាំងអស់នៃថ្ងៃទាំងនោះ មិនបំពេញតាមតម្រូវការចាំបាច់និងសមាមាត្រនៃផ្នែកទី៣ នៃលក្ខខ័ណ្ឌទាំងបីចំណុច វាអាចមានការជំទាស់គំនិតគ្នាក្នុងការពិចារណាអំពីកាលៈទេសៈជាក់លាក់នៃការប្រមូលផ្តុំនីមួយៗហើយដូច្នេះនឹងមានវិសមភាពនិងការរើសអើង (វាប៉ះពាល់ដល់ពលរដ្ឋដែលមានបំណងអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំ)[197]។ អំណាចក្នុងការរឹតត្បិតនិងហាមឃាត់ការជួបប្រជុំទាំងអស់នេះដែលមានចែងក្នុងមាត្រា ៥ (២) នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្នអាចដំណើរការជារបាំងក្នុងការហាមឃាត់ការជួបប្រជុំទាំងអស់ក្នុងពេលមានអាសន្ន។ ពាក្យពេចន៍នៃច្បាប់នេះមានលក្ខណៈទូលំទូលាយនិងត្រូវបានគេមើលឃើញថារាល់ការជួបប្រជុំមួយចំនួនឬទាំងអស់អាចត្រូវបានហាមឃាត់ដោយសេរីនៅក្នុងមាត្រា៥ (២)។ ស្រដៀងគ្នានេះ មាត្រា៤ នៃច្បាប់កូវីដ-១៩ ផ្តល់ឱ្យអាជ្ញាធរនូវ "អំណាចបណ្តោះអាសន្ន˝ ក្នុងការហាមឃាត់ការជួបប្រជុំដែលអាចបណ្តាលឱ្យមានការរីករាលដាលកូវីដ-១៩ ហាក់ដូចជាអនុញ្ញាតឱ្យមានការហាមឃាត់ដាច់ខាត ប៉ុន្តែមិនបានកំណត់ជាក់លាក់អំពីពេលណាដែលការហាមឃាត់នេះនឹងត្រូវបញ្ចប់នោះទេ។ ហើយនេះ |

193 មាត្រា១០ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

194 មាត្រា១២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

195 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១), កថាខណ្ឌ៤២ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

196 មាត្រា១២ នៃច្បាប់ស្តីកូវីដ-១៩។

197 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍រួមគ្នារបស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម និងការដោះស្រាយក្រៅប្រព័ន្ធច្បាប់ដោយសង្ខេប ឬតាមទំនើងចិត្តដើម្បីគ្រប់គ្រងការប្រមូលផ្តុំ, ( ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦(, UN Doc. A/HRC/៣១/៦៦ កថាខណ្ឌ៣០។ សូមអានគណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ, 'របាយការណ៍ជុំទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai,' UN Doc. A/HRC/២៣/៣៩, ( ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣, កថាខណ្ឌ៦៣ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session23/A.HRC.23.39_EN.pdf>

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | អាជ្ញាធរអាចហាមឃាត់ការជួបប្រជុំគ្នាដោយប្រើរយៈពេលយូរតាមទំនើងចិត្ត។[198] ពិន្ទុនេះត្រូវបានធ្លាក់មកត្រឹម ២,៥ ។ |
| ១.២៣ ការជួបប្រជុំស្របពេលគ្នានៅទីតាំង និងពេលវេលាតែមួយត្រូវបានអនុញ្ញាត | កម្រិតនៃ ក្របខ័ណ្ឌច្បាប់ដែល អនុញ្ញាតឱ្យមានការជួបប្រជុំ ស្របពេលគ្នា | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ គ្មានច្បាប់ការហាមឃាត់ទៅលើការជួបប្រជុំដែលបានធ្វើក្នុងពេលជាមួយគ្នានោះទេ។ មាត្រា១៤ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធីបានចែងថា ការធ្វើបាតុកម្មដោយសន្តិវិធីមានពីរក្រុមផ្សេងគ្នាហើយធ្វើនៅកន្លែងតែមួយនិងពេលវេលាតែមួយ អាជ្ញាធរដែនដីរាជធានីឬខេត្ត មានសមត្ថកិច្ចត្រូវសម្រេចឱ្យក្រុមអ្នកដែលបានដាក់សេចក្ដីជូនដំណឹងមុនទទួលបានសិទ្ធិធ្វើមុន ឬអាចអនុញ្ញាតឱ្យធ្វើនៅកន្លែងមួយផ្សេងទៀតដែលមានចម្ងាយយ៉ាងតិចប្រាំរយ(៥០០) ម៉ែត្រពីគ្នា។ ការផ្ដល់ជូននេះគឺជាផ្នែកមួយនៃមាត្រា១៤ ដែលទាក់ទងនឹងករណីបាតុកម្មជាក់ស្ដែងនៅ "កន្លែងមញ្ជោញមតិជាសាធារណៈ" ឬនៅកន្លែងឯកជន។ ប៉ុន្តែ នៅក្នុងផ្នែកទី២ នៃមាត្រា២.៤.៥ នៃការណែនាំការអនុវត្តបានបង្ហាញច្បាស់លាស់ថាអាជ្ញាធរគួរតែ "ប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងដ៏ល្អបំផុតរបស់ពួកគេ" ដើម្បីធានាថាក្រុមដែលចង់ធ្វើបាតុកម្មទាំងអស់អាចធ្វើបាតុកម្មបាន"ក្នុងកម្រិតដែលអាចធ្វើទៅបាន" ដែលពួកគេអាចធ្វើដូច្នោះក្នុងលក្ខណៈ ពេលវេលា និងទីតាំងដែលពួកគេបានស្នើសុំ។ |
| ១.២៤<br>នីតិវិធីប្ដឹងជំទាស់ មុនពេលមានស្ថាប័នឯករាជ្យ និងមិនលម្អៀងត្រូវបានបង្កើតឡើងសម្រាប់ការដាក់កំហិតលើការប្រមូលផ្ដុំ | កម្រិតនៃនីតិវិធីជំទាស់ដែលត្រូវបាន កំណត់នៅក្នុងក្របខ័ណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | ២,៥ | ២,៥ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ នៅក្នុងច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី "អាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចត្រូវតែឆ្លើយតបទៅនឹងលិខិតជូនដំណឹងយ៉ាងយូរត្រឹមបី(៣) ថ្ងៃនៃថ្ងៃការងារដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានគេដាក់ជូន[199]។ អាជ្ញាធរដែនដី រាជធានីឬខេត្តមានសមត្ថកិច្ចខកខានក្នុងការឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី "មានន័យថាអាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចបានព្រមព្រៀងហើយ"[200]។ បើកន្លែងណាមានព័ត៌មានច្បាស់ថាការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ។ អាជ្ញាធរ ដែនដីរាជធានីឬខេត្តត្រូវតែជូនដំណឹងទៅអ្នករៀបចំកម្មវិធី"ភ្លាមៗ" ហើយមានរយៈពេលបីថ្ងៃដើម្បីជួបជាមួយអ្នកដឹកនាំបាតុកម្មដើម្បីឈានទៅរកកិច្ចព្រមព្រៀងមួយ។ បើសិនមិនមានការព្រមព្រៀងគ្នានោះទេ មានត្រា១២ បានចែងថារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជាបុគ្គលម្នាក់ដែលជាអ្នកសម្រេចចុងក្រោយជាលាយលក្ខណ៍អក្សរនិងយ៉ាងយូរបំផុតម្ភៃបួន(២៤)ម៉ោង មុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនអាចត្រូវបានចាត់ទុកថាជា "ស្ថាប័នឯករាជ្យនិងមិនលំអៀងឡើយ"។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺជាសមាជិកនៃអង្គនីតិប្រតិបត្តិមិនមែនជា "ស្ថាប័នឯករាជ្យ"។ មិនអាចប្ដឹងទៅស្ថាប័នតុលាការបន្ថែមទៀតបានទេ។ ដូច្នេះមិនមាននីតិវិធីបណ្ដឹងឧបាស្រ័យឯករាជ្យឬមិនលំអៀងត្រូវបានកំណត់ដោយច្បាប់ទេ។ នៅលើការវាយតម្លៃឡើងវិញនៃចំណុចនេះពិន្ទុនេះត្រូវបានទម្លាក់មកត្រឹម ២,៥ ។ លើសពីនេះទៅទៀតច្បាប់ស្ដីពីកូវីដ-១៩ មិនមាននីតិវិធីបណ្ដឹងឧបាស្រ័យណាមួយត្រូវបានផ្ដល់មកលើការដាក់កម្រិតការជួបប្រជុំទេ ចំណុចនេះមិនច្បាស់ថាតើនីតិវិធីបណ្ដឹងឧបាស្រ័យធម្មតាក្រោមច្បាប់បាតុកម្មដោយសន្តិវិធីឬយ៉ាងណា[201]។ |

[198] សូមមើលចំណុចគន្លឹះទី១។

[199] មាត្រា១២ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[200] មាត្រា១០ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[201] មាត្រា៥(២) នៃច្បាប់ស្ដីពីគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។ មាត្រា ៤ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១.២៥ អ្នករៀបចំមិនប្រឈមនឹងទោសព្រហ្មទណ្ឌ ឬទណ្ឌកម្មរដ្ឋបាលការខកខានមិនបានជូនដំណឹងដល់អាជ្ញាធរ | កម្រិតនៃ ក្របខណ្ឌច្បាប់ដែលកំណត់អំពីការដាក់ទោស ព្រហ្មទណ្ឌនិង/ឬ រដ្ឋបាលចំពោះអ្នករៀបចំដែល ខកខានមិនបានជូនដំណឹងអាជ្ញាធរ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | ៣ | ៣ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ផ្តល់នូវការព្រមានដល់អ្នករៀបចំបាតុកម្មដែលមិនផ្តល់នូវការជូនដំណឹង[202]។ ច្បាប់ស្តីពីសហជីពនិងច្បាប់ស្តីពីការងារបានចែងថា ការធ្វើកូដកម្មដែលមិនស្របតាមបទប្បញ្ញត្តិរបស់ខ្លួនរួមទាំងតម្រូវឱ្យជូនដំណឹងជាមុនត្រូវចាត់ទុកថាខុសច្បាប់[203]។ ប៉ុន្តែមានតែស្ថាប័នតុលាការតែមួយគត់អាចកំណត់ពីភាពស្របច្បាប់និងមិនស្របច្បាប់នៃការធ្វើកូដកម្ម[204]។ យ៉ាងណាក៏ដោយ ច្បាប់ស្តីពីសហជីពចែងថា ប្រសិនបើអ្នកធ្វើកូដកម្មបន្តធ្វើកូដកម្ម ត្រូវបានតុលាការការងារប្រកាសថាខុសច្បាប់និងមិនបានអនុវត្តតាមការព្រមាន ពួកគេនឹងត្រូវទទួលរងការផាកពិន័យជាអន្តរការណ៍ ជាទឹកប្រាក់មិនលើសពី៥លានរៀល (ប្រមាណ ១២០០ ដុល្លាសហរដ្ឋអាមេរិក)[205]។ នៅពេលដែលការពិន័យគឺជាជម្រើសចុងក្រោយទៅតាមការព្រមានពីរបី ដង ចំនួនការផាកពិន័យបង្កើតឱ្យមានការដាក់កំហិតដោយមិនសមហេតុផលទៅលើសិទ្ធិសេរីភាពកម្មករក្នុងការប្រើប្រាស់សេរីភាពខាងសមាគម។ |
| ១.២៦ នគរបាលមានកាតព្វកិច្ចសម្របសម្រួលដល់ការជួបប្រជុំដោយសន្តិវិធី | កម្រិតនៃអនុវត្តច្បាប់និងគោលនយោបាយ គាំទ្រដល់ ការជួបប្រជុំដោយសន្តិវិធី | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថា អាជ្ញាធរដែនដីរាជធានីឬខេត្ត មានសមត្ថកិច្ចគួរតែទទួលខុសត្រូវក្នុងការការពារនៅបាតុកម្មដោយសន្តិវិធី និងមិនជ្រៀតជ្រែកនៅការធ្វើបាតុកម្មដោយសន្តិវិធីនេះ[206]។ អាជ្ញាធរមានសមត្ថកិច្ចឆ្លើយតបទៅនឹងសំណើសម្រាប់ជំនួយដល់អ្នករៀបចំបាតុកម្មដើម្បីធានាថា "សិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធីនិងការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈរបស់ពួកគេដោយមានសេចក្តីថ្លៃថ្នូរ"[207]។ ក្នុងករណីមានអំពើហឹង្សា សេចក្តីណែនាំឱ្យមានការអនុវត្តចែងយ៉ាងច្បាស់ថាបាតុកម្មអាចត្រូវបានបំបែកនៅពេលដែលគ្មានជម្រើសផ្សេងទៀត[208] បន្ថែមទៀតថារាល់សកម្មភាពរបស់នគរបាលត្រូវតែមានសមាមាត្រទៅនឹងស្ថានភាពហើយត្រូវបានប្រើក្នុងករណីចាំបាច់[209]។ |
| ១.២៧ អ្នករៀបចំការប្រមូលផ្តុំមិនទទួលខុសត្រូវលើបន្ទុកហិរញ្ញវត្ថុសម្រាប់ការផ្តល់សេវាសាធារណៈ | កម្រិតនៃក្របខណ្ឌច្បាប់ដែលការពារ អ្នករៀបចំ មិនឱ្យទទួលខុសត្រូវលើ ហិរញ្ញវត្ថុចំពោះការផ្តល់សេវាសាធារណៈ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីមិនបានចែងថា អ្នករៀបចំបាតុកម្មគឺទទួលខុសត្រូវចំពោះការគិតថ្លៃផ្នែកហិរញ្ញវត្ថុសម្រាប់ការផ្តល់សេវាសាធារណៈនោះទេ។ |

202 មាត្រា២១ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, សូមមើលផ្នែកទី៣ មាត្រា៤-៤-១ នៃសេចក្តីណែនាំឱ្យអនុវត្ត។

203 មាត្រា៩២ នៃច្បាប់ស្តីពីសហជីព។

204 មាត្រា៣៣៧ នៃច្បាប់ស្តីពីការងារ។

205 មាត្រា៩២ នៃច្បាប់ស្តីពីសហជីព។

206 មាត្រា១៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

207 មាត្រា១៨ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

208 ផ្នែកទី២ នៃចំណុច ៣.៦.៤ នៃសៀវភៅណែនាំការអនុវត្ត។

209 ផ្នែកទី២ នៃចំណុច ៣.៦.៥ នៃសៀវភៅណែនាំការអនុវត្ត។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១.២៨ អ្នករៀបចំការប្រមូលផ្តុំ និង អ្នកចូលរួមមិនទទួលខុសត្រូវចំពោះ ទង្វើខុសច្បាប់របស់អ្នកដទៃ ឬចំពោះការថែរក្សាសណ្តាប់ធ្នាប់សាធារណៈឡើយ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលអ្នករៀបចំ និង អ្នកចូលរួមមានទំនួលខុសត្រូវផ្លូវច្បាប់ចំពោះ ទង្វើខុសច្បាប់របស់អ្នកដទៃនិង/ឬ ចំពោះ ការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៤ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះ។ អ្នករៀបចំការជួបជុំមិនត្រូវមានទំនួលខុសត្រូវចំពោះការខូចខាតទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍មួយដែលបានប្រែជាអំពើហិង្សានោះឡើយ។ ក្នុងករណីមានការប្រជុំដោយសន្តិវិធីប្រែជាហិង្សាដូចដែលមានចែងក្នុងមាត្រា ២០ (២) នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី អ្នករៀបបាតុកម្មត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ។ មាត្រា ២៣ ដល់ ២៧ ចែងទាក់ទងនឹងការកាន់អាវុធ ឬសារធាតុគ្រោះថ្នាក់ ការខូចខាតទ្រព្យសម្បត្តិឯកជនឬសាធារណៈអំពើហិង្សាដែល បណ្តាលឱ្យមានរបួសឬស្លាប់។ ក្នុងករណីទាំងអស់នេះច្បាប់ចែងយ៉ាងច្បាស់ថាបុគ្គលដែលជាអ្នកធ្វើសកម្មភាពនោះជាអ្នកត្រូវទទួលខុសត្រូវ។ នេះមិនអាចចាត់ទុកថាជាការទទួលខុសត្រូវរបស់អ្នករៀបចំនិងអ្នកចូលរួមដ៏ទៃទៀតនោះទេ។ |
| ១.២៩ ការប្រើប្រាស់កម្លាំងរបស់រដ្ឋអាចធ្វើទៅបានលុះត្រាតែចាំបាច់ដើម្បីគ្រប់គ្រងស្ថានភាពក្នុងលក្ខណៈសមហេតុផល និង សមាមាត្រ | កម្រិតនៃក្របខ័ណ្ឌច្បាប់កំណត់ពីការប្រើប្រាស់កងកម្លាំងរបស់រដ្ឋនៅ ក្នុងស្ថានភាពដែលចាំបាច់ដើម្បីគ្រប់គ្រងស្ថានភាពក្នុងលក្ខណៈ សមហេតុផលនិងសមាមាត្រ | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | មិនមានចម្លើយ | ៤ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ប្រសិនបើការជួបប្រជុំដោយសន្តិវិធីប្រែជាហិង្សាអាជ្ញាធរត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់និងបញ្ឈប់ការធ្វើបាតុកម្មភ្លាមៗ[210]។ មាត្រា ២៣-២៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបង្ហាញពីរបៀបដែលអាជ្ញាធរគួរតែឆ្លើយតបប្រសិនបើបាតុកម្មប្រែទៅជាអំពើហិង្សាឬបាតុករប្រព្រឹត្តិបទឧក្រិដ្ឋ។ ការឆ្លើយតបរួមមានការរឹបអូសយកអាវុធ ផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។ ការអន្តរាគមន៍ណាមួយរបស់ប៉ូលីសត្រូវតែសមាមាត្រទៅនឹងស្ថានភាពហើយត្រូវបានប្រើតែក្នុងកម្រិតចាំបាច់ដើម្បីស្តារសណ្តាប់ធ្នាប់ភ្លាមៗ[211]។ លើសពីនេះទៅទៀតច្បាប់មិនបានចែងពីការប្រើប្រាស់កម្លាំងដោយអាជ្ញាធរទេ ទោះបីជាមិនបានហាមឃាត់យ៉ាងច្បាស់ក៏ដោយ។ |
| ១.៣០ ប្រព័ន្ធកត់ត្រាការប្រាស្រ័យទាក់ទង ដើម្បីឃ្លាំមើលបញ្ហា អ្នកទទួលខុសត្រូវលើការបញ្ជា និងអ្នកអនុវត្តបញ្ជាជាកាតព្វកិច្ច | កម្រិតនៃ ប្រព័ន្ធកត់ត្រាការប្រាស្រ័យ ទាក់ទងត្រូវបានបង្កើតឡើង ដោយក្របខ័ណ្ឌច្បាប់ | ការពិនិត្យ និងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | មិនមានចម្លើយ | ២ | ២ | ២ | ២ | ២ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីមិនចែងពីប្រព័ន្ធកំណត់ត្រាការប្រាស្រ័យទាក់ទងនោះទេ តែមាត្រា ១៩ ចែងថា "អាជ្ញា ធរដែលត្រូវបានចាត់ឱ្យរក្សាសន្តិសុខសុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈនៅកន្លែងបាតុកម្មប្រជុំដោយសន្តិវិធីត្រូវពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ ព្រមទាំងមានស្លាកឈ្មោះនិងអត្តលេខសម្គាល់ខ្លួននៅផ្នែកខាងមុខដែលលើកកម្ពស់គណនេយ្យភាពនិងសម្របសម្រួលការកំណត់អត្តសញ្ញាណអ្នកធ្វើខុស។ |

[210] មាត្រា២០(២) ២៣ ដល់២៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី

[211] ចំនុច ៣.៦.៥ នៃសៀវភៅណែនាំការអនុវត្ត

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១.៣១ ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងកូដកម្មស្របតាមស្តង់ដារអន្តរជាតិ | កម្រិតក្របខ័ណ្ឌច្បាប់ទាក់ទងនឹងកូដកម្មស្របតាមស្តង់ដារអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៣ | ៣ | កម្ពុជាមិនបានបំពេញតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិសម្រាប់កូដកម្មនោះទេ។ រដ្ឋធម្មនុញ្ញចែងពីសិទ្ធិធ្វើបាតុកម្មនៅមាត្រា ៣៧ មាត្រា ៤១ និង ៤២ និងបន្តការពារសិទ្ធិជួបប្រជុំនិងសិទ្ធិចូលរួម" ក្នុងអង្គការមហាជន" ដែលទាំងពីរនេះការពារដល់សិទ្ធិធ្វើកូដកម្ម។ ទោះយ៉ាងណាជំពូកទី៣ នៃរដ្ឋធម្មនុញ្ញអនុវត្តតែចំពោះ" ប្រជាពលរដ្ឋខ្មែរ" ជំនួសឱ្យសិទ្ធិទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ប្រទេសកម្ពុជា។ ដូចនេះការការពារសិទ្ធិធ្វើកូដកម្មនៅក្នុងរដ្ឋធម្មនុញ្ញគឺមិនគ្រប់គ្រាន់ទេសម្រាប់ពលរដ្ឋដែលមិនមែនជាពលរដ្ឋរស់នៅក្នុងប្រទេសកម្ពុជាដូចជាជនចំណាកស្រុកនិងជនភៀសខ្លួនជាដើម។ សិទ្ធិធ្វើកូដកម្មក្នុងជំពូកទី ១៣ នៃច្បាប់ស្តីពីការងារ[212] មាត្រា៣២០ បានចែងថាសិទ្ធិក្នុងការធ្វើកូដកម្ម "អាចអនុវត្តក្នុងលក្ខណៈទូទៅដើម្បីការពារផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គមរបស់កម្មករ"[213] ទោះយ៉ាងណាមាត្រា៣២៤ តម្រូវឱ្យ មានកូដកម្មជាច្រើនរួមទាំងការជូនដំណឹងជាមុន ៧ ថ្ងៃនៃថ្ងៃធ្វើការដល់សហគ្រាសឬគ្រឹះស្ថានសមាគមនិយោជកដែលដូចគ្នានឹងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការជូនដំណឹងមុនត្រូវបានបន្ថែមរហូតដល់១៥ ថ្ងៃ នៃថ្ងៃធ្វើការតាមរយៈមាត្រា៣២៧ ក្នុងករណីដែលកូដកម្មនោះប៉ះពាល់ដល់ផ្នែកសំខាន់ៗ។ ការជូនដំណឹងមុនត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវការទាមទារដែលជាមូលហេតុនៃកូដកម្ម។ ខណៈពេលដែលនីតិវិធីនៃការជូនដំណឹងជាមុនមិនមានការរំលោភបំពានដោយផ្ទាល់នៃស្តង់ដារអន្តរជាតិ រយៈពេលនៃការជូនដំណឹងមិនមែនជាហេតុផលសមរម្យនោះទេ[214]។គណៈកម្មាធិការខាងសេរីភាពខាងសមាគមបានកំណត់ថាការជូនដំណឹងជាមុន ៤៨ ម៉ោងគឺសមហេតុផលដូចជាការជូនដំណឹងជាមុន ២០ ថ្ងៃសម្រាប់សេវាកម្មផលប្រយោជន៍សាធារណៈ[215]។ ព័ត៌មានដែលបានស្នើសុំនៅក្នុងសេចក្តីជូនដំណឹងស្តីពីកូដកម្មគួរតែសមហេតុផលឬបកស្រាយក្នុងលក្ខណៈសមហេតុផលហើយការកាត់សេចក្តីជាលទ្ធផលមិនគួរត្រូវបានប្រើក្នុងលក្ខណៈដូចជាដើម្បីបង្ហាញសកម្មភាពសហជីពស្របច្បាប់ដែលស្ទើរតែមិនអាចធ្វើអ្វីបាននោះទេ[216]។ ដូច្នេះការជូនដំណឹងជាមុនដែលមានចែងក្នុងច្បាប់ស្តីពីការងារនឹងរំលោភលើស្តង់ដារអន្តរជាតិប្រសិនបើត្រូវអនុវត្តតាមទាំងបំពាន។ លើសពីនេះទៅទៀតនៅពេលដែលស្តង់ដារអន្តរជាតិអនុញ្ញាតឱ្យមានសិទ្ធិធ្វើកូដកម្មការកំណត់បែបនេះអាចទទួលយកបានលុះត្រាតែការពឹងផ្អែកលើអាជ្ញាកណ្តាលមិនមានកាតព្វកិច្ចហើយក្នុងករណីដែលការកំណត់នេះមិនអនុវត្តជាក់ស្តែងរារាំងការអំពាវនាវឱ្យធ្វើកូដកម្ម[217]។ មាត្រា៣២០ នៃច្បាប់ស្តីពីការងារកម្រិតលើសិទ្ធិក្នុងការធ្វើកូដកម្មនៅស្ថានភាពដែល" រាល់វិធីសាស្ត្រដោះស្រាយដោយសន្តិវិធីប្រើប្រាស់ក្នុងការដោះស្រាយវិវាទជាមួយនិយោជក" ។ បទប្បញ្ញត្តិនេះមិនអនុលោមតាមស្តង់ដារអន្តរជាតិដែលថាការចូលរួមក្នុងការដោះស្រាយវិវាទគួរតែជាការស្ម័គ្រចិត្ត។ បទប្បញ្ញត្តិនេះមិនបានអនុលោមតាមតាមស្តង់ដារអន្តរជាតិ ដែលការចូលរួមក្នុងការដោះស្រាយវិវាទគួរតែជាការស្ម័គ្រចិត្ត។ លើសពីនេះទៀតដោយកំណត់សិទ្ធិធ្វើកូដកម្មទៅនឹងស្ថានភាពដែលវិធីសាស្ត្រទាំងអស់ត្រូវបានប្រើប្រាស់ ដោយសន្តិវិធីច្បាប់ការងារមិនអនុលោមតាមស្តង់ដារអន្តរជាតិនោះទេ។ វាបង្កើតការរឹតត្បិតទូលំទូលាយទៅវិញ[218]។ លើសពីនេះទៀតមាត្រា ១៣ នៃច្បាប់សហជីពបាន |

[212] មាត្រា ៣១៩ នៃច្បាប់ស្តីពីការងារ។

[213] មាត្រា ៣២០ នៃច្បាប់ស្តីពីការងារ។

[214] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចរួមរបស់គណកម្មការធិការខាងសេរីភាពខាងសមាគម (បោះពុម្ពលើទី៦ការិយាល័យពលកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ២០១៨) កថាខណ្ឌ៧៩៩, "កាតព្វកិច្ចផ្តល់ការជូនដំណឹងមុនទៅនិយោជកមុនពេលរៀបចំកូដកម្មត្រូវបានពិចារណានិងទទួលយករហូតដល់មានហេតុផលសមរម្យ"។

[215] ដូចខាងលើ កថាខណ្ឌ៨០០ និង៨០១។

[216] ដូចខាងលើ កថាខណ្ឌ៨០៣។

[217] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចរួមរបស់គណកម្មការធិការខាងសេរីភាពខាងសមាគម (ឆ្នាំ២០១៨) កថាខណ្ឌ៧៩៣។

[218] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចនិងគោលការណ៍របស់គណៈកម្មាធិការខាងសេរីភាពខាងសមាគមនៃគណៈ អង្គការពលកម្មអន្តរជាតិ។ (បោះពុម្ពលើទី៥ការិយាល័យពលកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ២០០៦) កថាខណ្ឌ៥៤៧។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ចែងថាលក្ខន្តិកៈសហជីពទាំងអស់រួមមាន" លក្ខន្តិកៈដែលសន្លឹកឆ្នោតសំងាត់ត្រូវបានបោះឆ្នោតដោយយ៉ាងហោចណាស់៥០ភាគរយបូក១នៃសមាជិកសរុបដែលចូលរួមក្នុងការប្រជុំធ្វើសេចក្តីសម្រេចចិត្តធ្វើកូដកម្ម" ។ ហើយនេះជាការរឹតត្បិតហួសហេតុដែលជាចំនួនកំណត់ សិទ្ធិធ្វើកូដកម្មបានបន្ថយការការពារកូដកម្មនៅកម្ពុជា។ |
| សេរីភាពខាងការបញ្ចេញមតិ | | | | | | | | | |
| ១.៣២<br><br>ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ ផ្អែកតាមលក្ខខណ្ឌ ៣ ចំណុចយោងតាមមាត្រា ១៩ នៃ ក.អ.ស.ព.ន | កម្រិតនៃ ច្បាប់ដែលប៉ះពាល់សេរីភាពខាងការបញ្ចេញមតិ ផ្អែកតាមលក្ខខណ្ឌ ៣ ចំណុចពីមាត្រាទី ១៩ នៃ ក.អ.ស.ព.ន | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ១ | ១ | ច្បាប់សំខាន់ៗរបស់កម្ពុជាបានរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិដែលមិនអនុលោមទៅតាមលក្ខខណ្ឌបីចំណុចនៃមាត្រា១៩ នៃក.អ.ស.ព.ន។ ដូចេ្នះកម្ពុជាពុំបានបំពេញសូចនាករមួយនេះឡើយ[219] ។ ជាពិសេស ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការបរិហារកេរ្តិ៍ ការប្រមាថ ញុះញង់ និងកាលពីខែកុម្ភៈ ឆ្នាំ២០១៨ នៅបទល្មើសប្រមាថអង្គព្រះមហាក្សត្រ) ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ច្បាប់ស្តីពីទូរគមនាគមន៍ ច្បាប់ស្តីពីការអប់រំ ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបសារព័ត៌មាន និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅឆ្នាំ២០១៨ ដែលមិនអនុលោមតាមលក្ខខណ្ឌបីចំនុចនៃមាត្រា ១៩ (៣) នៃ ក.អ.ស.ព .ន[220]។ លើសពីនេះទៀត ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និង បណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអិនធឺណិតរឹតត្បិតលើសិទ្ធិសេរីភាពបញ្ចេញមតិ។ ការហាមឃាត់នៅក្នុងប្រកាសអន្តរក្រសួងគឺមានលក្ខណៈទូលំទូលាយពេក និងមិនច្បាស់លាស់សម្រាប់ប្រជាពលរដ្ឋដើម្បីកំណត់ថាតើខ្លឹមសារណាមួយដែលអនុញ្ញាតឬមិនអនុញ្ញាត។ លើសពីនេះទៅទៀតគោលបំណងនៃប្រកាសនេះមិនបានការពារសិទ្ធិនិងកេរ្តិ៍ឈ្មោះរបស់នរណាម្នាក់ឡើយ ឬដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈឬសុខភាពសាធារណៈ និងសីលធម៌។ ចុងក្រោយមានការផ្តន្ទាទោសសម្រាប់ការផ្សព្វផ្សាយ រួមមានបិទគេហទំព័រនិងចំណាត់ការផ្លូវច្បាប់ចំពោះបុគ្គលនិងនីតិបុគ្គល[221] ។ ការផ្តន្ទាទោសទាំងនេះមិនមែនជាមធ្យោបាយរឹតត្បិតដែលចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងនៃប្រកាសនេះ[222]។ មាត្រា៥ (១១) នៃច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចទៅរាជរដ្ឋាភិបាលក្នុងការហាមឃាត់ការនិយាយស្តីឬបញ្ចេញមតិដែលនាំឱ្យមាន "ភ័យស្លន់ស្លោឬវឹកវរឬនាំឱ្យខូចខាតដល់សន្តិសុខជាតិ" ឬអាច" បង្កការភាន់ច្រឡំ" ក្នុងចំណោមសាធារណជន។ ប្រភេទនៃការនិយាយទាំងនេះគឺមិនច្បាស់លាស់គ្មានការកំណត់និងរំលោភបំពាន។ ស្ទើរតែគ្រប់ប្រភេទនៃការបញ្ចេញមតិអំពីស្ថានភាពអាសន្នអាចត្រូវបានបកស្រាយថាជា" បង្កឱ្យមានការភ័ន្តច្រឡំ" ។ ការហាមឃាត់រាល់និយាយដែលអាចបង្ក" ភាព |

[219] មាត្រា២(១) នៃក.អ.ស.ព.ន តម្រូវឱ្យរដ្ឋភាគី ការគោរពនិងដើម្បីធានាដល់បុគ្គលទាំងអស់នៅក្នុងទឹកដីនិងក្រោមយុត្តាធិការរបស់ខ្លួននូវសិទ្ធិដែលបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ។ លើសពីនេះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថ្ងៃទី១០ខែកក្កដាឆ្នាំ ២០០៧ បានបកស្រាយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញថាសន្ធិសញ្ញាអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយកម្ពុជារួមមានអ.ស.ព.ន ត្រូវបានអនុវត្តនៅក្នុងច្បាប់ជាតិ។ សូមមើលសេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញលេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

[220] សូមអានសូមមើល "របាយការណ៍ប្រចាំឆ្នាំលើកទី១ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែសីហា ឆ្នាំ២០១៧) ទំព័រ ៧-៨ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf និងសូមអានសូមមើល "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៤ ដែលអាចរកបាន៖ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

[221] សូមអាន អាយ. ស៊ី .អិន.អិល "ការវិភាគប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលដំណើរការតាមប្រព័ន្ធអិនធឺណិត" ខែកក្កដា ឆ្នាំ២០១៨ ដែលអាចរកបាន៖ http://sithi.org/judicial/docs/ICNL-Analysis-Prakas-on-Websites-and-Social-Media_July-2018.pdf

[222] ដូចខាងលើ។ ទំព័រ៥ ដល់ទី៨ ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ច្របូកច្របល់” ឬ” ភាពរឹករឺ” មិនអាចត្រូវបានគេចាត់ទុកថាចាំបាច់នៅក្នុងភាពអាសន្នណាមួយឡើយ។ មាត្រា ៥ (១១) ដូច្នេះច្បាប់នេះនឹងស្របនឹងគោលការណ៍សមាមាត្រនៃ ក.អ.ស.ព.ន ឡើយ។ មាត្រា ១ នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ អនុញ្ញាតឱ្យបង្កើតរចនាសម្ព័ន្ធ ដែលអាចនាំឱ្យមានការរំលោភបំពានឯកជនភាព និងសេរីភាពខាងការបញ្ចេញមតិ។ មាត្រា១៨ដែលមិនមានភាពច្បាស់លាស់ ដែលអនុញ្ញាតការរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ មិនមានគោលបំណងស្របច្បាប់និងមិនសមាមាត្រ។ មាត្រា៦ នៃអនុក្រឹត្យនេះបានអនុញ្ញាតឱ្យអាជ្ញាធរអាចតាមដានទំនាក់ទំនងតាមអនឡាញ ក្នុងករណីមានការសង្ស័យថាមាតិកានោះអាច “ប៉ះពាល់ដល់សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ភាពថ្លៃថ្នូរ វប្បធម៌ ទំនៀមទំលាប់ប្រពៃណី”។ ការអនុញ្ញាតឱ្យមានការរាំងខ្ទប់មាតិកាប្រឆាំងនឹងគោលដៅដែលមិនបានកំណត់ជាក់លាក់ ដែលលើសពីភាពចាំបាច់។ ការរឹតត្បិតមកលើសេរីភាពខាងការបញ្ចេញមតិក្រោមអនុក្រឹត្យនេះមិនបានអនុវត្តតាមលក្ខខណ្ឌ៣ចំណុចនៃ ក.អ.ស.ន.ពនោះទេ។ [223] |
| ១.៣៣ ការនិយាយបង្ខូចកេរ្តិ៍មិនត្រូវមានទោស ព្រហ្មទណ្ឌទេ | កម្រិតនៃការបង្ខូចកេរ្តិ៍ត្រូវជាប់ទោស ព្រហ្មទណ្ឌ | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | មិនមាន ចម្លើយ | ២ | ២ | ២ | ១ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ ដូចមាត្រា៣០៥ និង៣០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានបទបរិហារកេរ្តិ៍និងការប្រមាថ។ ការបរិហារកេរ្តិ៍ត្រូវបានកំណត់ថា “ គ្រប់ការអះអាងបំផ្លើសឬ ទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសឬកិត្តិស័ព្ទនៃបុគ្គលឬស្ថាប័ន។ ការប្រមាថមានន័យថាពាក្យមើលងាយឬគ្រប់ពាក្យត្រគោះដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយគឺជាការប្រមាថ។ ការដាក់ទោសនៃការបរិហារកេរ្តិ៍នៅក្នុងច្បាប់ជាតិគឺមានបញ្ហាពីព្រោះនិយមន័យមិនច្បាស់លាស់ដោយមិនតម្រូវចាំឱ្យមានគ្រោះថ្នាក់ណាមួយកើតឡើងឡើយ។ ការដាក់ទោសនេះមិនបានការពារអំពីការពិតឬផលប្រយោជន៍សាធារណៈតម្រូវដោយច្បាប់និងបទដ្ឋានអន្តរជាតិនោះដែរ[224]។ លើសពីនេះទៀតក្នុងការអនុវត្ត ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ព្រហ្មទណ្ឌអាចប្រើលើបុគ្គល “ស្ថាប័ន” ដែលមិនបានគោរពតាមច្បាប់អន្តរជាតិ។ ខណៈដែលការពិន័យចំពោះការបរិហារកេរ្តិ៍ឬការជេរប្រមាថមិនបានបញ្ចូលទោសជាប់ពន្ធនាគារ ប៉ុន្តែបទល្មើសទាំងនេះត្រូវផ្តន្ទាទោសដោយការផាកពិន័យក្នុងក្រមព្រហ្មទណ្ឌ[225]។ លើសពីនេះនៅខែកុម្ភៈ ឆ្នាំ២០១៨ ការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌរួមទាំងមាត្រា ៤៣៧ស្ទួន "បទប្រមាថអង្គព្រះមហាក្សត្រ" ។ បទល្មើសនេះផ្ទុយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលចែងច្បាស់ថាបុគ្គលសាធារណៈត្រូវតែប្រឈមនឹងការរិះគន់កម្រិតខ្ពស់ ដោយគ្រាន់តែថាទម្រង់នៃការបញ្ចេញមតិបែបនេះត្រូវបានគេចាត់ទុកថាជាការប្រមាថដល់បុគ្គលសាធារណៈដែលគួរនឹងមានការដាក់ទណ្ឌកម្មនោះទេ[226]។ ការបំពានមាត្រានេះនាំឱ្យមានការពិន័យមិនស្មើគ្នាពោលគឺត្រូវជាប់ពន្ធនាគារពី ១ ឆ្នាំទៅ ៥ ឆ្នាំនិងពិន័យជាប្រាក់ពី ២ ទៅ ១០ លានរៀល។ មាត្រា ៧១ នៃ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា និងមាត្រា ៧១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក៏មានទោសព្រហ្មទណ្ឌចំពោះការបរិហារកេរ្តិ៍ដោយការរឹតត្បិតលើគណ |

[223] សូមមើលចំណុចគន្លឹះទី១។

[224] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ អនុសាសន៍ទូទៅលេខ៣៤ UN Doc. CCPR/C/GC/34, (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១), កថាខណ្ឌ៤៧, <https://www2.ohchr.org/english/bodies/hrc/docs/gc34.pdfhttps://bit.ly/1xmySgV>.

[225] សូមអាន “របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា” ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និង អាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៨ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

[226] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,‘អនុសាសន៍ទូទៅលេខ៣៤’ , UN Doc. CCPR/C/GC/៣៤, (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១), កថាខណ្ឌ៣៨ <https://www2.ohchr.org/english/bodies/hrc/docs/gc34.pdfhttps://bit.ly/1xmySgV>

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | បក្សនយោបាយនិងបេក្ខជនឬអ្នកគាំទ្រនៅពេលថ្លែងដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរថាបានប្រើពាក្យ "អសីលធម៌" ឬ "ប្រមាថ" ក្នុងអំឡុងពេលឃោសនាបោះឆ្នោត[227]។ ខណៈដែលច្បាប់អន្តរជាតិអនុញ្ញាតឱ្យមានការរឹតត្បិតក្នុងការប្រើប្រាស់ពាក្យពេចន៍ក្នុងពេលបោះឆ្នោត លក្ខណៈមិនច្បាស់នៃបទប្បញ្ញត្តិនេះមិនត្រូវបានគោរពតាមស្តង់ដារអន្តរជាតិនោះទេ ពីព្រោះច្បាប់នេះផ្តល់ឱកាសឱ្យមានការរំលោភបំពាន- ការមិនយល់ស្របជាមួយគណបក្សនយោបាយអាចត្រូវបានកំណត់ថាជា"អំពើអសីលធម៌ឬប្រមាថ"[228]។ មាត្រា ៧១ បានចែងទាំងការពិន័យជាប្រាក់និងការលុបបេក្ខភាព។ ការពិនិត្យឡើងវិញនៃសូចនាករនេះត្រូវបានធ្វើនៅក្នុងឆ្នាំទី៥ ហើយខណៈពេលដែលគ្មានការវិវឌ្ឍន៍ផ្នែកច្បាប់ពិន្ទុនេះត្រូវបានទម្លាក់មកត្រឹម ១ ពិន្ទុនៅពេលធ្វើការវាយតម្លៃឡើងវិញ។ នេះត្រូវបានគេរកឃើញពិន្ទុចំនួន ២ ដោយសារបទបរិហារកេរ្តិ៍មិនអនុវត្តទោសជាប់ពន្ធនាគារតាមក្រមព្រហ្មទណ្ឌទោះយ៉ាងណាសេចក្តីផ្តើមនៃការប្រព្រឹត្តបទល្មើស"ច្បាប់ប្រមាថអង្គព្រះមហាក្សត្រ" ក្នុងឆ្នាំទី៣ ផ្តន្ទាទោសដាក់ពន្ធនាគារដោការដាក់ទោសចំពោះទិដ្ឋភាពនៃបទបរិហារកេរ្តិ៍នេះ។ |
| ១.៣៤ ច្បាប់ការពារប្រឆាំងនឹងបណ្តឹងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ | តម្រូវឱ្យមានច្បាប់ដែលហាមឃាត់ការប្រើប្រាស់បណ្តឹងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១ | ១ | កម្ពុជាខកខានបំពេញតាមធាតុផ្សំនេះ ។ បច្ចុប្បន្ននេះមិនមានច្បាប់ដែលបានអនុម័ត បទបញ្ញត្តិឬគោលនយោបាយហាមឃាត់បណ្តឹងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ និងមិនមានបទល្មើសឬការដាក់ទណ្ឌកម្មសម្រាប់បុគ្គលឬនីតិបុគ្គលដែលដាក់ពាក្យបណ្តឹងនោះទេ។ លើសពីនេះក្រមព្រហ្មទណ្ឌមានបទល្មើសជាច្រើនដែលត្រូវបានកំណត់ដោយមិនច្បាស់លាស់រួមទាំងការបរិហារកេរ្តិ៍ដែលមិនគោរពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិហើយដូច្នេះធ្វើឱ្យការប្រើប្រាស់បណ្តឹងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈនៅក្នុងប្រទេសកម្ពុជាកើតមានញឹកញាប់។ |
| ១.៣៥ ការតាមដានមកលើការប្រាស្រ័យទាក់ទងអាចធ្វើបានក្រោយពេលមានការត្រួតពិនិត្យពីតុលាការតែប៉ុណ្ណោះ | តម្រូវឱ្យមានច្បាប់ដែលធានាថាការតាមដានមកលើការប្រាស្រ័យទាក់ទងអាចធ្វើបានក្រោយពេលមានការត្រួតពិនិត្យពីតុលាការតែប៉ុណ្ណោះ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ១ | ១ | ច្បាប់កម្ពុជាពុំបានបំពេញតាមចំណុចនេះទេ។ ច្បាប់ស្តីពីទូរគមនាគមន៍ដែលបានប្រកាសឱ្យប្រើនៅឆ្នាំ២០១៦ បានផ្តល់អំណាចទូលាយឱ្យរដ្ឋាភិបាលនូវក្នុងការតាមដានទូរគមនាគមន៍ដោយគ្មានការត្រួតពិនិត្យពីប្រព័ន្ធតុលាការឬស្ថាប័នឯករាជ្យផ្សេងទៀត។ មាត្រា ៦ ចែងថា "ប្រតិបត្តិករទូរគមនាគមន៍និងអ្នកដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ត្រូវផ្តល់ឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នូវទិន្នន័យសេវាកម្មបច្ចេកវិជ្ជាទូរគមនាគមន៍ព័ត៌មាននិងទិន្នន័យសេវាទូរគមនាគមន៍"។ យោងតាមបទបញ្ញត្តិនេះប្រតិបត្តិករទូរគមនាគមន៍ចាំបាច់ត្រូវឆ្លងការពិនិត្យពីតុលាការឬស្ថាប័នឯករាជ្យឡើយ។ ពាក្យថា "ទិន្នន័យសេវា" មិនត្រូវបានកំណត់នៅក្នុងច្បាប់ទេហើយអាចត្រូវបានបកស្រាយគ្រប់ប្រព័ន្ធបញ្ចូលការកំណត់ត្រាទំនាក់ទំនងអ្នកប្រើទាំងអស់ ប្រវត្តិស្វែងរក និងព័ត៌មានសម្ងាត់ផ្សេងទៀត។ នេះក៏រំលោភលើមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញដែលធានានូវសិទ្ធិរក្សាការសម្ងាត់។ មាត្រា៩៧ ច្បាប់ស្តីពីទូរគមនាគមន៍ចែងអំពីការលួចស្តាប់ ថតសម្លេងការសន្ទនាបានលុះត្រាតែមានការអនុញ្ញាតពី"អាជ្ញាធរជម្មានរូប" ហើយការផ្សព្វផ្សាយពីកិច្ចសន្ទនាទាំងនោះក៏ចាំបាច់មានត្រូវមានការអនុញ្ញាតពី"អាជ្ញាធរជម្មានរូប"។ បទបញ្ញត្តិទាំងនេះមានលក្ខណៈទូលាយងាយស្រួលក្នុងការបំពានព្រោះពួកគេអនុញ្ញាតឱ្យមានការឃ្លាំមើលដោយគ្មានគណនេយ្យភាពសាធារណៈឬការការពារសុវត្ថិភាព។ ស្រដៀងគ្នានេះច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ ២០១០ បានផ្តល់អំណាចដល់អង្គភាពដោយ |

[227] យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល២១ថ្ងៃ (មាត្រា៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា) និងរយៈពេល១៤ថ្ងៃសំរាប់ការបោះឆ្នោតឃុំ-សង្កាត់ (មាត្រា៧០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់)។

[228] សហភាពអឺរ៉ុប, របាយការណ៍បញ្ចប់បេសកកម្មការត្រួតពិនិត្យនៅកម្ពុជា ឆ្នាំ២០១៥ <https://eeas.europa.eu/sites/eeas/files/efm_cambodia_2015_final_report_publ.pdf>

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់តុលាការ[229]។ មាត្រាទី២៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយត្រូវបានអនុញ្ញាតឱ្យ "ឃ្លាំមើល ត្រួតត្រាស្តាប់សម្លេង ថតចម្លងនិងថតរូបនិងថតសម្លេងទូរស័ព្ទ" ដែលមានព័ត៌មានច្បាស់លាស់នៃអំពើពុករលួយ។ ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សាយតាមគេហទំព័រនិងបណ្តាញសង្គមបានបរាជ័យនៅក្នុងសូចនាករនេះដោយសារការបង្កើត "ក្រុមការងារតាមដាន" រួមគ្នាជាមួយតំណាងក្រសួងដើម្បី "ត្រួតពិនិត្យ" និងចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងការផ្សព្វផ្សាយខុសច្បាប់នៅលើគេហទំព័រនិងប្រព័ន្ធផ្សព្វផ្សាយសង្គម។ មិនមានការនិយាយពីការត្រួតពិនិត្យតាមនីតិវិធីតុលាការឡើយ[230]។ មាត្រា ១ នៃ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិអនុញ្ញាតឱ្យបង្កើតរចនាសម្ព័ន្ធដែលជួយសម្រួលដល់ការតាមដានលើការចែករំលែកព័ត៌មានឬសកម្មភាពតាមអនឡាញ រួមទាំងទំនាក់ទំនងឯកជន ដោយមិនមានការបញ្ជាពីតុលាការ។ |
| ១.៣៦<br><br>សិទ្ធិទទួលព័ត៌មាន ត្រូវបានការពារ និងលើកកម្ពស់ | កម្រិតនៃក្របខណ្ឌច្បាប់ ការពារ និងលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ១ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ ពីព្រោះសិទ្ធិទទួលព័ត៌មានមិនត្រូវបានការពារដោយច្បាប់ឡើយ[231]។ ទោះយ៉ាងណា រដ្ឋាភិបាលកំពុងធ្វើការលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ ច្បាប់ជាច្រើនមានឥទ្ធិពលទៅលើសិទ្ធិទទួលព័ត៌មានរួមមានច្បាប់ស្តីពីរបបសារព័ត៌មាននិងក្រមព្រហ្មទណ្ឌ។ ច្បាប់ស្តីពីរបបសារព័ត៌មានហាមឃាត់និងផ្តន្ទាទោសការបោះពុម្ពផ្សាយនូវការបញ្ចេញមតិជាច្រើន។ មាត្រា ១២ នៃច្បាប់នេះបង្កើតឱ្យមានការរឹតត្បិតលើរាល់ព័ត៌មាន ដែលអាចប៉ះពាល់ដល់សន្តិសុខជាតិនិងស្ថេរភាពនយោបាយ តែមិនតម្រូវថាទាល់តែមានទំនាក់ទំនងរវាងការបោះពុម្ពផ្សាយ និងហានិភ័យនៃគ្រោះថ្នាក់ឡើយ។ នេះបង្ហាញពីការខកខានក្នុងការការពារសិទ្ធិទទួលព័ត៌មាន។ បទល្មើសនៃការ "ក្លែងព័ត៌មាន" ក្រោមមាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានដាក់ជាបទល្មើសព្រហ្មទណ្ឌនូវអំពើដែលផ្តល់ឬបើកកកាយព័ត៌មានក្លែងដើម្បីធ្វើឱ្យជឿថា នឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូតខាត ប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស។ ការប្រើប្រាស់ពាក្យដែលមានន័យទូលំទូលាយ មិនច្បាស់លាស់នៃបទល្មើសបែបនេះបណ្តាលឱ្យមានការអនុវត្តច្របូកច្របល់ ដល់ការបញ្ចេញមតិដែលមិនមែនក្លែងក្លាយ ឬ ព័ត៌មានដែលជាមតិយោបល់។ នេះនឹងបង្កើនវិសាលភាពច្បាប់លើសពីកម្រិតនៃការរឹតត្បិតលើសេរីភាពនៃការបញ្ចេញមតិដែលត្រូវបានអនុញ្ញាត។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ ២ ឆ្នាំនិងពិន័យជាប្រាក់ពី ២ ទៅ ៤ លាន រៀល ការពិន័យនេះមើលទៅដូចជាមិនសមាមាត្រចំពោះសកម្មភាពព្រហ្មទណ្ឌទាល់តែសោះ។ ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចដល់រាជរដ្ឋាភិបាលក្នុងការហាមឃាត់ឬរឹតត្បិតការចែករំលែកឬប្រព័ន្ធផ្សព្វផ្សាយ[232] ដែលរារាំងសិទ្ធិក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មានក្នុងពេលមានអាសន្ន។ ច្បាប់នេះអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដាក់រឹតត្បិតលើព័ត៌មាន ដែលអាចរារាំងដល់ការរាយការណ៍ប្រកបដោយតម្លាភាព ធ្វើឱ្យខូចខាតដល់ប្រជាពលរដ្ឋ ។ មាត្រា៦ នៃ អនុក្រឹត្យស្តីពីការបង្កើតច្រក |

[229] សូមអាន "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និង អាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៤ ដែលអាចរកបាន៖ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

[230] ប្រកាសអន្តរ, ចំណុចទី៤ សូមមើល កាន់ វិច្ឆិកា, 'កម្ពុជាបង្កើតក្រុមការងារតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយតាមប្រព័ន្ធផ្សព្វផ្សាយនិងបណ្តាញសង្គម' (វីអូអេ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៨), <https://www.voacambodia.com/a/cambodia-forms-task-force-to-monitor-fake-news-on-social-media/4425534.html>

[231] ខែមីនា ឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានបញ្ជាក់ថាសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។ សូមមើល ខ្មែរថាមស៍ 'ការត្រៀមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន', (ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩) ដោយ តាំងវីដា https://www.khmertimeskh.com/50577422/access-to-information-draft-law-ready/ ។ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន អាចរកបាននៅ https://www.phnompenhpost.com/Assets/doc/Doc-Jan-31-2018-15-30-en.pdf

[232] មាត្រា ៥ (១១) នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ទ្វារអ៊ីនធឺណិតជាតិអនុញ្ញាតឱ្យមានការបិទខ្ទប់ និងផ្ដាច់មាតិកាអនឡាញទាំងឡាយណាដែលអាជ្ញាធរគិតថាប៉ះពាល់ដល់ "សុវត្ថិភាពចំណូលរបស់រដ្ឋ សណ្ដាប់ធ្នាប់សាធារណៈ ភាពថ្លៃថ្នូរ វប្បធម៌ ទំនៀមទំលាប់ប្រពៃណី" ដែលនេះនាំឱ្យមានការរឹតត្បិតមកលើមាតិកាទាំងនោះរួមទាំងមាតិកាដែលមិនមានកំហុសដែលចាត់ទុកថាជំទាស់នឹងគោលបំណងទាំងនេះ។ [233] |
| ១.៣៧<br><br>សិទ្ធិប្រើប្រាស់អ៊ិនធឺណិតមិនអាចត្រូវបានកាត់ផ្ដាច់តាមអំពើចិត្តនោះទេ | កម្រិតនៃសិទ្ធិប្រើប្រាស់អ៊ីនធឺណិត ត្រូវបានធានាដោយច្បាប់ និង ការពារពីការរឹតត្បិតតាមអំពើចិត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | ៣ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ។ ខណៈដែលគ្មានបទប្បញ្ញត្តិផ្តល់អំណាចដល់រដ្ឋាភិបាលអាចបិទប្រព័ន្ធអ៊ិនធើណិត មាត្រា៧ នៃច្បាប់ស្ដីពីទូរគមនាគមន៍អាចនាំឱ្យមានអនុវត្តតាមអំពើចិត្តដើម្បីបិទអ៊ីនធើណិតបាន។ មាត្រា៧ នៃច្បាប់ស្ដីពីទូរគមនាគមន៍ចែងថា "ក្នុងករណីដែលមានភាពមិនប្រក្រតី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួងឬស្ថាប័នដែលមានសមត្ថកិច្ចអាចបញ្ជាឱ្យប្រតិបត្តិករទូរគមនាគមន៍ពាក់ព័ន្ធចាត់វិធានការចាំបាច់ដោយផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល" ។ បន្ថែមពីនេះក៏បានផ្តល់ឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្រោមមាត្រា២៤ ដែលចែងថា "របនាសម្ព័ន្ធទូរគមនាគមន៍ និងបណ្ដាញទូរគមនាគមន៍ និងរចនាសម្ព័ន្ធគាំទ្រដល់ទូរគមនាគមន៍នឹងស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍" ។ ក្រោមបទប្បញ្ញត្តិទាំងនេះ រដ្ឋាភិបាលទំនងជាទទួលបានការត្រួតពិនិត្យគ្រប់ឧស្សាហកម្មទូរគមនាគមន៍រួមមានសកម្មភាពនិងហេដ្ឋារចនាសម្ព័ន្ធ។ ក្រុមការងារពិសេសដែលបង្កើតឡើងដោយប្រកាសអន្តរក្រសួងក៏មានអំណាចផ្ដាច់សេវាប្រព័ន្ធអ៊ិនធឺណេតដោយមិនចាំបាច់មានការត្រួតពិនិត្យពីតុលាការដើម្បីទប់ស្កាត់ការអនុវត្តន៍តាមអំពើចិត្តឡើយ[234]។ អនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិអនុញ្ញាតឱ្យមានការបង្កើតរចនាសម្ព័ន្ធដែលប្រមូលផ្ដុំការគ្រប់គ្រងប្រព័ន្ធអ៊ីធឺណិតរបស់រាជរដ្ឋាភិបាល[235]។ ហើយនេះ ក៏បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការកាត់ផ្ដាច់អ៊ិនធឺណិត។[236] |
| **ចំណុចគន្លឹះទី២៖ ក្របខណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិត្រូវបានអនុវត្តនិងប្រត្តិបត្តិតាមត្រឹមត្រូវឬទេ ?** | | | | | | | | | |
| **ធាតុផ្សំ** | **សូចនាករ** | **ប្រភពទិន្នន័យ** | **ឆ្នាំទី១** | **ឆ្នាំទី២** | **ឆ្នាំទី៣** | **ឆ្នាំទី៤** | **ឆ្នាំទី៥** | **ឆ្នាំទី៦** | ***កំណត់សម្គាល់*** |
| ២.១<br><br>ស្ថាប័នរដ្ឋាភិបាលយល់ពីសិទ្ធិ និងកាតព្វកិច្ចទាក់ទិននឹង សេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | % នៃការថ្លែងតាមប្រព័ន្ធផ្សព្វផ្សាយបង្ហាញឱ្យឃើញពី ការយល់ច្រឡំ ឬការបង្ហាញខុសអំពីសេរីភាពខាងការបង្កើត សមាគមជួបប្រជុំ និងបញ្ចេញមតិរបស់តំណាងរដ្ឋាភិបាល | ការតាមដានតាមប្រព័ន្ធ<br><br>ផ្សព្វផ្សាយ | ៤៨% | ២៣% | ១៥% | ១៤% | ៧៤% | ៨៧% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ១៥ ករណីថ្លែង ក្នុងចំណោមនោះ១៣នៃការលើកឡើងរបស់មន្ត្រីរដ្ឋាភិបាលបង្ហាញពីការការយល់ច្រឡំឬការបង្ហាញខុស។ |

[233] សូមមើលចំណុចគន្លឹះទី១។
[234] ប្រកាសអន្តរក្រសួងស្ដីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គម ប្រការ ៤ ។
[235] មាត្រា១នៃអនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិ។
[236] សូមមើលចំណុចគន្លឹះទី១។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២.២ អជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | # របាការណ៍បន្ថែមឱ្យឃើញថាអជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ០ | ១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា១ ករណី ដែលអាជ្ញាធរឬភាគីទីបីដែលត្រូវទទួលខុសត្រូវចំពោះការរំលោកបំពានឡើយ។ |
| | # របាការណ៍បន្ថែមឱ្យឃើញថាអជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍មិនបានកត់ត្រានូវករណីណាមួយរបស់អជ្ញាធរឬភាគីទីបីដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានឡើយ។ |
| ២.៣ សេរីភាពអាចអនុវត្តដោយគ្មានជ្រៀតជ្រែក និងគំរាមកំហែង | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានកោះហៅសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១៩៩ | ៦៦ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៦៦ ករណីនៃការកោះហៅ។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានកោះហៅសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១៦ | ៦ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៦ ករណីដែលត្រូវបានកោះហៅ។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានសាកសួរសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១១៥ | ១៣៧ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ១៣៧ ករណីដែលត្រូវបានសាកសួរ។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានសាកសួរសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ២ | ២៦ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ២៦ ករណីដែលត្រូវបានសាកសួរ។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានឃាត់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១១៤ | ១១៩ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា១១៩ករណីដែលត្រូវបានឃុំខ្លួន។ |
| | # នៃបុគ្គលម្នាក់ៗបានឃាត់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ២ | ០ | ការរាយការណ៍ពីហេតុការណ៍មិនបានកត់ត្រាករណីដែលត្រូវបានឃុំខ្លួន។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវធ្វើសេចក្តីយល់ព្រមដោយរដ្ឋាភិបាលដើម្បីចុះហត្ថលេខា និងផ្តិតមេដៃលើលិខិតយល់ព្រម | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៥៤ | ៥៨ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានកត់ត្រា ៥៨ ករណីដែលត្រូវបានធ្វើសេចក្តីយល់ព្រម ចុះហត្ថលេខា និងផ្តិតមេដៃ។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | # នៃបុគ្គលម្នាក់ៗត្រូវធ្វើសេចក្តីយល់ព្រមដោយរដ្ឋាភិបាលដើម្បីចុះហត្ថលេខា និងផ្តិតមេដៃលើលិខិតយល់ព្រមសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៣ | ១ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា១ ករណីដែលត្រូវធ្វើសេចក្តីយល់ព្រមចុះហត្ថលេខា និងផ្តិតមេដៃ។ |
| | # នៃបុគ្គលម្នាក់ៗនិងអង្គភាពបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានកាត់ទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៥២ | ៦០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៦០ ករណីដែលបានកាត់ទោស។ |
| | # នៃបុគ្គលម្នាក់ៗនិងអង្គភាពត្រូវបានកាត់ទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១ | ១ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ១ ករណីដែលបានកាត់ទោស។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានចាប់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៨១ | ១៣៨ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ១៣៨ ករណីដែលបានចាប់ខ្លួន។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានចាប់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១ | ០ | ការរាយការណ៍ពីហេតុការណ៍មិនបានកត់ត្រាករណីដែលត្រូវបានចាប់ខ្លួន។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១៦ | ៧២ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៧២ ករណីដែលត្រូវបានផ្តន្ទាទោស។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលផ្តន្ទាទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១ | ០ | ការរាយការណ៍ពីហេតុការណ៍មិនបានកត់ត្រាករណីដែលត្រូវបានផ្តន្ទាទោស។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាលសម្រាប់ការអនុវត្តសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១ | ២១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ២១ ករណី បុគ្គលឬអង្គភាពណាមួយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាល។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពណាមួយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាលក្នុងការអនុវត្តសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ០ | ១ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ១ ករណី អំពីបុគ្គលឬអង្គភាពណាមួយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាល ។ |
| សេរីភាពខាងការបង្កើតសមាគម | | | | | | | | | |
| ២.៤ ស្ថាប័នរដ្ឋាភិបាល គោរពសិទ្ធិ កាតព្វកិច្ច | # រាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែលបង្ហាញថារដ្ឋាភិបាល គោរពសិទ្ធិ កាតព្វកិច្ចនិងការប្រើប្រាស់សេរីភាពខាងការបង្កើត | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | ២០២ | ៣៣ | ៣៣ | ៣ | ១ | ១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាសេចក្តីថ្លែងការណ៍មួយរបស់អាជ្ញាធរ ដែលបង្ហាញការយល់ដឹងមិនត្រឹមត្រូវអំពីសេរីភាពខាងសមាគម។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| និងការប្រើប្រាស់សេរីភាពខាងការបង្កើតសមាគម | | | | | | | | | |
| | # ករណីរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ដែលរដ្ឋាភិបាលរំលោភលើសេរីភាពខាងការបង្កើតសមាគម | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៦១ | ៧០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៧០ ករណីនៃឧប្បត្តិហេតុដែលស្ថាប័នរដ្ឋាភិបាលបានរំលោភលើសេរីភាពខាងសមាគម។ |
| | # ចំនួនហេតុការណ៍ ដែលរដ្ឋាភិបាល រំលោភលើសេរីភាពខាងការបង្កើតសមាគម | ការរាយការណ៍ពីហេតុការណ៍ | ១១៤ | ១២២ | ១០១ | ៤៨ | ៤៣ | ៥០ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៥០ ករណីនៃឧប្បត្តិហេតុដែលស្ថាប័នរដ្ឋាភិបាលបានរំលោភលើសេរីភាពខាងសមាគម។ |
| ២.៥ ការចុះបញ្ជីសមាគមត្រូវបានអនុវត្តដោយយុត្តិធម៌ និងតម្លាភាព | កម្រិតនៃ ដំណើរការចុះបញ្ជីសមាគមត្រូវបានអនុវត្តដោយយុត្តិធម៌និងតម្លាភាព | ការតាមដានពីនីតិវិធីចុះបញ្ជីអង្គការសមាគម | មិនមានចម្លើយ | ១ | ១ | មិនមានចម្លើយ | ២ | ៣ | នៅក្នុងឆ្នាំទី៦នេះ ដំណើរការចុះបញ្ជីមានចំនួនតែ៣ សហជីពប៉ុណ្ណោះ ។ សហជីពទាំង ៣ នេះក៏បានចុះបញ្ជីដោតជ័យផងដែរ។ |
| ២.៦ មានសមាគមច្រើនដែលគោលបំណងស្រដៀងគ្នា | # ពាក្យសុំចុះបញ្ជីត្រូវបានបដិសេធ ដោយសារតែមានសមាគមច្រើនដែលមានគោលបំណងស្រដៀងគ្នា | ការរាយការណ៍ពីហេតុការណ៍ | ១ | ១ | ០ | ០ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាថាពុំមានករណីណាមួយដែលលិខិតចុះបញ្ជីត្រូវបានបដិសេធដោយសារតែមានសមាគមជាច្រើនដែលមានរួចស្រាប់ដែលមានគោលដៅស្រដៀងៗគ្នា។ |
| | | ការតាមដានពីនីតិវិធីចុះបញ្ជីអង្គការសមាគម | មិនមានចម្លើយ | ០ | ០ | ០ | ០ | ០ | ឧបករណ៍វាយតម្លៃការចុះបញ្ជីអង្គការសមាគមមិនបានកត់ត្រាករណីបដិសេធចុះបញ្ជីដោយសារមូលហេតុបែបនេះទេ។ |
| ២.៧ សមាគមអាចបង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីពដោយសេរី | % នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ អំពីការជៀតជ្រែក មកលើគោលបំណង បង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៣៨% | ៤៤% | ៤១% | ២៦% | ២៦% | សូមមើលសំណួរ៤.១ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | # ហេតុការណ៍ ដែលមានការ ជ្រៀតជ្រែកមកលើគោល បំណង សមាគមក្នុងការបង្កើតបណ្ដាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព | ការរាយការណ៍ពីហេតុការណ៍ | ០ | ១៤ | ០ | ៣ | ២ | ១ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ១ ករណីនៃការជ្រៀតជ្រែកដែលសមាគមប៉ុនប៉ងដើម្បីបង្កើតបណ្តាញសម្ព័ន្ធ សហព័ន្ធសហជីព ឬប្រភេទផ្សេងទៀតនៃសហជីព។ |
| ២.៨ សមាជិកនៃអង្គការសមាគមសម្ព័ន្ធសហព័ន្ធមានសិទ្ធិដកខ្លួនចេញបាន | % នៃថ្នាក់ដឹកនាំសមាគមបានរាយការណ៍អំពីល័ក្ខខណ្ឌដកខ្លួនចេញពីសមាជិក | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | សូចនាករនេះនឹងត្រូវបានតាមដានចាប់ផ្តើមនៅឆ្នាំទី ៧។ |
| ២.៩ សមាគមដំណើរការដោយពុំមានការជ្រៀតជ្រៀកពីរដ្ឋាភិបាល | % នៃថ្នាក់ដឹកនាំសមាគមបានរាយការណ៍អំពីការជ្រៀតជ្រែងលើសលុបពីសំណាក់រដ្ឋាភិបាលក្នុងឆ្នាំមុន | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៧៦% | ៧៤% | ៧៩% | ៧៥% | ៦៧% | សូមមើលសំណួរ៤.៥ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # ហេតុការណ៍ដែលរដ្ឋាភិបាលជ្រៀតជ្រែកមកលើសមាគម រំលោភលើបទដ្ឋានអន្តរជាតិ បង្ហាញក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | ១៨៨ | ១៨៤ | ៤៣ | ១០៤ | ៥៦ | ៤៣ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៤៣ ករណី នៃការត្រួតត្រារបស់រដ្ឋាភិ បាលលើសមាគមដែលជាការរំលោភលើស្តង់ដារអន្តរជាតិ។ |
| | # ហេតុការណ៍ដែលរដ្ឋាភិបាលជ្រៀតជ្រែកមកលើសមាគម រំលោភលើបទដ្ឋានអន្តរជាតិបង្ហាញក្នុងការរាយការណ៍ហេតុការណ៍ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៣៥ | ៣៦ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៣៦ករណី នៃការត្រួតត្រារបស់រដ្ឋាភិបាលលើសមាគមដែលជាការរំលោភលើស្តង់ដារអន្តរជាតិ។ |
| ២.១០ បុគ្គលពុំបានក្លាយ | %នៃបុគ្គលដែលរាយការណ៍អំពីការក្លាយជាជនរងគ្រោះដោយសារតែការចូល | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការ | ៣% | ៣៥% | ៣៦% | ៣០% | ២៦% | ២៤% | សូមមើលសំណួរ៥.៦ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ជាគោលដៅដោយសារតែការចូលរួមជាមួយសមាគមនោះទេ។ | | សង្គមស៊ីវិលនិងសហជីព | | | | | | | |
| | %នៃបុគ្គលដែលរាយការណ៍អំពីការក្លាយជាជនរងគ្រោះដោយសារតែការចូលរួមជាមួយសមាគម | ការស្ទង់មតិជាសាធារណៈ | មិនមានចម្លើយ | ១៤% | ១៩% | ២៥% | ២៦% | ២២% | សូមមើលសំណួរ៣.៤ នៃការស្ទង់មតិសាធារណៈ។ |
| ២.១១ សមាគមត្រូវបានការពារពីការជ្រៀតជ្រែករបស់ភាគីទីបី។ | % នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ការជ្រៀតជ្រែកពីភាគីទីបី | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ២៣% | ២៥% | ១៧% | ១៤% | ៨% | ១៦% | សូមមើលសំណួរ៤.៧ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # នៃហេតុការណ៍របស់ជនទីបីបានជ្រៀតជ្រែកសមាគម | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ២៤ | ៣៥ | ១០ | ១៥ | ១៤ | ២៥ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ២៥ ករណី ដែលបង្ហាញថាសមាគមត្រូវបានរំខានធ្វើទុក្ខបុកម្នេញដោយភាគីទីបី។ |
| | # នៃហេតុការណ៍របស់ជនទីបីបានជ្រៀតជ្រែកសមាគម | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៨ | ១៤ | ១២ | ២២ | ១៩ | ការរាយការណ៍ហេតុការណ៍បានកត់ត្រា ១៩ ករណី ដែលបង្ហាញថាថ្នាក់ដឹកនាំសមាគមត្រូវបានរំខានធ្វើទុក្ខបុកម្នេញដោយភាគីទីបី។ |
| ២.១២ សមាគមមិនប្រឈមនឹងលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលជាបន្ទុក និងស្មុគស្មាញ | % នៃថ្នាក់ដឹកនាំសមាគមដែលប្រឈមនឹងលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលជាបន្ទុក និងស្មុគស្មាញ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៦០% | ៥៨% | ៦០% | ៦០% | ៤៥% | សូមមើលសំណួរ៤.១២ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| ២.១៣ ការដាក់ទណ្ឌកម្មលើសមាគមត្រូវបានអនុ | # ការរាយការណ៍ហេតុការណ៍ដែលការដាក់ទោសដោយពុំបានអនុវត្តស្របទៅតាមច្បាប់របស់កម្ពុជា | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ១២ | ១ | ០ | ០ | ០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយមិនបានកត់ត្រារាល់ករណីនៃការដាក់ទណ្ឌកម្មលើសមាគមណាមួយដែលមិនត្រូវបានអនុវត្តស្របតាមច្បាប់កម្ពុជាឡើយ។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វត្តស្របតាមច្បាប់របស់កម្ពុជា | | | | | | | | | |
| | # ការរាយការណ៍ហេតុការណ៍ដែលការទណ្ឌកម្មដោយពុំបានអនុវត្តស្របទៅតាមច្បាប់ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៣ | ០ | ០ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍ពុំបានកត់ត្រាករណី នៃការដាក់ទណ្ឌកម្មលើស្ថាប័ន សមាគម ដោយពុំបានអនុវត្តស្របទៅតាមច្បាប់របស់កម្ពុជា។ |
| ២.១៤ សមាគមបានឧបាស្រ័យប្រសិនបើពួកគេត្រូវបានដាក់ទោស | % នៃថ្នាក់ដឹកនាំសមាគមយល់ការណ៍ថាអាចទទួលបានទោសព្រហ្មទណ្ឌនិងផ្លូវច្បាប់ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៥០% | ៤២% | ៩% | ៣២% | ២០% | ៨៣% | សូមមើលសំណួរ៤.១៩ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។<br>ចំនួនឆ្លើយតបតិចតួចចំពោះសំណួរនេះមានន័យថាមានភាពប្រសើរឡើងពី១ឆ្នាំទៅ១ឆ្នាំ។ |
| ២.១៥ ការរំលាយសមាគម ធ្វើបានក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | # ហេតុការណ៍រាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយនៃការរំលាយសមាគមក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ០ | ០ | ០ | ០ | ១ | ១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា១ករណីនៃការរំលាយសមាគមដោយមិនស្ម័គ្រចិត្ត។ |
| | # ការរាយការណ៍ពីហេតុការណ៍ការរំលាយណាមួយក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ០ | ០ | ០ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍ពុំបានកត់ត្រាករណី នៃការរំលាយណាមួយក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់។ |
| ២.១៦ សមាគមមិនត្រូវបានរឹតត្បិតមិនឱ្យធ្វើសកម្មភាពសេដ្ឋកិច្ចឡើយ | %នៃថ្នាក់ដឹកនាំសមាគមដែលយល់ថាសមាគមត្រូវបានរឹតត្បិតមិនឲ្យធ្វើសកម្មភាពសេដ្ឋកិច្ចឡើយ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៤% | ៧% | ៣% | ៤% | ០% | ៥% | សូមមើលសំណួរ៤.២២ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២.១៧ សមាគមមិនត្រូវបានរឹតត្បិតក្នុងការទទួលបានមូលនិធិ | %នៃថ្នាក់ដឹកនាំសមាគមដែលថា សមាគមពុំត្រូវបានរឹតត្បិតក្នុងការ ទទួលបានមូលនិធិ | ការស្ទង់មតិថ្នាក់ដឹកនាអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៨៣% | ៧២% | ៧៩% | ៨០% | ៧៦% | សូមមើលសំណួរ៤.២៤ និង៤.២៦ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព។ មូលនិធិក្នុងស្រុក = ៧៧% និង ជំមូលនិធិបរទេស = ៧៥% |
| ២.១៨ សមាគមពុំតម្រូវឱ្យបំពេញតាមលក្ខខណ្ឌរបាយការណ៍ហិរញ្ញវត្ថុច្រើនលើសលប់នោះទេ | %នៃថ្នាក់ដឹកនាំសមាគមដែលថាសមាគមត្រូវបំពេញ របាយការណ៍ហិរញ្ញវត្ថុ ច្រើនលើសលប់ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៦០% | ៥៨% | ៦០% | ៦៩% | ៥៤% | សូមមើលសំណួរ៤.១៥ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | % នៃថ្នាក់ដឹកនាំសមាគមបង្ហាញថា មិនអាចបំពេញរបាយការណ៍ហិរញ្ញ វត្ថុ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៦២% | ៣៦% | ១៦% | ១៩% | ២៥% | ២៧% | សូមមើលសំណួរ៤.១៣ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| ២.១៩ ស្ថាប័នរដ្ឋាភិបាលបង្ហាញសកម្មភាពការគោរពនិងការលើកកម្ពស់សិទ្ធិក្រុមអ្នកងាយរងគ្រោះ` សេរីភាពខាងសមាគម | % នៃថ្នាក់ដឹកនាំសមាគមបង្ហាញថាការសហការដែលត្រូវធ្វើជាមួយរដ្ឋាភិ បាលដើម្បីគោរពនិងលើកកម្ពស់សិទ្ធិរបស់ ក្រុមងាយរងគ្រោះ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | សូចនាករនេះនឹងត្រូវបានតាមដានចាប់ផ្តើមនៅឆ្នាំទី ៧។ |
| | #របាយការណ៍ព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដែលរដ្ឋាភិបាលបានប្តេជ្ញាបង្ហាញ សកម្មភាពលើកកម្ពស់ឬការពារសិទ្ធិរបស់ក្រុម ងាយរងគ្រោះ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | 0 | 0 | 0 | 0 | 0 | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយពុំបានកត់ត្រាករណីដែលរដ្ឋាភិបាលបង្ហាញសកម្មភាពលើកកម្ពស់សេរីភាពខាងការបង្កើតសមាគមឬការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះ។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សេរីភាពខាងការជួបប្រជុំ | | | | | | | | | |
| ២.២០ តំណាងសមាគមបុគ្គលឬតាមរយៈអង្គការអាចអនុវត្តសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី | % ថ្នាក់ដឹកនាំសមាគមដែលបានរាយការណ៍ថាអាចអនុវត្ត ដោយសេរីនូវសេរីភាពការជួបប្រជុំដោយសន្តិវិធី | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ១៩% | ១០% | ៤% | ៧% | ៧% | ៤% | សូមមើលសំណួរ៩.២ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # នៃហេតុការណ៍បានបង្ហាញថាការកំណត់ការរឹតត្បិតទៅលើសេរីភាពនៃការជួបប្រជុំ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៤៥ | ៥៧ | ៥ | ១០ | ១៥ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ១៥ករណីដែលរដ្ឋាភិបាលបានរឹតត្បិតការជួបប្រជុំ។ |
| | % នៃប្រធានបទការជួបប្រជុំទៅនឹងការជៀតជ្រែករបស់ហេតុដែលត្រូវបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៦% | ៩% | ១០% | ៣៣% | ២៦% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៣៨ ករណីនៃការជួបប្រជុំត្រូវបានជៀតជ្រែកដោយរដ្ឋាភិបាលក្នុងចំណោម១៤៦ នៃការជួបប្រជុំ។ |
| ២.២១ ក្រុមនានាអាចជួបប្រជុំដោយពុំចាំបាច់សុំឬទទួលការអនុញ្ញាតពីអាជ្ញាធរជាមុនឡើយ | # ការរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយនៃការជួបប្រជុំត្រូវបានរឹតត្បិតឬហាមឃាត់ផ្ទាល់ដោយសារតែកង្វះការអនុញ្ញាតជាមុន | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៧ | ៦ | ០ | ០ | ០ | ការតាមដានប្រព័ន្ធផ្សព្វផ្សាយមិនបានកត់ត្រានូវហេតុការណ៍ណាមួយនៃការជួបប្រជុំដែលត្រូវបានហាមឃាត់ឬមានការរឹតត្បិតដែលត្រូវបានធ្វើឡើងដោយសារតែមិនទទួលបានការអនុញ្ញាតជាមុន។ |
| | # នៃហេតុការណ៍បង្ហាញអំពីការជួបប្រជុំដែលត្រូវបានរឹតត្បិតនិងហាមឃាត់ផ្ទាល់ដោយសារតែកង្វះការអនុញ្ញាតជាមុន | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ២ | ១០ | ០ | ០ | ០ | មិនមានហេតុក្នុងការរាយការណ៍ពីហេតុការណ៍អំពីនៃការជួបប្រជុំដែលត្រូវបានហាមឃាត់ឬមានការរឹតត្បិតដោយសារតែពុំមានការអនុញ្ញាតជាមុន។ |
| | # នៃហេតុការណ៍តាមរយៈប្រព័ន្ធផ្សព្វផ្សាយអំពីការជួបប្រជុំដែលត្រូវបានជៀតជ្រែកជាមួយនឹងកង្វះការអនុញ្ញាតជាមុន | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៦ | ១៦ | ០ | ៤ | ២ | ការតាមដានប្រព័ន្ធផ្សព្វផ្សាយកត់ត្រា ២ ករណីនៃការជួបប្រជុំដែលត្រូវបានជៀតជ្រែកដោយសារតែមិនទទួលបានការអនុញ្ញាតជាមុន។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | # នៃហេតុការណ៍បង្ហាញថាការជួបប្រជុំ ត្រូវបានជ្រៀតជ្រែកជាមួយកង្វះការអនុញ្ញាតជាមុន | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៩ | ៥ | ០ | ០ | ០ | មិនមានហេតុការណ៍ក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាករណីការប្រមូលផ្តុំដែលត្រូវបានរឹតត្បិត ឬហាមឃាត់ ដោយសារតែពុំមានការអនុញ្ញាតមុន។ |
| ២.២២ ការហាមឃាត់ការជួបប្រជុំគឺជាវិធានការជម្រើសចុងក្រោយក្នុងករណីចាំបាច់ និងសមស្របទៅតាមគោលបំណងដែលចង់បាន | % នៃការជួបប្រជុំដែលគ្រោងទុកតាមប្រព័ន្ធផ្សព្វផ្សាយបានបង្ហាញថាត្រូវបានហាមឃាត់ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៣% | ៣% | ២% | ៦% | ២% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ២ ករណីនៃការជួបប្រជុំត្រូវបានហាមឃាត់ក្នុងចំណោមការជួបប្រជុំដែលបានគ្រោងទុកចំនួន ១២៥ ។ |
| | % នៃការហាមឃាត់បានបង្ហាញតាមរយៈប្រព័ន្ធផ្សព្វផ្សាយដោយគ្មានការផ្ដល់ជូនដំណឹងច្បាស់លាស់ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ២% | ២% | ២៥% | ៦០% | 0% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយមិនបានកត់ត្រាករណីការជួបប្រជុំត្រូវបានហាមឃាត់ដែលមានការបញ្ជាក់ពីមូលហេតុច្បាស់លាស់។ |
